# <u>មហាចោទល់ដែន</u>

## រឿងមហាចោរនៅទល់ដែនវគ្គទី១៖ខ្លាបាក់ចង្កូម

## ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

ផ្ទះនោះទាបប្រក់ស្បូវ ជញ្ជាំងក្តារ សង់លើដីទួលតូច តែស្អាត មានរបងអំពិលទឹកព័ទ្ធជុំវិញ។

ខាងមុខ គឺដងស្ទឹងនៃអាណាខេត្រសិរីសោភ័ណ្ឌ ដែលក្នុងនាឆ្នាំ១៨៦៥នេះ គង្គាហូរគំហុកយ៉ាងខ្លាំង ហាក់សម្តែងសេចក្តីក្រោតខឹងអំណាចសៀម ដែលសង្កត់សង្កិនយូរមកហើយ។ខាងក្រោយគឺជួរភ្នំស្វាយដែលលាតសន្ធឹងទៅឆ្ងាយទល់នឹងជើងមេឃ។

ក្នុងខ្ទមនៅទៅមាត់បង្អួច មនុស្សម្នាក់អង្គុយផ្អែកខ្នងលើកៅអីផ្តៅធំមួយសម្លឹងមិនព្រិចភ្នែកទៅគេហដ្ឋានមួយទៀតដែលល្អឆើតឆាយបីដូចវិមាននាឋានសួគ៌ាល័យ។

មនុស្សចាស់សក់ស្កូវ ពុកចង្ការស្រមូមសក្បុស ប៉ាន់អាយុប្រមាណចិតសិបប្លាយឆ្នាំ។

មើលរាងកាយ មើលភិនភាគ យើងសន្និដ្ឋានបានថា ពុំមែនជាមនុស្សសាមញ្ញទេ គឺប្រាកដជាមនុស្សពិសេសជាមិនខាន។

គាត់មានសម្បុរទង់ដែង។សម្បុរនេះបង្ហាញជីវិតរបស់គាត់ឲ្យយើងដឹងថា គាត់ពុំមែនជាមនុស្សជិះជាន់គេ ដែលស្រណុកនៅតែក្នុងម្លប់ ចាំតែគេបម្រើធ្វេងស្តាំនោះទេ។សម្បុរនេះជាសម្បុរមនុស្សលំបាក ហាលខ្យល់ ហាលថ្ងៃ ហាលភ្លៀង ជាមនុស្សពុះពារ ប្រឹងប្រែងតស៊ូ មានប្រដែងរកយុត្តិធម៌ និងសុភមង្គលជូនប្រទេសជាតិ និងប្រជាជនខ្មែរយើង។

ហេតុនេះតាចាស់យើងជាមនុស្សមានឧត្តមគតិខ្ពស់!!

ថ្ងាសគាត់ធំទូលាយ។នៅលើថ្ងាសនេះ យើងហាក់មើលឃើញរស្មីនៃការពិសោធធំៗ ដែលបោះបង្គោលជិតជាប់នៅនោះរួច ដែលនាំឲ្យយើងមានសន្តានចិត្តមួយកោតសរសើរដល់គាត់យ៉ាងជ្រាលជ្រៅបំផុត។

កាលយើងគយគន់គាត់ឲ្យយូរបន្តិចទៅទៀត យើងស្មើបរំភើបនឹងផ្នត់ដែលលាតបន្ទាត់យ៉ាងអង្កាញ់រសាំនៅលើថ្ងាសនោះ។គន្លងផ្នត់ទាំងនោះនិយាយប្រាប់យើងនូវអនុស្សាវរីយ៍ដ៏វិចិត្រផ្សេងៗ ដែលគាត់បានជួបប្រទះក្នុងដំណើរជីវិតរបស់គាត់ មានអនុស្សាវរីយ៍នៃសេចក្តីសប្បាយ អនុស្សាវរីយ៍នៃគ្រាក្រជាដើម។

អនុស្សាវរីយ៍ទាំងនោះជាគំរូនៃជីវិតដែលអាចត្រដាងបានជាខ្សែរឿងមួយយ៉ាងជក់ចិត្តដល់យុវជនដែលស្រឡាញ់ការដើរផ្សងព្រេងសំណាង ដូចវីរជនខ្លះក្នុងប្រលោមលោកធំៗនៃប្រទេសនានាក្នុងសម័យកាលបុរាណ។

ទឹកមុខរបស់តាចាស់យើងមើលឃើញគួរសម្បើម សម្បើមត្រង់គាត់មានថ្ងាមខ្លា និងភ្នែកមុត។តែបើយើងធ្លាប់ស្គាល់គាត់ យើងមុខជាស្រឡាញ់គាត់វិញ ពីព្រោះគាត់ជាមនុស្សស្លូត ចិត្តត្រង់ចេះអាណិត ចេះជួយសង្គ្រោះដល់អ្នកក្រីក្រ

គ្រប់ៗគ្នា មិនថាស្រី ឬប្រុស ក្មេងចាស់ទេ។ម្យ៉ាងទៀត គាត់ជាមនុស្សមានវោហារពូកែ មានប្រាជ្ញាវៃឆ្លាតណាស់ក្នុងការដោះស្រាយ និងមានសតិរឹងប៉ឹងចំពោះឧបសគ្គទាំងពួង។

វិសេសក្លាហាន នេះហើយជាឈ្មោះគាត់។

មេទ័ពជើងចាស់ វិសេសបានចូលបម្រើប្រទេសជាតិជាទាហានក្លាហានតាំងពីខ្លួននៅកម្លោះពេញវ័យនៅឡើយ។ ដោយចិត្តស្នេហាមាតុភូមិយ៉ាងជ្រាលជ្រៅ ដោយពលិកម្មមានការលះបង់ក្តីសប្បាយកាមរាគ ល្បែងស៊ីសង ស្រី ស្រា ជាដើម ដើម្បីបំពេញកិច្ចការសាធារណៈឲ្យបានហ្មត់ល្អ ដោយសតិសម្បជញ្ញៈ ចេះត្រិះរិះស្គាល់ខុសត្រូវ ដោយមានចិត្តជាមនុស្សសេរី មិនរវល់លុតក្រាបសំពះអង្វរអ្នកណាដើម្បីបុណ្យសក្តិខ្លួន វិសេសក្លាហានបានឡើងបុណ្យសក្តិជាលំដាប់ រហូតដល់បានជាមេទ័ពជាតិទាំងឡាយ។

កាលនៅមានកម្លាំងមាំមួននៅឡើយ វិសេសក្លាហានបានចូលប្រឡូកគ្រប់សង្គ្រាមទាំងអស់ រួចក្នុងសង្គ្រាមនីមួយៗ ជាមួយយួន ជាមួយសៀមក្តី ជាមួយលាវក្តី វិសេសក្លាហានមានសូរស័ព្ទទាំងសម្លេងឈ្មោះពីរោះ ប្រកបដោយជោគជ័យជានិច្ច។

តែដល់សម័យចូលវ័យជរាពិការនេះ ស្រុកដុនដាប ខ្មែរបែកសាមគ្គី អ្នកកាន់អំណាចខ្មែរមានចិត្តទន់ខ្សោយធ្វើការគ្មានវិធីសាស្រ្ត អត់បាយ ខ្មាំងចូលរុករានពាសពេញ វិសេសក្លាហានក៏ថយខ្លួនមកនៅក្នុងកូនដែលយើងបានពណ៌នាមកហើយនេះ។

រាល់ថ្ងៃ វិសេសក្លាហានភ្ញាក់ពីព្រលឹម អង្គុយសម្លក់គេហដ្ឋានដែលគាត់មើលឃើញតាមបង្អួចនេះ។

គាត់មានចិត្តទោមនស្សក្រៃពេក។ម្ចាស់គេហដ្ឋានដ៏ស្កុកស្គម្ភនោះឈ្មោះ ព្រះកម្ពុត ។ គឺជាខ្មែរមួយរូបដែរ ដែលបានទៅរៀននៅខាងសៀម រួចបានរលាយជាតិខ្លួនជាជាតិសៀម ភ្លេចនឹកនាដល់អរិយធម៌ខ្មែរ ដល់កត្តិយសខ្មែរ ដល់កិត្យានុភាពខ្មែរសូន្យឈឹង រួចគិតធ្វើបាបដល់រាស្រ្តខ្មែរ មានការចាប់ចង កំហែងគំរាម កេណ្ឌប្លន់ កាប់សម្លាប់គ្នាឯងជាដើម។

តាំងពីព្រះកម្ពុតមកគ្រប់គ្រងអាណាខេត្រសិរីសោភ័ណ តាងនាមរដ្ឋាភិបាលសៀមនេះ ព្រះកម្ពុតរស់នៅក្នុងការសប្បាយ(ស្រី ស្រា ល្បែង ភ្លេងភ្លាត់ច្រៀងរាំ)គ្រប់បែបយ៉ាង ហើយប្រើលទ្ធិផ្តាច់ការលើខ្មែរយើង។ប្រជានុរាស្រ្តក៏បានស្គាល់នូវទុក្ខវេទនាក្រៃពេកឥតមានពេលណាមកប្រៀបដូចបានឡើយ។ម្យ៉ាងទៀត ក្នុងការគ្រប់គ្រងនោះ ព្រះកម្ពុតគិតតែប្រមូលធនធានសម្បត្តិសម្រាប់តែខ្លួនមួយប៉ុណ្ណោះ។

អាស្រ័យហេតុនោះ ចំពោះប្រាសាទដ៏ល្អឆើតដែលវិសេសក្លាហានឃើញនោះ បើអ្នកមើលៗមិនឃើញរឿង មុខជាកោតសរសើរដល់ភ័ព្វសំណាងរបស់ព្រះកម្ពុតមិនខាន។

តែកែវភ្នែកវិសេសក្លាហានមើលប្រាសាទនោះឃើញជាភ្លើង ជាសាច់ ជាឈាម ជាញើស ជាកម្លាំងរបស់ប្រជាជនខ្មែរទៅវិញ។ប្រាសាទហាក់ឈរយ៉ាងក្រអើតដាក់គាត់គ្មានខ្លាច គ្មានអៀនឡើយ។

ដោយគាត់ចាស់ហើយ ដៃគាត់កាន់អាវុធទៀតពុំកើត ជើងគាត់រត់ដើរទៀតលែងបាន មាត់គាត់ប្រាសចាកអស់សម្លេង គាត់ហាក់ឃើញអានុភាពបុរាណរបស់គាត់ទ្រុឌទ្រោម ពីមុខអយុត្តិធម៌របស់ព្រះកម្ពុត។នៅក្នុងទ្រូងក្លាហានមានតែក្នុងចិត្ត កម្លាំងបញ្ញាទេដែលរស់រវើកក្នុងថ្លើមគាត់ ហើយដែលហេតុនាំឲ្យគាត់ចំបែងរាល់ពេលវេលា។

មួយថ្ងៃៗ គាត់សំឡឹងគេហដ្ឋាននោះដោយចេតនាចង់ឲ្យរលាយ ចង់ឲ្យឆេះ ចង់ឲ្យបាត់វិនាសសូន្យឈឹងទៅ។

ប្រាសាទព្រះកម្ពុតហាក់ធ្ងន់លើចិត្តវិសេសក្លាហានអ្វីម្ល៉េះទេ ពីព្រោះប្រាសាទនេះសាងលើដីខ្មែរ និងសាងលើស្មារស្រ្តខ្មែរ។ទឹកភ្នែកពីរតំណក់យ៉ាងល្វីងចត់ហូរធ្លាក់ពីនេត្ររីបុរសយើង។
ឱ! វិសេសក្លាហានអស់ឫទ្ធានុភាពហើយ។គាត់ជា ខ្លាបាក់ចង្កូម ។យើងមានចិត្តមេត្តាដល់ចាស់ព្រឹទ្ធាចារ្យពិសេសមួយនេះជាពន់ពេក។

សព្វថ្ងៃគាត់គ្មានទ្រព្យសម្បត្តិ គ្មានធនធាន គ្មានបាយបរិភោគគ្រប់គ្រាន់ គ្មានប្រដាប់ប្រដាប្រើប្រាស់សមរម្យ គ្មានខោអាវស្លៀកពាក់គួរសម គ្មានលុយកាក់ចាយវាយ គ្មានភូមិអាករ កំព្រាម្នាក់ឯងគ្មានទីពឹង។រឿងវិសេសក្លាហានផ្ទុយពីរឿងស្នេហាជាតិឯទៀតជាច្រើនរូប។

តែវិសេសក្លាហានពុំមានអារិះចិត្តនឹងឋានៈកំសត់ ទុគ៌តនេះទេ គាត់នឹកថាគាត់អាចបិទភ្នែកស្លាប់ទៅវិញដោយសតិសម្បជញ្ញៈរបស់គាត់នៅស្អាត គ្មានបន្ទោសអ្វីដល់គាត់ឡើយ។គាត់ស្លាប់ទៅវិញបាន ព្រោះផ្លូវដែលគាត់ជ្រើសរើសដើម្បីដើរ គឺផ្លូវថ្លៃថ្នូរប្រកបដោយកិត្តិយសពិតៗ។នឹកដូច្នោះ វិសេសក្លាហានមានទឹកមុខញញឹមយ៉ាងជ្រាលជ្រៅឡើងវិញ។

ក្នុងពេលនោះ ស្រីម្នាក់ចូលមកសម្អាតតុទូ។គឺជាមនុស្សម្នាក់អាយុប្រមាណជាងសែសិបឆ្នាំ។នាងនោះបើកទូឮក្រាក។វិសេសក្លាហានភ្ញាក់ខ្លួនព្រើត នៅស្ងៀមមួយស្របក់ ទើបមានវាចាសួរថា៖

- អ្នកណា? ភួងឬ?
- ចាស៎! ខ្ញុំ។
- ភួង! តើទេវីកូនស្រីខ្ញុំទៅណាហើយ?

នាងទាសីលុតជង្គង់ពីក្រោយខ្នងវិសេសក្លាហាន ឆ្លើយយ៉ាងគោរពវិញថា៖

- ចាស៎! នាងទៅបេះផ្កាក្រោយផ្ទះហើយ ពីព្រោះថ្ងៃនេះជាថ្ងៃសីលផង។
- កាលណាវាមកវិញ?
- ចាស៎! ជម្រាបប្រសាសន៍ ប្រហែលជាមិនយូរប៉ុន្មានទេ...

នាងរង់ចាំពាក្យអ្វីទៀតដែលឥតឮសោះ។នាងក៏បន្តការជូតតទៅទៀត គ្រាតែជ្រះស្រឡះទើបត្រឡប់ទៅក្នុងវិញបាត់ទៅ។រីឯវិសេសក្លាហាន កាលនិយាយទៅដល់ឈ្មោះកញ្ញាទេវី ជាបុត្រី ចិត្តស្នេហាបុត្រយ៉ាងខ្លាំងរត់ចូលឈៀបមកដល់ក្នុងបេះដូងគាត់។ទឹកមុខស្ងួតពីមុនមក ក៏ប្រែក្លាយជារីករាយប្រិមប្រិយទៅវិញ។រូបវលក្ខណ៍កល្យាណលេចធ្លោចេញមកក្នុងមនោគតិរបស់គាត់។គាត់ហាក់ឃើញស្រីឆោមសាច់សល្អផ្ទរផង់ ថ្ពាល់ខួច មុខស្រស់ ភ្នែក និងបបូរមាត់មានសម្ផស្ស ចង្កេះរៀវ ដំណើរសមសួន ល្អផុតនារីទាំងពួង។

ក្នុងពេលដ៏ខ្លីនោះព្រលឹងវិសេសក្លាហាន អណ្តែតទៅបបោសអង្អែលរូបទេវីជាបុត្រីទើបមានអាយុ១៨ឆ្នាំគត់។ស ន្តានចិត្តអាណិត អាណិតយុវតីមួយយ៉ាងគ្រលួចក៏ឈានជំហានមកប្រដេងកន្លែងសេចក្តីស្នេហានៃបុត្រីដែលមានអ ម្បាញ់មិញនេះ។

ភ័ព្វសំណាងអ្វីក៏អាក្រក់ម្ល៉េះ កញ្ញាដ៏ល្អវិចិត្រនេះម្តេចមកកើតចំអន្លង់ធំព្ទសូរឃ្យូរ។ទៅថ្ងៃមុខ គាត់ពុំដឹងថាស្ត្រីឧត្តម វេងទុក្ខវេទនាឬយ៉ាងណាទេ? ពុំដឹងជានាងទៅពឹងពាក់នរណា? ឱ! អនាគតគ្មានអ្វីទៀតសោះ។នាងជារូប ជាទី ព្រលឹង ជាទីសង្ឃឹមរបស់គាត់។ថ្ងៃជាថ្ងៃសីល នាងទៅបេះផ្កា នាងល្អដូចជាផ្កាកំពុងរីក នាងក្រអូបដូចផ្កា។នាង ថ្វាយបង្គំព្រះ ដៃនាងប្រណម្យ ជីវិតរបស់នាងរស់តែក្នុងធម៌ ក្នុងមេត្តា ក្នុងកុសល។នាងមានសម្តីផ្អែមពីរោះ ពុំដែល ចេះខឹងរហូតទៅដល់ជេរស្តីនរណាឡើយ។

ដោយផ្ទាំងអនាគតលោតត្រដាងឡើងពុំបានរុងរឿងសោះ នោះវិសេសក្លាហានមានទុក្ខព្រួយបារម្ភយ៉ាងខ្លាំង។ គាត់ នឹកថា ទៅថ្ងៃមុខ អ្នករួមសុខទុក្ខជាមួយកញ្ញាទេវី គឺប្រាកដជានាងភួង ពីព្រោះនាងភួងជាទាសីដែលបានបំបៅដោះ នាងទេវី។នាងភួងស្រឡាញ់នាងទេវីដូចជាកូនបង្កើត។នាងភួងពុំដាច់ចិត្តទៅណាចោលនាងទេវីសោះ ហើយព្រម រស់ដោយលំបាកជាមួយនាង ដើម្បីជួយមើលថែរក្សានាង ដើម្បីបានមើលមុខនាង។ ដោយនឹកឃើញដូច្នោះ វិសេស ក្លាហានអាណិតនាងភួងក្រៃពេក រកវត្ថុអ្វីមកប្រៀបផ្ទឹមស្មើគ្មាន៕

# រឿងមហាចោរនៅទល់ដែនវគ្គទី២៖បងប្អូនពីរនាក់

## ដោយសព្វវចនាធិប្បាយសេរីគីគីឌា

ព្រះសុរិយាចោលពន្លឺពណ៌មាសលើសិរីសោភ័ណ បីដូចប្រាប់ថាព្រឹត្តិការណ៍មួយយ៉ាងចម្លែក នឹងចាប់កើតមានថ្ងៃនោះតទៅមិនខាន។

ស្រីស្រស់ទេវី បុត្រីវិសេសក្លាហាន ដើរពីគុម្ពផ្កាមួយទៅគុម្ពផ្កាមួយ។

ព្រឹកនោះធម្មជាតិជូនទេសភាពមួយជាទីពេញចិត្តបំផុត។រុក្ខាមានស្លឹកពណ៌បៃតងខ្ចី ត្រដាងផ្ទៃមួយយ៉ាងធំទូលាយទៅលើពសុធា។នៅចុងស្លឹកនីមួយៗ នៅទងធាងនីមួយៗ នៅកៀនមែកនីមួយៗ គឺបុប្ផាពណ៌ស លឿង ខៀវ ក្រហម ស្វាយ រីករហង់ត្រង់នោះគ្រប់បែបយ៉ាង ខ្លះមានរំយោលឆើតឆាយ ខ្លះមានទងផ្កាជាក្បាច់ ជាក្បូរដែលធ្វើឲ្យចក្ខុមនុស្សលោកឃើញចម្លែកប្លែកអស្ចារ្យ ចង់ឲ្យតែទស្សនាគយគន់ មើលមិនចេះអស់មិនចេះហើយ។

ឱ! ស្នាដៃធម្មជាតិដែលចេះតុបតែងលោក តើអ្នកកើតឡើងសម្រាប់តែទេវីបុត្រីវិសេសក្លាហានម្នាក់ឯងឬ?ឬសម្រាប់អ្នកទាំងអស់គ្នា? អ្នកនិងកញ្ញាទេវី ហាក់ចេញតែពីគុម្ពមួយ ពីព្រោះល្អឆើតឆាយផុតវិសេសដូចគ្នា។

នាងទេវីដើរមួយៗ យ៉ាងស្រាលខ្លួន។ ស្រីស្រស់ក្រឡេកមើលនាយអាយ ឈប់រើសផ្កាណាដែលនាងស្រឡាញ់។ នាងបេះផ្កាមួយយកមកសៀតលេងនឹងសក់នាង។នាងយកមកល្បងសៀតលើទ្រូងនាង រួចយកមកដាក់ផ្ទឹមនឹងមុខនាង។នាងរឹតតែល្អជាងមុនទៅទៀត។នារីសប្បាយរីករាយក្នុងចិត្តឥតឧបមា។

ក្នុងមួយនាទីដ៏សុខសាន្តនេះ ដី ស្មៅ ឈើ ផ្កា ទឹក មេឃ ធម្មជាតិទាំងមូលគឺជាទ្រព្យរបស់នាងទាំងអស់ ដែលមាននាងជាព្រះខន្តិយានីយ៍ម្ចាស់ស្រីតែមួយ។

តាំងពីតូចមក នាងពុំដែលបានសប្បាយថ្ងៃណាមួយដូចថ្ងៃនេះឡើយ។នាងជាស្រីធ្លាប់តែរស់ក្នុងបរិវេណផ្ទះ ក្នុងជញ្ជាំងស្លឹកក្រៀមទាំងបួនជុំវិញ។ក្រៅពីព្រំដែនដែលវត្ថុមើលឃើញ កាន់បាននោះនៅមានរបងដែកមួយបែបទៀតដែលភ្នែកធម្មតាមើលមិនឃើញឡើយ គឺរបងទំនៀមទម្លាប់។

ខ័ណ្ឌសីមានេះ ចងក ចងដៃ ចងជើង ចងចិត្តនាងមិនឲ្យទៅណាបានឆ្ងាយពីខ្ទមនាងឡើយ។ហេតុនេះជីវិតទេវីស្រីកល្យាណគឺជាជីវិតក្នុងរូង ក្នុងអណ្តូងងងឹត ក្នុងកន្លែងឃុំឃាំងបីដូចជីវិតអ្នកទោស។ក្នុងមួយអាទិត្យទាល់តែចំថ្ងៃសីលទើបនាងបានចេញដើរម្តង ដោយមានកិច្ចបេះផ្កាជាហេតុ។ក្នុងពេលសេរីដ៏ថ្លៃវិចិត្រនេះ កញ្ញាហាក់បានធួរសាច់ ធួរឈាម ធួរសរសៃ ដោយបានដកដង្ហើមយកខ្យល់ថ្មីក្នុងទីសួន។

ហេតុថ្ងៃសីលចំពោះនាងគឺថ្ងៃរួចខ្លួន ថ្ងៃថ្មី ថ្ងៃសប្បាយ ថ្ងៃមនុស្ស ថ្ងៃស្មើមុខ ថ្ងៃសិទ្ធិ ថ្ងៃសេរី។

កញ្ញាបេះបុប្ផាគ្រប់ពណ៌បានមួយដុំធំ។នាងទៅបត់ជើងលើស្មៅ។នាងក្រងផ្កា នាងញញឹម នាងធ្មេចភ្នែក ចិត្តស្រីស្រម័យនឹក... នឹក... នាងនឹកដល់គូស្នេហារបស់នាង ម្តេចក៏បាត់យូរម្ល៉េះ មិនឃើញមក? តើប្រុសជីវិតទៅណា? តើ

ថ្លៃឧត្តមរវល់ការអ្វី? តើថ្លើមថ្លៃផុតអស់ប្រុសឈឺហើយ ឬដូចម្តេច? តើសង្សារប្រសើរភ្លេចនាងឬ? តើព្រលឹងបងស្នេហាប្អូនដូចប្អូនស្នេហាបងឬទេ? តើគូស្នេហាហ៊ានប្តូរជីវិតនឹងបងឬទេ?

ចំណោទទាំងប៉ុន្មាននេះ បុរសម្នាក់មាឌធំ ស្មាទូលាយ ដើមទ្រូងធំ ចង្កេះរាវ សក់រួញអង្គាជី មុខស្រស់ ភ្នែកមុតថ្លា សម្លៀកបំពាក់រុងរឿង អាវពណ៌ខៀវរលើបរលោង ដាវស្រោមពណ៌មាសព្យួរនៅចង្កេះ សមជាអ្នកមានបណ្តាសក្តិខ្ពស់ អាយុប្រមាណជាង២០ឆ្នាំ ស្ទុះភ្លែតចេញពីគុម្ពផ្ការហ័ស ដូចគ្នាមកចាប់ឱបនាងទេវីពីក្រោយរឹតជាប់ដូចដង្កាប់ ឱនមុខថើប...។

នារីជំបូងភ្ញាក់ខ្លួនដូចកន្ត្រាក់ ប៉ុន្តែលុះដៃនិងដៃជួបគ្នា មុខនិងមុខដល់គ្នា ម្រាមនាងរាវរឹតកប្រុសចម្លែកដើងឆើតនេះយ៉ាងខ្លាំងបន្ថែមទៀត។រួចគឺឈាមដែលរត់ខុសធម្មតា គឺបេះដូងដែលវាយលឿនជាងធម្មតាគឺមនោសញ្ចេតនាដែលជ្រួល ខ្នួលលើសធម្មតាក្នុងរូបយុវជនទាំងពីរ។

តណ្ហា! ឱតណ្ហា! នារីភ្លេចអស់ហើយ! ផ្កាទៅដោយផ្កា ឪពុកទៅដោយឪពុក ដីទៅដោយដី ធម្មជាតិទៅដោយធម្មជាតិ នៅសល់តែវត្ថុគឺបងនិងប្អូនប៉ុណ្ណោះដែលអ្នកផងស្គាល់ឈ្មោះហៅថា សេចក្តីស្នេហាឬរាគៈ ឬភ្លើងមេត្រី។

នាងទេវីនិយាយខ្សឹបៗដាក់ត្រចៀកបុរសថា៖

នាងហៅបន្តទៀត៖

- បង! បងមាននួ!

បុរសលើកស្រីឡើងឲ្យអង្គុយ។អ្នកសើចរកនាង ឃើញធ្មេញសស្គុស យកម្រាមដៃចាប់ចង្កានាងដោយមេត្រី រួចឆ្លើយតិចៗទៅវិញ៖

- បងស្រឡាញ់អូនណា! បងមិនចង់លែងអូនឲ្យផុតពីរង្វង់ដៃបងទេ បងចង់តែនៅឱបជាប់សាច់មួយជាមួយអូន។

នារីបែបអៀន មុខឡើងក្រហម ញញឹមចុងតមាត់តបទៅវិញ។បុរសចាប់បង្វិលខ្លួននាងយ៉ាងលឿន ខ្នងនាងក៏បានមកជាប់នឹងដើមទ្រូងប្រុសជាទីស្នេហា។

ក្នុងសន្ទុះនេះ ស្ត្រីផ្តេកក្បាលនាងលើស្មាមាននួជាគូជីវិតយ៉ាងស្និទ្ធស្នាល។ ដៃបុរសឱបរឹតចង្កេះនាង។ ដៃនាងអង្អែលដៃបុរស។ នាងហាក់បាត់ខ្មាសបន្តិចដែរ ដោយនៅមិនចំកែវភ្នែកបុរសដូចមុនពេក។ ស្រីជីតានិយាយដោយក្រៀមក្រំថា៖

- ប្អូនក៏ស្រឡាញ់បងដែរ... អូ ទេ! ប្អូនស្រឡាញ់បងណាស់។

បុរសឆ្លើយកាត់ដោយម៉ឺងម៉ាត់ថា៖

- អូនដឹងទេ ហេតុអ្វីបានជាអូនស្រឡាញ់បង?

នាងទេវីខ្នួលរំជួលក្នុងចិត្តពេកក្រៃ នាងគ្រវីក្បាលដកដង្ហើមធំឆ្លើយដោយមានសម្លេងស្រងូតស្រងាត់វិញថា៖

- ហ៊ី! ប្អូនអូននិយាយមិនបានអស់ដូចចិត្តទេ។ប៉ុន្តែបើនិយាយឲ្យខ្លី ប្អូនស្រឡាញ់បងពីព្រោះស្រឡាញ់ៗៗ ប៉ុណ្ណោះឯង។

មាននួមានចិត្តគ្រលួចអាណិតស្រី។នាងទេវីលើកដៃឡើងអង្អែលថ្ពាមបុរសជាទីស្នេហា។នាងនិយាយមួយៗថា៖

- ប្អូនស្រឡាញ់បង ពីព្រោះបងមានលក្ខណៈពេញជាមនុស្ស។
- ពេញយ៉ាងណា?
- គឺបងជាខ្មែរ បងស្រឡាញ់ជាតិខ្មែរ បងស្រឡាញ់អ្នកស្រុកខ្មែរ បងធ្វើការរកប្រយោជន៍ឲ្យខ្មែរ បងហ៊ានប្តូរជីវិតនិងខ្មែរ បងហ៊ានស្លាប់និងខ្មែរ បងមិនប្រកាន់កិច្ចការ មិនថាជាការណាជាការណា បងមិនយករឿងបុណ្យសក្តិមកជាគ្រឿងបំពុលខ្លួនបង បងមិនយករឿងទ្រព្យសម្បត្តិមកសង្កត់ខ្លួនបង មិនបង្ខូចខ្លួននឹងរឿងស្រី ស្រា ល្បែង របាំ។បងជាមនុស្សថ្លៃថ្លាណាស់... ប្អូនសូមទោស ប្អូននិយាយមិនអស់ទេ។

បុរសញញឹមរួចឆ្លើយវិញថា៖

- ក្នុងលោកនេះមានតែប្អូនមួយទេដែលចេះពិនិត្យមើល ហើយស្គាល់តម្លៃពិតៗរបស់មនុស្ស។បងស្រឡាញ់ប្អូន ពីព្រោះតែអូនមានចិត្តខ្ពស់មែននេះ។លាក់បាំងអ្វី មានខ្លះគេស្រឡាញ់មនុស្ស ដោយមនុស្សនោះមានបុណ្យសក្តិ ទ្រព្យសម្បត្តិ ចេះធ្វើឫកធំ ចេះក្អេងក្អាង ចេះដេក ចេះនៅស្ងៀមដោយឥតធ្វើការ ចេះបរិភោគម្ហូបឆ្ងាញ់ ដោយឥតចាំបាច់ធ្វើការបង្កើនឲ្យបានប្រាក់ ចេះវោហាអាងអួតខាងជេរស្តី ខាងបញ្ចោរ ចេះមួលបង្កាច់។ម្ល៉ោះហើយ អ្វីដែលខុសទៅជាត្រូវ ត្រូវទៅជាខុស អាក្រក់ទៅជាល្អ ល្អទៅជាអាក្រក់ បាត់អស់យុត្តិធម៌ សីលធម៌ មនុស្សធម៌។ម្យ៉ាងទៀត បងដែលស្រឡាញ់អូននេះគឺស្រឡាញ់ព្រោះតែអូនក្រ។បងដឹងថា គឺមកពីអូននេះហើយបានជាឪពុកបងមាន។ទ្រព្យសម្បត្តិដែលអូនត្រូវមាន បានទៅអ្នកមានវិញ។និយាយដូច្នេះ បងខ្លោចចិត្តអាណិតដល់ជនអ្នកក្រទាំងអស់គ្នាណាស់។សព្វថ្ងៃបងច្បាំងនឹងគំនិតលោភាទោសាទាំងនោះ ដើម្បីសេចក្តីសុខ និងសេចក្តីចម្រើនដល់អ្នកទាំងអស់គ្នាណាស់។ហេតុនេះ ចូរអូនត្រាទុកក្នុងចិត្ត ហើយចាំជានិច្ចថា ក្នុងជាតិនេះយើងស្រឡាញ់គ្នា ពុំមែនលើទុក្ខរបស់អ្នកឯទៀតទេ។អូនយល់ទេ?
- ចាស៎! យល់ហើយ បងនិយាយពីពោះស្តាប់ណាស់។ក្នុងជាតិនេះប្អូនសុំតែរស់ជាមួយបងទេ។ប្អូនមានចិត្តដូចបង គឺស្អប់ស្រីដែលចាំតែទីពឹងលើគេ ធ្វើការមានចៅហ្វាយបង្គាប់រួចសប្បាយតាមបុណ្យគេប៉ុណ្ណោះ។ប្អូនយល់ថា កើតមកជាមនុស្សត្រូវធ្វើដើម្បីរស់។មនុស្សត្រូវដុសខាត់ សម្អាតចិត្ត គឺមិនតាំងខ្លួនជាបញ្ញើក្អែក ឬជាឈ្លើង ដែលរស់ដោយសារឈាមគេនោះទេ។មនុស្សត្រូវរកកិត្តិយស រកសេចក្តីថ្កុំថ្កើង រកសេចក្តីថ្លៃថ្នូរ អំពីការងារដែលធ្វើនេះឯង។ប្អូនរីករាយនឹងរស់ជាមួយបងព្រោះបងមានគំនិតដូចប្អូន។តែប្អូនសុំចិត្តបងមួយ...។
- គឺអ្វី?
- គឺកុំទុកប្អូនជាគ្រឿងសម្រាប់សប្បាយ ជាវត្ថុសម្រាប់តម្រេកចិត្តបង ជាគ្រឿងសម្រាប់លម្អ ឬសម្រាប់បម្រើបង...។
- ប្អូនជាស្រី ប្អូនពុំមែនពឹងបងជាប្រុសនោះទេ។ប្អូនពឹង រួចត្រូវការយ៉ាងជាច់ខាតនឹងពឹង។

- តែប្អូនសុំបញ្ជាក់ថា ប្អូនពុំពឹងដូចគេឯងទេ។ប្អូនពឹងឲ្យបងជួយបណ្ដុះបណ្ដាលប្អូនឲ្យដឹង ឲ្យចេះ ឲ្យស្គាល់ផ្លូវល្អចម្រើនប៉ុណ្ណោះឯង។ស្ដាប់បានទេ?

មាននទ្ធពេញចិត្តក្រៃពេកនឹងសម្ដីនារីជាសង្សារ អ្នកពុំឆ្លើយភ្លាមទេ អ្នកឱនទៅថើបថ្ពាល់ស្រីដែលនៅជិតនឹងច្រមុះអ្នកស្រាប់។នាងទេវីស្រៀវខ្លួនខ្វាកៗ នាងចង់ឱនឱបលេបបុរសវិញ តែអៀនពេករកធ្វើអ្វីទៅមិនរួច។នាងរកឧបាយកំប្លែងលេងថា៖

- បងកុំទុកអូនដូចជាផ្កាណា! ថើបរួចគ្រវាត់ចោលនោះ។
- បងថើបអូន ព្រោះស្រឡាញ់អូនទេ។
- ដូច្នោះបងអត់ស្រឡាញ់អ្នកណាទៀតទេ។
- អ្នកឯទៀត បងស្រឡាញ់ជាមិត្រ ចំណែកអូន បងស្រឡាញ់ជាប្រពន្ធ វាខុសគ្នាឆ្ងាយណាស់ណ៎ា!បើដូច្នោះមានតែអូនចង់ឲ្យបងដើរថើបគេឯងតែពាសវាលទៅឬ?
- ទេៗ មិនបានជាដាច់ខាត...។
- ចូរអូនកុំទុកបងជាប្រុសផ្កាមាសណ៎ា! តោងទុកបងត្រឹមជាមាសបានហើយ។
- បងជាពេជ្រ។
- អូនជាទាំងគ្រាប់។
- ខ្ញុំមិនមែនជាអ្វីទាំងអស់ ខ្ញុំថ្លៃជាងនេះទៅទៀត ខ្ញុំជាមនុស្ស។
- បងជាមនុស្សដែរ។

ក្នុងលោកនោះ សូរស្គរលាន់ឮឡើងទូងៗ នៅឯគេហដ្ឋានព្រះកម្ពុត។មាននទ្ធងើបអើតមើលទៅទិសដែលសូររត់មកដល់។នាងទេវីក៏ក្រោកងាកមើលទៅតាម។ មាននទ្ធនិយាយទៅកាន់ថា៖

- បងសូមលាអូនសិន ដល់ម៉ោងគេប្រមូលទ័ពហើយ ចាំអាទិត្យក្រោយសឹមជួបគ្នាទៀត។

អ្នកសើចយ៉ាងស្រស់ដាក់នាង។នាងសើចយ៉ាងស្ងួតដាក់អ្នកដោយមិនចង់ឲ្យឃ្លាតសោះ។ មាននទ្ធស្ទង់ឃើញចិត្តនាង។អ្នកចាប់ដៃនាងទាំងពីរច្របាច់យ៉ាងខ្លាំង ឱនថើបជាចុងក្រោយបង្អស់ រួចនាងទេវីឈរមើលមុខសង្សារដែលថយខ្លួនមួយៗ ចេញពីនាងទាំងស្ដាយ។នារីខ្លោចផ្សាក្នុងចិត្តជាពន់ពេក។ នាងស្រែកតិចៗ ផ្ដាំថា៖

- បង! បង! យប់នេះពេលអាធ្រាត្រសុំជួបនឹងបងមួយភ្លែត ត្រង់ក្រោមដើមពោធិ៍ធំជិតខ្ទមអ្នកតា។

បុរសញញឹមដាក់នាង ងក់ក្បាលទទួលទន្ទេញថា៖

- យប់នេះ អាធ្រាត្រក្រោមដើមពោធិ៍ធំ។
- កុំខានណ៎ា!
- បាទ! ...កុំខានណ៎ា!
- ចាស៎!

ថាហើយបុរសស្ទុះភ្លែតត់ផ្លោះគុម្ពផ្កាទាំងពួងបាត់ទៅ។នាងកញ្ញាឈរមើលគូសង្សារយ៉ាងរំភើបញាប់ញ័រក្នុងចិត្ត។ នាងងាកចេញហាក់អស់កម្លាំងហេវទន់ដៃ ទន់ជើង ធេងធោងៗក្នុងខ្លួន។នាងដើរមួយៗ ទៅរើសផ្កាដែលនាងបេះចងទុកលើស្មៅ។

ដើរចេញពីទីស្នេហាបានប្រមាណ ប្រហែលដប់ជំហាន បុរសម្នាក់មាឌស្តើងមាំ ប្រដាប់ដោយ គ្រឿងទាហាន អាវុធនៅចង្កេះ រូបឆើត ស្ទុះចេញពីគុម្ពផ្កាមួយមកឱបនាងទេវីពីក្រោយ។ស្រីភ្ញាក់ខ្លួនស្ទើរភ្លាត់ស្មារតី នាងបម្រះយ៉ាងខ្លះអស់ទំហឹង ចងចិញ្ចើម ភ័យផង បបូរមាត់ស្លេកស្លាំង។

ក្នុងមួយវិនាទីនោះ នាងក៏បានរួចពីក្រញាំដៃ ពីបុរសថ្មី។បុរសសើចក្អាកក្អាយដោះមួកគំនាប់នាងយ៉ាងកំប្លែងអស់ពីចិត្ត។

នាងទេវីខាំធ្មេញគ្រឹត សំឡក់បុរស មុខនាងដែលស្លាំង ក៏ប្រែជាក្រហមភ្លាម។នាងនិយាយដោយសង្កត់ពាក្យទៅរកយុវជនចម្លែកថា៖

- យី! លោកកាមា! ចៀសចេញពីទីនេះឲ្យឆាប់។

នាងចង្អុលមុខបុរសដោយបន្តវាចាថា៖

- នែ! មុខលោកឯង កុំមកប៉ះសាច់ខ្ញុំណា! ប៉ះមិនបានទេ។ទៅៗ ស្អប់មុខណាស់។

បុរសឈ្មោះកាមា ពេបមាត់សើចយ៉ាងវែង ច្រត់ចង្កេះមើលនាងដែលខឹង ហើយពោលតបដោយសម្លេងក្អលខ្លាំងថា៖

- ស្រីដែលមានរូបល្អ ដូចអូន មិនគួរមានចិត្តអាក្រក់សោះ។

ថាហើយកាមាសើចក្អាកក្អាយ សើចឮរំពង។

- យី! អីលោកហ៊ានហៅរូបខ្ញុំអូនផង? ខ្ញុំជាប្អូនលោកពីកាលណាមក? មនុស្សអីក៏មានចិត្តឫស្យា មុខក្រាស់ម៉្លេះ?

ថាហើយ នាងច្រត់ដៃនឹងចង្កេះនាង សម្លឹងមុខបុរសគ្មានប្រហែលឡើយ។កាមាសើចដដែល។

- បើមិនឲ្យហៅអូន តើឲ្យខ្ញុំហៅអីវិញ? ហៅបង? ហៅអ្នកបង? ហៅមិនកើតទេ។

នាងទេវីឮសម្តីចុងក្រោយនេះ នាងស្មានក្នុងចិត្តថា ប្រហែលបុរសនេះឃើញនាង និងមានន្ទហើយ ពីព្រោះកាមាត្រូវជាប្អូនបង្កើតរបស់មានន្ទ។នាងខំទប់សេចក្តីអៀនខ្មាស ប្រឹងធ្វើទឹកមុខដដែល។

- យី! ចំណាស់ប៉ុនខ្ញុំ លោកហៅខ្ញុំបងមិនបានឬ?
- ហៅមិនបាន ព្រោះខ្ញុំស្រឡាញ់អ្នកយូរមកហើយ។ខ្ញុំចង់បានអ្នកជាប្រពន្ធខ្ញុំ។ខ្ញុំប្រាថ្នាលើកតម្កើងអ្នកឲ្យខ្ពស់ផុតអស់នារីដែលមាននៅលើលោកនេះ។ ខ្ញុំចង់ឲ្យអ្នកថ្កុំថ្កើងដោយសារស្នាដៃខ្ញុំ។
- មិនបាច់និយាយច្រើនទេ! ខ្ញុំមិនត្រូវការឲ្យលោកលើកតម្កើងខ្ញុំទេ ពាក្យថោក គំនិតទាប ខ្ញុំមិនចង់ស្តាប់លោកទេ។

បុរសឡើងក្រហមស្លឹកត្រចៀក។ដោយស្រឡាញ់នាងទេវីពេក កាមាមើលមុខនាងឃើញល្អអ្វី ក៏ល្អម្ល៉េះទេ ទោះកំពុងខឹងក្រញូវដូច្នោះក៏នៅតែល្អ។សម្លេងពីរោះអ្វីក៏ពីរោះម្ល៉េះ ទោះគំហក ជៀលត្មះប៉ុណ្ណោះហើយ ក៏នៅតែពីរោះ។អ្នកមើលមុខនាងដោយអង្វរ ហើយពោលថា៖

- ខ្ញុំទាប អ្នកខ្ពស់ បានជាខ្ញុំស្រឡាញ់អ្នក។ខ្ញុំសូមចិត្តអ្នកចុះ កុំខឹងអ្វីនឹងខ្ញុំ។ដោយស្រឡាញ់អ្នកពេកហើយ បានជាអម្បាញ់មិញ ខ្ញុំស្ទុះមកឱបអ្នក។សូមទោសអ្នកចុះ កុំប្រកាន់ខ្ញុំ។ខ្ញុំពិតជាស្រឡាញ់អ្នកមែន។ថ្ងៃនេះ ខ្ញុំចង់និយាយជាមួយនឹងអ្នកឲ្យបានវែងឆ្ងាយ ដើម្បីអ្នកយល់...។
- ខ្ញុំមិនបាច់ស្តាប់លោកទេ។ខ្ញុំមិនចង់ស្តាប់ ខ្ញុំមិនចង់យល់លោកទេ។

កាមាខឹងធ្ងួលក្នុងចិត្ត ដោយមើលឃើញជាក់ថា ធម៌ត្រជាក់មិនបានការ។អ្នកខាំធ្មេញដើរចូលទៅរកនាង ប្រាថ្នាគិតចាប់គំហែង ចាប់ដោយកម្លាំងតែម្តង។នារីសម្លឹងបុរសយ៉ាងកកាចបំផុត។កាមាទុចង់ក់។នាងពោលថា៖

- កាមា! កាមា! កាមា! កុំចូលជិត! តែបើចូល មានតែស្លាប់ និងរស់ប៉ុណ្ណោះ!
- ខ្ញុំមិនថយមួយជំហានទេ។
- ឈប់! កាមា បើចង់និយាយនឹងយើងណាស់ ឈរឲ្យស្ងៀមមួយកន្លែងចម្ងាយបីម៉ែតពីយើង។អើ! ធ្វើយ៉ាងហ្នឹង បានហៅថ្លៃថ្នូរ ពេញដោយជាកូនប្រុស។ឥឡូវនិយាយមកចុះ បើពេញជាកូនប្រុសព្រះកម្ពុតមែន ខ្ញុំស្តាប់។
- អ្នកជ្រាបទេ? ខ្ញុំស្រឡាញ់អ្នកយូរមកហើយ។ឪពុកខ្ញុំ ព្រះកម្ពុតជាចៅហ្វាយលើភពផែនដី ចង្វាត់សិរីសោភ័ណនេះ។ខ្ញុំអាចសូមឪពុកខ្ញុំ ចូលដណ្តឹងអ្នកបាន។តែខ្ញុំគ្រាន់តែចង់ដឹងចិត្តអ្នកបន្ថែមបន្តិចទៀតទេ បានជាខ្ញុំតែងឆ្លៀតឱកាស ចង់ជួបនឹងអ្នក ដើម្បីយើងនិយាយគ្នាឲ្យដឹងដើម ដឹងចុងបន្តិច។ឪពុកខ្ញុំប្រាកដជាស្រឡាញ់អ្នកដែរ ពីព្រោះគាត់បាននិយាយដំណាលពីរឿងអ្នករឿយៗណាស់។
- ឪពុកលោកតំណាលពីគ្រប់ស្រីដែលមានរូបល្អ។នេះជាការធម្មតាទេ។
- ទេ! លោកប្រហែលជាចង់បានអ្នកជាកូនប្រសាដែរ។
- ប្រហែលជាចង់បានខ្ញុំយកទៅធ្វើជាប្រពន្ធខ្លួនឯងទេដឹង? ឪពុកលោកជាមនុស្សមកពីអវចី ប្រពន្ធរាប់ដប់ម្ភៃ លួចកូនគេ លួចប្រពន្ធគេ។
- យីអ្នក! ខ្ញុំនិយាយមិនស្តាប់ បានតែបងមាននន្ទឬ ទើបនិយាយស្តាប់បាន?
- អើ! ខ្ញុំស្តាប់តែមាននន្ទពិតប្រាកដមែន។មាននន្ទជាគូសង្សារខ្ញុំ ជាប្តីខ្ញុំពេញចិត្ត។អើ! អើ! បើកាមាឯងជាប្អូនមាននន្ទ ហើយដឹងថាមាននន្ទជាបងកាមាឯងស្រឡាញ់ខ្ញុំហើយ ម្តេចក៏កាមាឯងមកស្រឡាញ់ខ្ញុំទៀត?ឬចង់ក្បត់មាននន្ទជាបងបង្កើត? លោកក្បត់ចុះ តែខ្ញុំ ខ្ញុំមិនក្បត់ទេ។កាមា! ខ្ញុំសូមលោករកស្រីណាទៀតទៅ មិនខ្វះទេ ស្រីល្អនោះ។តែធ្វើដូច្នោះ នាំឲ្យបាក់បែកគ្រួសារយើងទេ។ទៅ! កាមាអញ្ជើញទៅចុះ។

កាមារឹតតែខឹងទៀត អ្នកសំឡក់នាងទេវីស្ទើរផ្ទុះពីរបើ។ខ្យល់គំនុំមួយ បោកមកលើដួងចិត្តអ្នកដូចព្យុះសង្ឃរា។យ៉ាងរហ័សអ្នកបែរមុខចេញ ស្ទុះលោតកាត់គុម្ពផ្កាមួយ ពីមួយទៅមួយ តម្រង់ទៅគេហដ្ឋានព្រះកម្ពុតឪពុក។

នាងកញ្ញាទេវីបានធូរ ដូចដកបន្លាពីដើមទ្រូង ធូរចិត្ត ឈរមើលកាមាដែលបាត់ទៅ។អស់កម្លាំងហេវ នារីដើរមួយៗ ទៅកាន់ផ្ទះនាង៕

# រឿងមហាចោរនៅទល់ដែនវគ្គទី៣៖រាត្រីស្ងាត់

## ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

រាត្រីស្ងាត់ខ្យល់បក់ល្ហិចៗ ល្ហើយរហឹម។ស្លឹកឈើទាំងឡាយត្រូវនឹងវាយោដែលរត់សន្សឹមៗ កើតជាតូរ្យតន្ត្រីមួយយ៉ាងមនោរម្យ។
លើមេឃ ព្រះច័ន្ទចោលនេត្រាប្រកបដោយមេត្តា មកលើពិភពលោក ធ្វើឲ្យទេសភាពអាណាខេត្តសិរីសោភ័ណក្លាយទៅជាភាពយន្តមួយយ៉ាងកម្សត់។ផ្កាយភ្លឺព្រិចៗព្រោងព្រាតកណ្តាលផ្ទៃពពកខៀវស្រងាត់។
ក្នុងកូនផ្ទះ នាងទេវីអង្គុយបត់ជើងរវៃសូត្រពីមុខកូនចង្កៀងខ្លាញ់មួយ។សូររត់ព្យរ៉ែ តិចៗ ជើងចក់យំចឹកៗនៅលើដំបូល។
នារីស្រៀវខ្លួនខ្ញាក នឹកដល់ប្រុសជាទីស្នេហា។ចិត្តនាងរមួតរមួលខ្លាំង។ពន្លឺចង្កៀងធ្វើឲ្យឃើញមុខនាងក្រឡង់ដូចវង់ព្រះច័ន្ទ។កណ្តាលវង់នេះ ភ្នែកពីរបញ្ចាំងរស្មីយ៉ាងរលង់។ស្បែកបបូរមាត់ឃើញស្ពើង គួរឲ្យចង់អង្អែលលេង។
ដៃនាងធ្វើការ ចិត្តនាងហិចហើរទៅឆ្ងាយ ឆ្ងាយពីរហាត់ ឆ្ងាយពីផ្ទះ ឆ្ងាយពីរបង ឆ្ងាយដល់ដើមពោធិ៍ ដែលហាក់នៅជើងមេឃ ជុះតែងងរង់ចាំនាង។ដៃនាងធ្វើការ ភ្នែកនាងរំពៃលបមើលឪពុកនាងដែលសម្រាន្តបើកភ្នែកព្រិចៗ។
ទេវីស្រីទន្ទឹងចង់ឲ្យឪពុកនាងសម្រាន្តលង់លក់ទៅ។មួយនាទីកន្លងយូរ ហាក់ដូចមួយសតវត្សរ៍។ខាងក្រៅឆ្កែព្រុសឡូៗ ឮគួរឲ្យខ្លាច តែនាងបែរជាភ័យទៅវិញ ព្រោះខ្លាចសង្សារកម្សត់រង់ចាំនាង។ម្យ៉ាងទៀតខ្លាចក្រែងខានជួបហើយខាននិយាយ។នារីភ័យនឹងបានជួប នារីសប្បាយនឹងជីពចរនាងដើរឮទូងៗ ធ្ងន់ៗ...។
វិសេសក្លាហានក្រោកឈរឡើង។នាងទេវីភ្ញាក់។វិសេសក្លាហានដើរទៅជញ្ជាំង ចាប់យកដាវមួយយ៉ាងវែង ហូតផ្លែដាវចេញពីស្រោម មេដៃស្ទាបផ្លែដាវ។នាងទេវីមើលកាយវិការរបស់ឪពុកនាងគ្មានចោលកន្លែងណា។វិសេសក្លាហានចាប់ដងដាវដៃម្ខាង ដៃម្ខាងទៀតចាប់ចុងដាវសាកល្បង មើលហាក់សួរដាវថា នៅរឹងប៉ឹងទេ ?
ធ្វើដូច្នោះបណ្តើរ គាត់ងាកមកមើល និយាយនឹងនាងបណ្តើរ៖

- កូន! ល្មមទៅចូលរកដំណេកហើយ។

នារីដាក់ភ្នែកចុះនៅស្ងៀម ឪពុកនាងបន្តទៅទៀតយ៉ាងរាយមាយថា៖

- យប់ៗ កូនឯងខ្លាចអីឬ ?

នាងមើលទៅឪពុកនាង ចោលញញឹមយ៉ាងស្រស់ជូនទៅលោកឪពុក រួចហើយឆ្លើយយ៉ាងស្រួយស្រេះ៖

- កូនខ្លាចដែរ លោកឪពុក។
- ខ្លាចអី ?
- ខ្លាចចោរ។
- អត់ខ្លាចទេ។

- មិនមែនចោរលួចអីវ៉ាន់ទេ គឺចោរចាប់មនុស្សស្រីៗនោះណា!
- អី! ទៅខ្លាចអី អាចោរបែបនោះ? បើវាមក ឪពុកចាប់ដាវនេះជាចុងក្រោយបង្អស់។ឪពុកនឹងការពារកូនឲ្យបាន ដូចកាលឪពុកនៅកម្លោះ... ផ្តាំចាស់ម្តង។កុំព្រួយអី! ទៅ! ពន្លត់ភ្លើងដេកទៅ!

នាងទេវីក៏រុំអំបោះ តម្លោះរហាត់ រៀបចំទុកដាក់តាមកន្លែង ពន្លត់ភ្លើង ចូលដំណេកតាមពាក្យឪពុកនាង។ក្នុងមុងងងឹត លើពូកដែលមានកម្រាលសស្អាត នារីគេងងើយភ្នែកទៅលើគិត។រូបប្រុសថ្លៃវិសេសមកប្រឡែងលេងនឹងនាងក្នុងខួរក្បាលនាង។ស្ត្រីសប្បាយជាពន់ពេក។
មួយម៉ោងកន្លងទៅ... ពីរម៉ោងកន្លងទៅ... ស្រីលបស្តាប់ឮសូរឪពុកនាងស្រមុកខែៗ។យុវតីត្រេកអរព្រួចគ្រលួចក្នុងចិត្ត។
កល្យាណីរិះរកពាក្យសម្តីដើម្បីនិយាយនឹងសង្សាររបស់នាង។នាងគិតថា ត្រូវថែមត្រង់នេះមួយមាត់ ត្រូវបន្ថយពាក្យត្រង់នេះមួយឃ្លា រួចនាងទន្ទេញគំនិតដែលនាងរកឃើញហើយដែលនាងសន្មតថា ថ្លៃថ្លាពីពោះមែននោះ។កែវល្បងនិយាយឃ្លាឡើងវិញមួយដងជាពីរដង។
វិសេសក្លាហានសម្រាន្តលក់ស្កប់ស្កល់។កញ្ញាក្រោកពីគ្រែ ត្រចៀកប្រុងស្តាប់។គ្មានសូរអ្វីប្លែកឆ្លើយសោះ។ដល់ប្រាកដថា គ្មានឮអ្វីហើយ ទើបដីវ៉ាបើកមុងខ្វាក លបៗ បន្ទោរជើង ដើរតម្រង់ទៅមាត់ទ្វារ។នាងទាញទ្វារដោយទប់សូរមិនឲ្យឮឃឹតៗ ទ្វារចំហកាន់តែធំឡើងៗ។ទេវីបញ្ចិតខ្លួន លបស្តាប់ជាចុងក្រោយបង្អស់ ស្ទុះចេញទៅក្រៅ។ស្រីឆោមចាប់លើកសំពត់បន្តិចហើយរត់យ៉ាងលឿនកាត់តម្រង់ទៅដើមពោធិ៍។លុះឈប់ដកដង្ហើម ហូតកន្សែងជូតញើសបើកស្បៃគ្របសុដន់បង្ហើបបន្តិចបក់បញ្ចូលខ្យល់។
ឱ! រាត្រីស្ងាត់ភ្លឺព្រិលៗ ឃើញដើមឈើឈរស្លុងៗ អ្នកហាក់មានអានុភាពអ្វីម្ល៉េះ? អ្នកចាប់ចិត្ត ចាប់សតិបញ្ញាមនុស្សលោកឲ្យលង់លក់ក្នុងសុបិនមួយដ៏អស្ចារ្យដែលយើងចេតនាចង់ឲ្យតែពេលនៅនឹងដដែល ដើម្បីគ្រេបទេសភាពងងឹតស្រពិចស្រពិលដែលមានលាយទឹកស្នេហាសង្សារនេះឲ្យបានអស់ចិត្ត។
ចំពោះនាងទេវីស្រីនឹងកត់ត្រាទុកក្នុងចិត្តជាប់ជានិច្ចថា រាត្រីនេះជារាត្រីធំបំផុតតែមួយក្នុងមួយជីវិតរបស់នាង។ឆោមស្រស់ចង់ឲ្យរាត្រីនេះក្លាយទៅជារាត្រីឯករបស់ប្រវត្តិសង្ខារនាង។ សង្សារស្រីចង់សរសើររាត្រីនេះ ចង់ច្រៀងតែពីរាត្រីនេះ ប្រយោជន៍ឲ្យគូស្នេហ៍ជាន់ក្រោយៗស្គាល់តែរាត្រីមួយនេះ។
ជាអវសាន កែវចាំៗៗពុំឃើញប្រុសកម្លោះមកដល់សោះ។សូរចង្រិតយំក្នុងគុម្ពស្មៅ ធ្វើឲ្យចិត្តនាងស្រើបស្រាលត្រេកត្រអាលក្រៃពេក។អំពិលអំពែកហើរចោប់ភ្នែកនាងឲ្យមើលឃើញតាម ក្រែងឆ្លុះឃើញគូជីវិតរួចដឹងថាសង្សារនៅទីណា។សូរថ្លែនផ្លាស់កន្លែងទាញធក់ក្រដាសត្រចៀកនាងឲ្យតាមសូរ។
មិនយូរប៉ុន្មាន ស្រមោលមួយលេចចេញមក។
ស្រីឆោមត្រេកអរជាអនេក ស្ទើរលោតទៅលើមេឃ។នារីក្រោកឈររង់ចាំទទួល។ស្រមោលកាន់តែជិតមក។លុះបុរសម្នាក់មកដល់ បុត្រវិសេសក្លាហានចោលខ្លួនទាំងស្រុង ទៅក្នុងរង្វង់ដៃគូស្នេហាដែលនាងទន្ទឹងចាំផ្លូវ ដូចគេចាំមាតាមកពីផ្សារ។ទេវីស្រីលោតឱបរឹតបុរស ថ្វីត្បិតតែរង្វង់ដៃកម្លោះនេះរឹតនាងខ្លាំងទៅហើយ។
មានន្ទពុំបង្អង់ឲ្យខាតពេលឡើយ កក្រោយុវជនឱនក្រេបលំអងក្លិននារីដោយរួសរាន់ បន្ទាន់ចិត្តដែលស្នេហាយ៉ាង

ជ្រាលជ្រៅ។ទេវីស្រូបក្លិនសង្សារវិញយ៉ាងតិចៗ តែយ៉ាងខ្ជួលខ្ជាញ់ព្រោះនាងខ្មាសច្រើនណាស់ទៅហើយ។ គឺបុរសហើយ ដែលកាត់សុបិនដ៏ថ្លៃថ្លានេះ ហើយដែលដាស់នាងឲ្យដឹងខ្លួនមកនៅលើពិភពលោកយើងនេះវិញ។

- អូន! អូន! អូន!

យុវតីរឹតតែឱបគូជីវិតខ្លាំងទៅទៀត ដោយឥតឆ្លើយតបវិញឡើយ មាននន្ទបន្តវាចាទៅទៀតថា៖

- អូន! អូនកុំឲ្យខាតពេលយើង។
- ចា៎ះ!
- អូន! ម្ដេងក៏ម្ដងនេះ អូនហាក់ដូចជាញាប់ញ័រជាងសព្វថ្ងៃមួយជងម្ល៉េះ? អូនមានរឿងអ្វី អូនកើតអ្វី?
- ចា៎ះ! ចា៎ះ! ខ្ញុំញ័រដោយត្រេកអរបានជួបនឹងបង ប្អូនអត់កើតអ្វីទេ ប្អូនសប្បាយ។ ទេ! ប្អូនមានទុក្ខ អ៊ុំ! ទេ ប្អូនសប្បាយទេ។
- ប្អូនសប្បាយ?
- ចា៎ះ! ប្អូនសប្បាយ! ប្អូនសូមជម្រាបរឿងមួយដល់បងឲ្យបានជ្រាប។ រឿងប្អូនជាស្រីដូចស្រីឯទៀត។ រឿងប្អូនឥតប្លែកពីស្រីឯទៀតទេ។ ចា៎ះ! ចា៎ះ! រឿងប្អូនដូចជារឿងអ្នកឯទៀត... ។

មាននន្ទសើចដោយឃើញថា នាងនិយាយពុំទៅមុខសោះ។ បុរសអង្រួនស្មានាងថា៖

- នែ! បងស្ដាប់បានហើយ! រឿងអ្វី?

នារីជំទើតចុងជើង ដើម្បីឲ្យមាត់របស់នាងទៅជិតត្រចៀកប្ដីនាងបន្តិចទៅទៀត៖

- បង! បង!
- បាទ!
- ប្អូន! ... ឱ! ... ប្អូននិយាយមិនរួចទេ។ ប្អូន... ។

មាននន្ទតឹងដើមទ្រូង និយាយដាច់ៗនេះជាពន់ពេក តែបុរសឃើញថា កែវកម្សត់ប្រែភេទខុសពីធម្មតាខ្លាំងណាស់។ អ្នកឱបរឹតជីតារឹតតែខ្លាំងឡើង។ អ្នកយកម្រាមដៃអង្អែលសាច់នាងថ្នមៗ រួចពោលសម្ដីយ៉ាងទន់ភ្លន់ថា៖

- អូន! សូមនិយាយមក កុំឲ្យបងចាំស្ដាប់យូរពេក។ ប្អូនធ្លាប់គប់ប្រសព្វនឹងបង ជាយូរណាស់មកហើយ។ គួរណាស់ តែអូនស្ដាប់បងឲ្យជាក់។ អូនៗ សូមទុកចិត្តបងចុះ បងនឹងជួយអូន ទោះដល់ក្ដីមរណៈក៏បងហ៊ានដែរ។ ឱ! ក្នុងជាតិនេះ បងស្រឡាញ់អូនអស់ប៉ុណ្ណឹងហើយ គឺថាឥតមានរបស់អ្វីមកប្រៀបផ្ទឹមបានទេ។ សូមអូននិយាយមកចុះ បងចាំស្ដាប់។
- ចា៎ះ! ... ចា៎ះ! ... ហ៊ឺ! ប្អូននិយាយមិនបានទេ។ ចាំយប់ស្អែកទៀតចុះ។
- ទេ! បងចង់ដឹងតែយប់នេះឯង។
- ចា៎ះ! ហ៊ឺ! សូមចាំដល់យើងបែកគ្នាសិន។
- ទេ! បងចង់ដឹងតែឥឡូវនេះឯង។
- បង! បង!

នារីឱបបុរសយ៉ាងខ្លាំងជាថ្មីម្តងទៀត រួចបន្តវាចាថា៖

- ចាំះ! បងៗ ប្អូនខ្មាសបងណាស់។
- អូនមិនស្រឡាញ់បងទេ?
- អូនស្រឡាញ់ៗជីវិតមួយ។
- ប្រាប់មក។
- ចាំះ! ប្អូនមាន... ។
- មានអី?
- ផ្ទៃពោះ។
- មានផ្ទៃ? អីអូនមានផ្ទៃពោះ?
- ចាំះ! ប្អូនជាមាតានៃបុត្ររបស់បងចំនួនពីរខែហើយ។

បុរសចាប់មុខនាង ដៃទាំងពីរប្រេបាច់ដោយស្នេហា និងដោយរីករាយយ៉ាងខ្លាំង។ នារីបន្តកិច្ចសន្ទនាតទៅទៀតថា៖

- ចាំះ! ប្អូនមានផ្ទៃពោះ បន្តិចទៀត បុត្រមួយនឹងកើតឡើងមានរូបល្អដូចបង។ ក្នុងសាច់ សរសៃឆ្អឹងរបស់កូននេះ ឈាមបង និងឈាមប្អូនហូរលាយគ្នា។ ឱ បង! កូននោះមានឬកពាដូចបង មានសម្តីដូចបង មានសន្តានចិត្តដូចបងមិនខាន។ បន្តិចទៀត ប្អូនបីបុត្រនោះនឹងដៃប្អូនហើយ។ ឱ! បន្តិចទៀតប្អូនបំបៅបុត្រនោះ ប្អូនចិញ្ចឹមបុត្រនោះ។ បង! បងធ្វើយ៉ាងណា? ឥឡូវនេះ? ដើម្បីកុំឲ្យអ្នកជិតផងតិះដៀលប្អូនជាស្រី! បងចោលប្អូនឬ?

ទឹកភ្នែកហូរសស្រាក់ពីភ្នែកនាងទេវី។ មានន្ទរំជួលដួងចិត្ត អាណិតសង្សារកម្សត់។ អ្នកតបថា៖

- មិនអីទេ យើងរៀបការគ្នាឆាប់ៗនេះ។

កញ្ញារីករាយយ៉ាងណា អស្ចារ្យនឹងពាក្យនេះ។ គឺជាពាក្យដែលនាងរង់ចាំប្តូរស្លាប់ ប្តូរស់។

- ចុះ ឪពុកបងថាម៉េច?
- ឪពុកជាឪពុក ប្រពន្ធជាប្រពន្ធ!

ទេវីទទួលពាក្យនេះដោយពេញចិត្តទៀត។ ស្ត្រីសើចទាំងទឹកភ្នែករមៀល ស្រក់តក់ៗ ធ្លាក់លើទ្រូងមានន្ទ ដែលមានចិត្តខ្លោចផ្សាឥតឧបមា។

បុរសពុំចង់ឲ្យនាងយំទេ ពុំចង់ឲ្យនាងកើតទុក្ខទេ អ្នកចង់ឲ្យសង្សារសប្បាយ។ អ្នកពន្យល់នាងថា៖

- កុំយំអូន! គេយំតែកាលណាស្រុកខ្ញុំគេ។ បងមិនចោលអូនទេ បងប្តេជ្ញាថា ទោះមានរឿងរ៉ាវឪពុកម្តាយ បងប្អូន ជំទាស់យ៉ាងណា ក៏បងយកអូនជាប្រពន្ធដែរ។ ចូរអូនកុំភ័យអី ព្រោះយើងនិយាយថា យើងសាងសុខដោយខ្លួនយើង។ យើងគ្មានគំនិត ពឹងផ្អែកផ្តេករកសុខលើចន្ទល់អ្នកណាទេ។ អូននិងបង បានគិតហើយ បានយល់ហើយ យើងស្រឡាញ់គ្នា។ គំនិត និងបំណងនេះ ជាទេពវត្ថុ ដែលគ្មានអ្វីមករំលោយបានឡើយ។ យើងជាមនុស្ស យើងជាអ្នកសម្រេចវាសនាយើង យើងជ្រើសរើសផ្លូវយើងដើរ យើងគូសវាសជីវិតយើង

ដោយខ្លួនយើង នេះជាការធម្មតាទេ យើងជាយុត្តិធម៌តាមគន្លងធម៌ទៀតផង។ រីឯមាតាបិតាយើងទុកជាធំជានិច្ច ក៏ប៉ុន្តែដែលល្អប្រពៃ មិនត្រូវបញ្ចុះតម្លៃខ្លួនឲ្យទាប អាម៉ាស់ខ្លួនរហូតទៅផ្តាច់កូន ឲ្យបែកគូគេនោះទេ។ បើមាតាបិតាខ្លះ ធ្វើដូចនេះ គឺជាមាតាបិតាប្រើអំណាចលើកូន គឺជាអំពើសង្កត់សង្កិនមនុស្ស ក៏លាមកក្រៃលែង។ ចូរអូនគិតមើល ពាក្យថាសម្លាប់ស្នេហា កាត់ចំណងមេត្រីភាព រំលាយរឿងកម្សត់ផ្សេងៗ ជាពាក្យមួយ ដែលគ្មានជនណាចង់ឮទេ។ តែកាលណា គេឮឡើង គេអារចិត្ត គេខាំធ្មេញ គេខឹង។ ឯណាយុត្តិធម៌ ឯណាសីលធម៌ ឯណាមនុស្សធម៌ ឯណាធម៌ព្រះ បើធ្វើឲ្យព្រាត់ប្រាស់គូគេនោះ? ការបង្ខំ ការបង្គាប់ ការគំរាម ការត្រួតត្រាលើចិត្តមនុស្ស ជាអំពើអមនុស្សធម៌ចំពោះមនុស្សដូចគ្នា ដែលចេះគិត ចេះគូរ។ ក្នុងលោកនេះបងសូមកុំឲ្យមានរឿងអកុសលដូចនេះទៀតឡើយ គឺសូមឲ្យគូស្នេហាបានជួបគ្នា អាចទុកដាក់ខ្លួនឯង តាមសេចក្តីយល់ឃើញរបស់ខ្លួន។

- ចាំះ ! ប្អូនបានធូរស្បើយបន្តិចដែរ តែពុំដឹងជាមានរឿងអ្វីទៀតទេ ដែលអាចជំទាស់មិនឲ្យយើងជួបគ្នាបាន!
- ចូរអូនដឹងឲ្យច្បាស់ថា មនុស្សអ្នកគិតការ ទេវតាអ្នកសំរេច។ ចំពោះឪពុករបស់អូន បងជឿថា លោកចាស់ហើយ ហើយលោកស្គាល់បង ដឹងចិត្តបង ស្រលាញ់បងណាស់។

នាងទេវីដកដង្ហើមធំ។ ស្រីគ្រវីក្បាល ដោយនឹកឃើញរឿងមួយទៀត។ នាងនិយាយស្រងូតស្រងាត់ថា៖

- បង ! ប្អូនមិនគួរមកស្រលាញ់បងទេ ។ ប្អូនទាបណាស់ ។ យើងខុសគ្នាដូចមេឃ និងដី។ រឿងខុសគ្នាខ្លាំងពេកនេះហើយ ដែលនាំឲ្យប្អូនមានទុក្ខព្រួយយ៉ាងខ្លាំងនៅពេលនេះ។ បើសិនជាប្អូនយកអ្នកក្រដូចគ្នា ម្ល៉េះសមប្អូនមិនបានទុក្ខព្រួយដូច្នោះទេ។
- កុំគិតដូចនោះអូន ... ខុសស្រឡះ។ នែ ! អូន ! យើងកើតមកលើលោកនេះ គ្មានអ្នកណាយកបុណ្យស័ក្តិ និងទ្រព្យសម្បត្តិមកជាមួយផងទេ មនុស្សកើតឡើងខ្លួនទទេដូចៗគ្នា។ សព្វថ្ងៃអូនក្រ ។មកពីបងមាន។ ស្តាប់បានទេ ?គឺថាទ្រព្យដែលអូនត្រូវបាន ទៅជាហូរមកចូលហឹបបងវិញ។ ឯចំនែកខាងបុណ្យសក្តិវិញ មនុស្សត្រូវតែងចង់បាន។ ក៏ប៉ុន្តែបើចង់បាន ត្រូវមើលនាយមើលអាយសិន។ មានខ្លះចង់បានបុណ្យសក្តិ ខំបន្ទុះបន្ទាលខ្លួនដោយរៀនសូត្រតំរិះវិជ្ជាផ្សេងៗ ឲ្យបានចេះដឹងជ្រៅជ្រះ ហើយខិតខំធ្វើការបំរើប្រទេសជាតិ និងប្រជាជនឲ្យបានគង់វង្សស្ថិតស្ថេរចិរកាលទៅ។ ជនបែបនេះហើយដែលប្អូនត្រូវស្វែងរកឲ្យបានជួប។ ......

កាលពេលដែលមានន្ទ និងនាងទេវីកំពុងនិយាយគ្នានេះ ស្រមោលមួយលបស្តាប់នៅជិតនោះ រួចរសាត់យ៉ាងលឿនទៅឯខាងផ្ទះនាងទេវី។ គឺស្រមោលកាមាប្អូនមានន្ទ បុត្របន្ទាត់របស់ព្រះកំពុត មេទ័ពខាងតំបន់ម្លូព្រៃ ក្រោមកិច្ចបញ្ជាការរបស់មានន្ទជាបង ដែលជាមេទ័ពនាអាណាខេត្តសិរីសោភ័ណនេះឯង។ កាមាទៅដល់ខ្ទមរំសេសក្លាហានប្រានទ្វារចូល រួចបង្ហូកឡើងថា៖

- លោកអ៊ំ ! លោកអ៊ំ !

ចុងដាវវិសេសក្លាហានផ្ទុចមកចំចុងដង្ហើមកាមាជាស្រេច។ ស្រឡាំងកាំងក្នុងងងឹត កាមាហៀប នឹងនិយាយ តែវិសេសក្លាហានគំហកថា៖

- នៅស្ងៀម អាចោរកំណាច ! ឯងហ៊ានតែកម្រើកខ្លួន ជីវិតឯងសូន្យក្នុងពេលនេះឥឡូវ !
- ខ្ញុំបាទមិនមែនចោរទេ លោកអ៊ំ!
- បើឯងពុំមែនចោរ ម្ដេចឯងចូលក្នុងផ្ទះអញទាំងយប់? ឯងមកមានការអ្វី ?
- ខ្ញុំបាទយកការណ៍មួយអាម៉ាស់បំផុតមកជំរាបលោកអ៊ំឲ្យបានជ្រាប។

វិសេសក្លាហានគំហកថា៖

- ការអ្វី អាចោរអប្បលក្ខណ៍ ? អញដឹងហើយការដែលឯងចង់និយាយនឹងអញ។ ហ៊ឺសៗ ឳពុកឯង និងអញជាគូសត្រូវប្រចាំជីវិតនឹងគ្នា។ ឳពុកឯងគុំអញស៊ីសាច់ហុតឈាម។ អញគុំឳពុកឯងវិញដូច្នោះដែរ។ រាល់ថ្ងៃអញនៅទីនេះ ទន្ទឹងចាំរឿងដែលឳពុកឯងបង្កើតឡើង ដើម្បីរំលោភលើអញ។ អានាងពេលមកដល់មែន។ ឥឡូវគ្មានអ្វីច្រើនទេ ចូលមកចុះ ដកដាវឡើងកុំទុកឲ្យនៅស្ងៀមយូរទាន់ចិត្តនៅក្ដៅៗ ដាវអញសំរាកយូរមកហើយ ទើបមកដល់ឥឡូវដាវអញមានចិត្តរីករាយ និង មានសកម្មភាពជាថ្មី។ មកអានាង។ ឱ ! ឳពុកឯងចំជាមនុស្សកំសាកញីណាស់អីមិនហ៊ានស៊ូនឹងអញដោយខ្លួនឯងទេ? ទើបប្រើឯងមកនេះ រួចប្រើមកទាំងយប់ទៀត ! ហាសៗ ឳពុកឯងមិនសមកិត្តិយសជាស្ដេចត្រាញ់ពិតៗនោះទេ។ ឳពុកឯងស្លាប់នឹងគ្រឿងអាវុធអញរឺ ?

កាមាសើចបើកភ្នែកធំៗ។

- សូមទោសលោកអ៊ំ ខ្ញុំមិនដឹងរឿងទាំងនេះទេ។ រឿងទាំងនេះជារឿងផ្ទាល់ខ្លួនរបស់លោកអ៊ំទេ ដែលប៉ះពាល់ដល់កិត្តិនាមលោកអ៊ំ។ ដែលខ្ញុំមកនេះ ... ។
- កុំលាក់ កុំធ្វើពុត កុំធ្វើពើ ... អើបើឯងមិនដឹង អញជាអ្នកប្រាប់ឲ្យឯងដឹង។
- ទេ ៗ ៗ លោកអ៊ំ កុំទាន់អាល ខ្ញុំសូមនិយាយមួយម៉ាត់សិន។
- ឱ ឯងភ័យខ្លាចស្លាប់ដែរ? ឯងមិនសមជាកូនប្រុសទេ។
- ហ៊ី ! លោកអ៊ំ ខ្ញុំនិយាយមួយម៉ាត់ទេ។
- និយាយភ្លាម កុំបង្អង់ អញសម្លាប់ចោលឥឡូវនេះ។
- បាទ ! ខ្ញុំបាទមកនេះដើម្បីនិយាយហើយតើ ប៉ុន្តែបើចុងដាវនៅផ្ទាប់នឹងចុងដង្ហើមយ៉ាងនេះ និយាយម្ដេចកើត ?
- ហាៗ ! អញមិនចេះសម្លាប់មនុស្សដែលឥតមានអាវុធនៅក្នុងដៃទេ នៅឲ្យស្ងៀមកុំកម្រើក។

ក្នុងមួយវិនាទីនោះ វិសេសក្លាហានចូលប្រកៀកនឹងខ្លួនកាមា ហូតយកដាវដែលព្យួរនៅចង្កេះគ្រវាត់ឮប្រាវលើក្ដារ ផែកឆេរមើលសព្វហោប៉ៅពុំឃើញមានអាវុធអ្វីទៀត ក៏បញ្ជាឲ្យកាមាអង្គុយលើកៅអីជិតនោះ កាមាធ្វើតាមបង្គាប់។ មួយសន្ទុះក្រោយមក ចង្កៀងខ្លាញ់ក៏ភ្លឺឡើង កាមាញញឹមយ៉ាងខែងរកវិសេសក្លាហាន ដែលប្រុងស្មារតីគ្មានធ្វេសសោះឡើយ។

- មើលរឿងអ្វី ?
- សូមលោកអ៊ំ មើលទៅបន្ទាប់កូនស្រីលោកអ៊ំមើល។

វិសេសក្លាហានងាកទៅមើលទ្វារ ឃើញចំហមួយប្រលោះខ្លួន។ លោកភ្ញាក់ខ្លួនខ្វាក ស្ទង់ដឹងស្ថានការណ៍កើតសង្ស័យ ចិត្តក្តៅក្តួល។ កាមាកាន់ជ័យជំនះមួយយ៉ាងអស្ចារ្យនៅពេលនោះ។

- សូមលោកអ៊ំអញ្ជើញចូលមើលលើគ្រែកូនស្រីលោកអ៊ំមើល។

វិសេសក្លាហានស្ទុះភ្លែតចូលក្នុងបន្ទប់នារី យកចុងដាវវាត់បើកមុងមានតែពូក និងខ្នើយ។ ចិត្តមោហោមួយយ៉ាងរំពងក្នុងរាត្រីស្ងាត់ថា៖

- ហាស់ ! កូនស្រី ! ទេវី !

សូរសម្រែកឮបានតែប៉ុណ្ណោះតាចាស់យើងដួលផ្ងាខ្លួនទៅក្រោយសន្លប់បាត់ស្មារតី។ កាមាឃើញដូច្នោះ ក៏ក្រោកពីកៅអីឈានជើងទៅយកដាវខ្លួនដែលដេកលើក្តារមកស៊កចូលក្នុងស្រោមដូចមុន រួចផ្លោះតាមបង្អួចទៅបាត់ក្នុងទីងងឹតទៅ។ សម្រែកវិសេសក្លាហានលាន់ឮស្ទើរហែកមេឃ។ សូរសម្រែកបោះពួយក្នុងអាកាសទៅដល់ត្រចៀកនាងទេវី ដែលកំពុងនិយាយលេងយ៉ាងរីករាយជាមួយមានន្ទជាគូគាប់ នាងឈប់ង៉ក់ដូចគេកន្ត្រាក់។ កញ្ញាងើបក្បាលឡើងពីជង្គង់មានន្ទដោយបើកភ្នែកធំៗ ។ ដើមទ្រូងនាងញ័រយ៉ាងខ្លាំង។ ស្រីហាក់ដឹងរឿងអាសន្នអស់។ នាងច្រានមានន្ទរឹងដែលដួលទៅក្រោយ រួចរត់សំដៅទៅផ្ទះ។ មានន្ទស្រឡាំងកាំងក្រោកឡើងបោសគូទស្រែកដោយសម្លេងហៅនាង៖

- ឈប់ៗ រឿងអ្វី ? ទេវីអូន !

តែនារីទៅឆ្ងាយណាស់ទៅហើយ បុរសក៏ដើរតាមក្រោយនាងទៅ ដោយឈានជើងយ៉ាងវែងៗ ប្រញាប់ប្រញាល់ឲ្យបានទាន់គូជីតាពន្លឺចង្កៀងចោះប្រលោះមួយយ៉ាងធំក្នុងអាកាសងងឹត តាមទ្វារខ្ទមដែលចំហ។ នាងទេវីទុចជើងដោយបានឃើញពន្លឺនេះ។

ពន្លឺធ្វើឲ្យនាងកើតក្តីខ្លាច តែទោះដល់មរណៈក៏ដោយនាងត្រូវតែចូលទៅរកពន្លឺនេះ។ ព្រលឹងនៅចុងសក់ កញ្ញាប្រឹងទប់សន្តានចិត្តកុំឲ្យជ្រួលច្របល់ពេក តែឥតប្រយោជន៍។ ស្រីដឹងមុនថា ទុក្ខមួយយ៉ាងធំនឹងមានដល់នាងក្នុងមួយភ្លែតទៀតនេះ តែនាងយល់ថាចៀសទុក្ខនេះមិនបានផុតទេ នាងត្រូវតែប៉ះទង្គិចជាដាច់ខាត។ នាងនឹកថា មិនអីទេខ្លួននាងខុស ហើយនាងព្រមទទួលទុក្ខទាំងអស់ដោយឥតប្រកែក តែពុំដឹងជាទុក្ខនោះ មានភាព រឺ បែបយ៉ាងណានៅឡើយ។

កល្យាណកើតមានមនោសញ្ចេតនាមួយថ្មីដែលមកសណ្ឋិតក្នុងខ្លួននាង គឺចង់ដឹង។ នាងឈានជើងមួយៗចូលក្នុងផ្ទះយ៉ាងមានះ ដោយធ្មេចភ្នែកកុំឲ្យឃើញពន្លឺដ៏មហិមានេះ។ មួយជំហានដែលនាងដើរ ធីតាហាក់ឃើញឧបសគ្គកាន់តែធំឡើង។ ខ្លួន ស្រីព្រលឹងហាក់ចេះតែថយក្រោយទៅវិញ។ មួយជំហានដែលនាងបានបោះកន្លងរួចមកហើយ គឺឧបសគ្គមួយដែលនាងឆ្លងរួច ស្រីហាក់បានធូរចិត្តបន្តិច។ ផ្ទះស្ងាត់ឈឹង ទេវីរឹតតែឆ្ងល់ទៅទៀត។ នាងដើរដល់មាត់ទ្វារ។ នាងដកដង្ហើមធំម្តង។ នាងអើតមុខចូលខាងក្នុងផ្ទះ។ ឱ ! រឿងអីដូច្នោះ ? នាងឃើញឪពុកនាង

ដួលដេកលើក្តារសន្លប់បាត់ស្មារតីឥតដឹងខ្លួន។ យុវតីខ្លោចចិត្តអាណិតឪពុក។ នាងយំយ៉ាងខ្លោចផ្សា ហើយរត់ទៅបីត្រកងលោកឪពុកជាអ្នកមានគុណ ផ្អែកក្បាលដាក់លើភ្លៅនាង។ បុត្រីអង្រួនដាស់បិតា តែគ្មានពាក្យអ្វីសួរ អ្វីឆ្លើយសោះ។ កញ្ញាភិតភ័យកាន់តែខ្លាំងឡើងៗ។ កល្យាណងើបមុខឡើងឃើញម៉ែភួង នាងទ្រហោយំថា៖

- ម៉ែភួង ជួយផង ! ជួយឪពុកខ្ញុំផង លោកកើតអី ?

នាងភួងទឹកភ្នែករហាមដៃរឱបជើងវិសេសក្លាហានយំដូចកូនក្មេង។

- ម៉ែភួងៗ ទៅរកទឹកមួយផ្តិលមក ឆាប់ៗ ម៉ែភួង។

លុះបានទឹកមក នាងទេវីលាបមុខលោកឪពុក លាបដៃជើង និង សព្វសព៌ាង្គកាយ។ គាប់ជួនពេលនោះ ព្រលឹងវិសេសក្លាហានក៏ចូលមកសណ្ឋិតកាន់រូបវិញធ្វើឲ្យមេទ័ពចាស់ងាកក្បាលចុះឡើងៗ។ នាងទេវីត្រេកអរក្រៃលែង ដូចបានឃើញឪពុកនាងមានកំនើតជាថ្មី។ ស្រីខំដាស់បោសអង្អែលទាំងទឹកភ្នែកថា៖

- លោកពុក លោកពុក នេះកូន ស្គាល់កូនទេ លោកពុក ពុកកើតអ្វី ?

ដំបូងវិសេសក្លាហានហាក់ភ្ញាក់ពីដេក។ លោកឮមាត់កូនលោកខ្សាវ រួចសូរមាត់បុត្រីនេះឮកាន់តែខ្លាំងឡើងៗ។ លោកបើកភ្នែកឃើញនាងទេវីឱបលោក ឃើញនាងភួងនៅទ្រចុងជើងលោក។ មួយស្របក់ក្រោយមក កម្លាំងក៏កាន់តែមានឡើងវិញបន្តិចម្តងៗ ទើបវិសេសក្លាហាន នឹកឃើញរឿងដែលនាំឲ្យលោកដេកដួលនៅទីនេះ។

សេចក្តីក្រោធខឹងមួយឆួលឆេះឡើងយ៉ាងពេញទំហឹង មករោលរាលរូបគាត់។ គាត់ក្រោកអង្គុយសម្លឹងមើលមុខនាងទេវីមិនដាក់ភ្នែក។ លោកប្រានកៃវដែលធ្លាប់ជាពន្លកចេញពីខ្លួនលោក កុំឲ្យស្រីអប្បលក្ខណ៍កាន់សាច់លោកទៀត។ នាងទេវីធ្ងល់ ធ្ងល់នឹងកាយវិការនេះ ទើបនាងនឹកភ្លែតឡើងថា លោកឪពុកនាងជ្រាបរឿងនេះហើយ។ នាងលុតជង្គង់ ដៃទាំងពីរខ្ទប់មុខយំឮយឹកៗ។ កញ្ញាពោលទាំងត្រដាបត្រដួសថា៖

- លោកឪពុក កូនសូមទោស ! ចាះ ! កូនសូមទោស លោកឪពុក ! កូនបានជាខុសចំពោះចិត្តលោកឪពុកហើយ។ ចាះ! កូនខុសពិតមែន។ កូនស្រលាញ់ ។ កូនបានលបចេញពីផ្ទះទៅជួបនឹងគេទាំងយប់ពាក់កន្តាលអធ្រាត្រ។ កូនខុសនឹងទំនៀមទំលាប់ ខុសនឹងអ្នកមានគុណមែនហើយ។ តែសូមលោកឪពុកជ្រាបថាកូនពុំទាន់បានខុសនឹងធម្មជាតិទេ។ កូនជាផ្នែកមួយរបស់ធម្មជាតិ កូនជាមនុស្ស។

ថាហើយនាងមើលមុខវិសេសក្លាហាន។ តែទឹកមុខបិតានៅក្រហមដដែល ភ្នែកនៅតែសម្លក់ក្រឡេតដដែល មានតែថ្គាមទាំងពីរ ដែលប្រខាំគ្នាថែមទៀត នារីអស់សង្ឃឹម។ ញើសលោតចេញពីថ្ងាសនាងផ្លោតៗ ហូរតាមខ្នងនាង។ ស្ងួនភ្ងាដឹងថា ឪពុកនាងពុំប្រណីទោសនាងទេ។ ហេតុនេះមានតែទឹកភ្នែកប៉ុណ្ណោះ ដែលនិយាយទៅទៀត។

វិសេសក្លាហានក្រោកឈរឡើង ដង្ហើមធំៗ ខ្លីៗ មុខដូចខ្លា។ នាងទេវីរឹតតែភ័យទៅទៀតឱបជើងលោកឪពុក។ នាងភួងអោជើងម្ខាង។ យូរបន្តិចមក វិសេសក្លាហានអោនទៅចាប់បុត្រីឲ្យក្រោកឈរឡើង នាងទេវីបានធូរក្នុងចិត្តឥតឧបមា នឹកថាឪពុកនាងយល់ព្រមអនុលោមកំហុសនាងហើយ។ វិសេសក្លាហានដឹកដៃឆោមស្ងួនទៅមាត់ទ្វារ។ កញ្ញាបែរជាធ្ងល់ឡើងវិញជាពន់ពេក ដោយមិនដឹងថា ឪពុកនាងចង់ធ្វើយ៉ាងណា ចង់និយាយយ៉ាងណា។ លុះដល់មាត់ទ្វារហើយ វិសេសក្លាហានច្រានស្មានាងទេវីយ៉ាងខ្លាំងទៅខាងក្រៅ ដោយពន្លឺពាក្យថា៖

- ទៅចុះ អញអស់មានកូនទៀតហើយ។

នាងក្លូងដែលឃើញរឿងចំលែកអស្ចារ្យដូច្នោះ ស្ទុះក្លែតទៅឱបជើងវិសេសក្លាហានសាជាថ្មី ហៀបនឹងនិយាយ តែវិសេសក្លាហានប្រានាងដួលទៅក្រោយដោយគំហកថា៖

- ទេ! អញគ្មានកូនទៀតទេ។

នៅខាងក្រៅ នាងទេវីឱបដៃស្រពោនដូចផ្កាត្រូវថ្ងៃ។ នាងអស់ចិត្ត អស់ពាក្យនឹងនិយាយ អស់គំនិតនឹងគិត។ ស្រីយំខះទឹកភ្នែកអស់ហើយ។ មួយរំពេចនេះ នាងឃើញជាក់ថាកែវអស់ផ្ទះនៅទៀតហើយ គឺមុខជាដេកក្រោមដើមឈើ ត្រូវខ្យល់ ត្រូវថ្ងៃ ត្រូវភ្លៀង អត់បាយហើយចាប់ពីរាត្រីនេះតទៅ។ ទេវីបែរមើលក្នុងទីងងឹត ដើម្បីរកផ្លូវដែលនាងត្រូវដើរទៅមុខក្នុងជីវិតនេះ តែមិនឃើញផ្លូវណាសោះ។កល្យាណបែរមើលរកទិសដែលនាងត្រូវយក តែមិនដឹងជាយកទិសណាសោះ។ នាងបែរមើលដំបូលផ្ទះ។ ឱ! ដំបូលនេះដាច់ចិត្តលែងទទួលនាងទៅហើយ។

មានន្ទមកដល់ ! ដៃប្រុសម្នាក់ចាប់នាងយ៉ាងខ្លាំងទាញចូលក្នុងផ្ទះវិញ។ ជីតាភ្ញាក់។ មានន្ទដើរយ៉ាងស្វាហាប់ចូលស្លុងទៅក្នុងផ្ទះ លុតជង្គង់ម្ខាងគ្រឹប ទៅលើក្តារពីមុខវិសេសក្លាហាន និយាយដោយវាចាមួយៗ យ៉ាងដាច់ខាត៖

- សូមទានលោកអ៊ំ រូបកូនប្រុសរបស់លោកអ៊ំ ទើបលេចចេញពីបន្ទូលចិត្តលោកអ៊ំ។ ខ្ញុំមានន្ទ ខ្ញុំសូមប្រគល់ខ្លួន ប្រគល់ជីវិតជាកូនប្រុសតែមួយរបស់លោកអ៊ំ។ សូមលោកអ៊ំជឿថា កូនប្រុសនេះមានចិត្តដូចលោក មានគំនិតដូចលោកអ៊ំ មានឧត្តមគតិចំពោះជាតិ និងចំពោះប្រជាជនដូចលោកអ៊ំគ្មានខុសប៉ុនមួយចម្រៀកសក់ទេ។ ខ្ញុំសូមលើកដៃសច្ចាចំពោះមុខលោកអ៊ំថា ចាប់តាំងពីយប់នេះទៅ ខ្ញុំធ្វើការពុះពារគ្រប់បែបយ៉ាង ប្រឆាំងនឹងអយុត្តិធម៌ ដែលជនជាតិខ្មែរយើងកំពុងរងទុក្ខវេទនា ប្រឆាំងនឹងគំនិតខ្ញុំគេដែលខ្មែរមាន ប្រឆាំងនឹងជនជាតិនានា ដែលគ្របសង្កត់ខ្មែរយើងជំនួសលោកអ៊ំដែលចាស់ណាស់ទៅហើយ។ ក្នុងការតស៊ូនេះ ខ្ញុំប្ដេជ្ញាជាឱឡារិកថា ចំពោះប្អូនទេវីខ្ញុំទទួលបីបាច់រក្សាអស់មួយជីវិត ទុកនាងជាគូវាសនាពីអតីតជាតិមក ហើយជាវត្ថុមួយដ៏ថ្លៃថ្លា ដែលខ្ញុំការពាររាល់ទិវា។

វិសេសក្លាហាន មើលមុខមានន្ទដោយពុំលែងចោលសោះ។ លោកញញឹមជាសញ្ញាទទួលយល់ព្រម។ លោកងក់ក្បាល រួចលូកដៃទៅចាប់ស្មាមានន្ទ មានវាចាថា៖

- ចាប់តាំងពីពេលនេះតទៅ ឯងជាកូនអញទាំងពីរ។

នាងទេវីសប្បាយចិត្តក្នុងគ្រានោះ នឹងរកវត្ថុអ្វីមកប្រៀបគ្មានឡើយ។ នាងហាក់ហើបខ្លួនពីដី ហាក់អណ្ដែតត្រសែតលើអាកាសជាមួយមានន្ទ និងជាមួយឪពុកនាង កញ្ញាស្ទុះទៅឱបជង្គង់លោកឪពុកជាទីស្នេហា។ នាងក្លូងក៏ធ្វើដូច្នោះដែរ។ វិសេសក្លាហានបន្តសេចក្ដីមួយៗ ដូចតទៅ ៖

- កាលណាបានឯងគិតរៀបការគ្នា ?
- បាទខ្ញុំបាទសូមរៀបការក្នុងបីខែទៀត។

វិសេសក្លាហានងើបទៅលើគិត។ រួចលោកគ្រវីក្បាល។

- ទេ ! មិនបានទេ
- បាទពីរខែទៀត
- ទេ!
- បាទមួយខែទៀត
- ទេ !
- បើដូច្នោះតាមចិត្តលោកអ៊ំកាលណា ? មួយអាទិត្យទៀត ?
- ទេ ! មិនបានទេ។ តោងសែនទាំងយប់នេះ។

មានន្ទឮដូច្នោះ ក៏ដាក់ភ្នែកចុះ។ អ្នកនៅសៀមគិតវាយក្រឡាស្ទង់ ញញឹមរួចទទួល :

- បាទ ! បាន !

ពិធីសែនព្រេនចាប់ធ្វើឡើងមួយរំពេចក្នុងវេលានោះ។ នាងភួងត្រូវទៅជាស់លោកមេឃុំ ជំទប់មកដោយឥតបង្អង់។ នាងទេវីត្រូវធ្វើម្ហូបអាហារមាន់ទាសំរាប់សែនក្លាម។ វិសេសក្លាហាន និងមានន្ទត្រូវកាច់ស្លាធម៌ រកទៀនធូបដោយរួសរាន់។ មិនយូរប៉ុន្មាន លោកមេឃុំ លោកជំទប់ក៏មកដល់ ភ្លើងទៀនធូបក៏ភ្លឺវន្ទាល កូនស្រី កូនប្រុសក៏ក្រាបទាំងគូទន្ទឹមគ្នា។លោកមេឃុំ លោកជំទប់បាចទឹកឲ្យពរសព្ទសាធុការដល់គូថ្មី ដែលផ្តិតមេដៃចុះសំបុត្រអាពាហ៍ពិពាហ៍ មិនឲ្យយូរដល់តិចតួចឡើយ។ ទើបវិសេសក្លាហានឲ្យពរជ័យដល់បុត្រាបុត្រី ឲ្យបានសុខគ្រប់ប្រការ។

- សូមកូននៅជាមួយគ្នាឲ្យបានសុខ។ ឪពុកគ្មានអ្វីចងដៃកូនទេ ឪពុកមានតែប្រទេសខ្មែរយើងទាំងមូលចងដៃកូន ។ ប្រទេសនេះមានទឹក ដី ព្រៃសព្វគ្រប់មុខ លោហធាតុគ្រប់មុខ។ កូនអាចនាំគ្នាកាប់គាស់ចិញ្ចឹម ដាំ ផ្កា ពុញារ ទាញផលឲ្យបានបរិបូណ៌តាមចិត្តកូន។ប៉ុន្តែដើម្បីឲ្យផលដែលកូនរកបានមក កូនតោងធ្វើខ្លួនកូនឲ្យទៅជាម្ចាស់ស្រុកពិតៗ កូន ! កូន !...

ក្នុងពេលប្រស់ទឹកឲ្យពរនេះ វិសេសក្លាហានដួលផ្ងារខ្លួនទៅក្រោយ។ លោកមេឃុំ លោកជំទប់ មានន្ទ នាងទេវី នាងភួងក៏ផ្អើលឆោឡោ ខ្លះកោសខ្យល់ ខ្លះចាប់ ខ្លះប្របាច់ ខ្លះហៅ ខ្លះផ្លុំត្រចៀក តែជីពចរវិសេសក្លាហាន ក៏ចេះតែវាយថយទៅៗ រហូតដល់ដាច់ខ្យល់សូន្យឈឹងតែម្តង។ វិសេសក្លាហានចូលកាន់មរណភាពក្នុងពេលនេះឯង។ លោកថយចេញពីពិភពលោកនេះដោយមានទឹកមុខញញឹម ព្រោះលោកបានទុកដាក់បុត្រីជាទីស្នេហារបស់លោកហើយ ញញឹមព្រោះលោកជឿថា វេលក្ខណ៍មានបង្អែកមួយដ៏មាំមួនហើយ ញញឹមដោយពេញចិត្តគ្មានអរិត្រង់ណា។

នាងទេវី និងមានន្ទប្តីប្រពន្ធថ្មី កើតទុក្ខនឹងមរណៈសញ្ញានេះយ៉ាងខ្លាំងជាងគេ។ នាងភួងឱបជើងខ្មោចយំអោក់អឿលរៀបរាប់ពីចិត្តវិសេសក្លាហាន ពីគុណសម្បត្តិវិសេសក្លាហាន។ នាងទេវីរៀបរាប់អំពីសេចក្តីសោកស្តាយដោយបិតានេះ ពុំទាន់បានឃើញនាងសុខ រឺទុក្ខយ៉ាងណាផងទៅថ្ងៃមុខ។ នាងរំជួលយោលយោគសោកយ៉ាងក្រៃអនេក។ មានន្ទមានទឹកមុខក្រៀមបំផុត។ ក្នុងពេលនោះ ជើងសេះឮសូរកុបៗផាយពីចំងាយមក។ មានន្ទប្រុងខ្លួនមើលទៅទិសដែលអស្សពាហ៍មក។ លុះមកដល់មុខខ្ទមកម្សត់ អ្នកជិះលោតចុះពីលើខ្នងអាជានេយ្យយ៉ាងរហ័ស។ បុរសមិនស្គាល់នេះមកគំនាប់មានន្ទយ៉ាងស្វាហាប់ រួចហុចសំបុត្រមួយដែលមានន្ទហែកមើលឃើញមានសេចក្តីដូចតទៅៈ

សិរីសោភ័ណ ថ្ងៃ ១០កើត ខែ ពិសាយ ព.ស ២៤០៨
ទីព្រះពន្លាជ័យព្រះកំពុត មកដល់មានន្នមេទ័ពអានាខេត្តសិរីសោភ័ណ
ចូលខ្លួនមកជាប្រញាប់ គ្មានបង្អង់បានឡើយ។ រឹងទទឹង មានទោសអាជ្ញាសឹក។
ព្រះកំពុត

លុះមើកូនសំបុត្រចប់ហើយ មានន្នដកដង្ហើមធំ។ ណាមួយខ្មោចឪពុកក្មេកនៅជ្រងោ ណាមួយអាណិតដល់នាងទេវី ណាមួយព្រួយបារម្ភប្រហែលឪពុកលោកដឹងរឿងមករៀបការហើយ បានជាហៅទៅបន្ទាយយ៉ាងប្រញាប់ដូច្នោះ។ អ្នកសសៀរទៅជិតនាងទេវីកំពុងតែយំ ខ្សឹបប្រាប់ថា :

- ឪពុកបងមានសំបុត្រហៅបងយ៉ាងប្រញាប់ មានសំបុត្រនេះ។

នាងទទួលសំបុត្រមកអាន។ នាងបែរមកកើតទុក្ខនឹងប្តីទៀតហើយ។ ឱ !ទុក្ខអើយទុក្ខ ! ! គិតទៅក្នុងវដ្តសង្សារនេះ ឃើញតែទុក្ខជួបតែទុក្ខ មានតែទុក្ខ។ ទុក្ខអ្វីក៏ទុក្ខម្ល៉េះ មកញាំញីនាងទេវីមួយគ្រាជាពីរគ្រា រួចមកបន្ថែមលើគ្នាគ្មានស្រាកស្រាន្តដូច្នោះ។ នាងសួរស្វាមីថា៖

- មានរឿងអ្វីបង ?
- ទេ មិនដឹងទេ តែអូនយកប្រាក់ពីរណែននេះទុកស្អែកទិញអីវ៉ាន់ និមន្តលោកធាន់ រូបបងមកជួយធ្វើក្តារមឈូសពីព្រឹកមិនខាន។
- ចា៎ះ ! បងមកកុំខានណា !

មានន្នឮបណ្តាំនេះព្រឺព្រួចគ្រលួចក្នុងចិត្តអាណិតភរិយា ? ព្រោះភរិយានេះផ្តាំតែប៉ុណ្ណោះឯង។ បងមកកុំខានណា ពាក្យនេះឮសូរធ្ងន់ក្នុងដួងចិត្តមេទ័ពក្មេងនេះ។ ពាក្យនេះពីរោះរកតូរ្យតន្ត្រីណាមកប្រៀបស្មើគ្មាន។ ពាក្យនេះឮក្តួងៗក្នុងបេះដូង...។ ពាក្យនេះថ្មីដរាបចង់តែឮ ចង់តែស្តាប់ ចង់តែឲ្យនាងថាម្តងទៀត។ មានន្នមើលមុខនាង នាងមើលមុខមានន្ន រួចបុរសក្រោកដើរយ៉ាងលឿនទៅខាងក្រៅ ដែលអ្នកយកសំបុត្រនៅរង់ចាំ។ រួចមានន្នប្រាប់អ្នកយកសំបុត្រថាឲ្យដើរទៅបន្ទាយវិញចុះ ។ ចំនែកអ្នកលោតលើខ្នងលេះបំផាយតម្រង់ទៅអាសនៈព្រះកំពុតជាបិតា៕

## រឿងមហាចោរនៅទល់ដែនវគ្គទី៤៖សពស្នេហា

### ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

រាត្រីកំសត់កន្លងទៅដោយលំបាក។ បរិយាកាសក្នុងផ្ទះវិសេសក្លាហានឃើញថា តឹងតែងហួសប្រមាណ។ បុគ្គលវិសេសក្លាហានដេកសន្ធឹងគ្មានកម្រើក សំពត់សគ្របពីលើនាងទេវី នាងភួង ស្ត្រីចាស់ខ្លះទៀតយំទ្រហឹងអឺងកង។ សកម្មភាពនៃមនុស្សក្នុងខ្ទមតូចនេះ ក៏មានខុសពីធម្មតា។ អ្នកជិតខាងមកកុះករជាច្រើន ខ្លះឈូសឈើ ខ្លះធ្វើក្តារមឈូស ខ្លះជួយធ្វើម្ហូបអាហារ ខ្លះជួយចាត់ចែងការផ្សេងៗ ខ្វែងដៃខ្វែងជើង។ គេជជែកគ្នាអ៊ូអរ សំដែងសេចក្តីអាណិតដល់អ្នកដែលស្លាប់ទៅ។ ព្រះសុរិយារះខ្ពស់បន្តិចទៅហើយ ព្រះសង្ឃប្រាំអង្គនិមន្តមក យូរបន្តិចមក គេញសូរធម៌លាយទៅក្នុងអាកាសអន្តែតទៅតាមខ្យល់ ប្រានព្រលឹងនាងទេវីកំព្រាឲ្យទៅខ្ពស់តែអែង ដល់ស្ថានមួយដ៏ចម្លែកដែលអ្នកផងទៅមិនដល់។ សូរធម៌នាំឲ្យចិត្តនាងរីកធំ ស្តឹកធ្ងួលប្លែក សូរធម៌ចូលទៅក្នុងក្រឳចិត្តនាង សូរធម៌នាំឲ្យកើតសង្វេគ ភ្លឹកភ្លាំងអស់ស្មារតី។ ធីតាចង់ឲ្យបិតានាងរស់ឡើងវិញ និយាយឡើងវិញ អង្គុយឡើងវិញ ដើរឡើងវិញ តែរូបកាយសពនៅធ្មឹងឥតធ្វើតាមចិត្តនាងចង់នេះសោះ។ កញ្ញានឹកដល់ទឹកមន្តដែលគេអាចប្រោសមនុស្សឲ្យរស់ជីវិតវិញបាន។ បើមានមែន កញ្ញានឹងយកមកធ្វើឲ្យឪពុកនាងរស់ដោយទឹកមន្តនោះ ឲ្យឃើញយ៉ាងជាក់ស្តែងឡើង។ បើបានដូចនោះមែន ម្ល៉េះពុំដឹងជាសប្បាយយ៉ាងណាទេ។ តែគ្មានសោះ។

កញ្ញានឹកដល់សង្ខារឪពុក ដែលចេញពីរូបទៅពុំដឹងជាទៅណាហើយទេ។ តាមពាក្យចាស់គេថា មនុស្សស្លាប់ ព្រលឹងមិនទាន់ដឹងខ្លួនទេ ព្រលឹងនេះនៅវិលវល់ជិតៗនោះ ពេលយប់ដេកលើចុងឈើ ពេលថ្ងៃដើរលើលោកយើងនេះ។ តែដល់ផុតមួយអាទិត្យទៅ ព្រលឹងនេះទៅសោយសុខនៅឋានសួគ៌ រឺ ទៅសោយទុក្ខនាឋាននារក រឺ ទៅកើតទៀតនៅភពឋានកណ្តាលយើងនេះ។ស្រីឆោមអាណិតឪពុកនាងយ៉ាងគ្រលួចក្នុងដួងចិត្ត។ នាងចោទសួរទៅទៀតថា រឺមួយមនុស្សស្លាប់ទៅសូន្យសោះតែម្តង។ បើពុំសូន្យទេគួរតែយកវត្ថុនេះ នោះមានអង្ករ ថ្នាំង ទ្រព្យសម្បត្តិ បុណ្យសក្តិទៅជាមួយផងបាន។ នេះគ្មានយកអ្វីទៅបានសោះ វត្ថុដែលប្លុងនៅជ្រងោនឹងមុខនាង។ ប្រសិនបើមានព្រំដែន ពីសេចក្តីរស់ទល់នឹងសេចក្តីស្លាប់ ហើយបើមានគេអាចលាគ្នាបាន ម្ល៉េះនាងសំពះលាឪពុកនាងរួចប្រុងប្រៀបរៀបចំបាយទឹក ស្បៀងអាហារ ចានក្បាន ខោអាវ ខ្នើយ មុងជូនលោកឪពុកនាងមិនខាន។ ឱ! ក្នុងពេលនេះហើយ ទើបនាងនឹករលឹកដល់ធម៌ព្រះពុទ្ធបរមគ្រូដែលអធិប្បាយហាក់ដូចលេងសោះថា ស្លាប់គឺធ្វើដំនើរចេញពីផ្ទះទៅដោយឥតប្រាប់អ្នកណា ដោយឥតយកអ្វី ដោយឥតគេមើលឃើញ ស្លាប់គឺបែកឋានគ្នាជាពីរស្រេលះ។ ស្រីស្រស់ភ្ញាក់ស្មារតីទៀតថា ព្រោះហេតុនេះហើយបានជាឪពុកនាងពុំស្រលាញ់ទ្រព្យ រឺ បុណ្យសក្តិ រឺ ប្រាក់កាសដូចគេ រួចបែរជាស្រលាញ់កេរ្តិ៍ឈ្មោះល្អវិញ។ ឱ ! មានតែកេរ្តិ៍ឈ្មោះល្អនេះទេ ដែលគង់វង្សនិត្យនៅជានិច្ចលើលោកនេះ។ វត្ថុនានាសឹងជាវត្ថុអនត្តាដែលវិនាសអន្តរាយទៅវិញទាំងអស់។ អ្នកព្យាយាមប្រមូលធន ឪពុកនាងប្រមូលកិត្តិនាម។ អ្នកផងឱបក្រសោបទ្រព្យធ្វើជាដើមទុន ឪពុកនាងទុកឈ្មោះដើមទុន។ កញ្ញាទេវីយល់ថា ឪពុកនាងមានចិត្តខ្ពស់ពិតមែនត្បិតលោកស្គាល់តម្លៃពិតរបស់ជីវិតមនុស្ស ហើយបានដើរផ្លូវត្រូវផង។ អាស្រ័យហេតុនេះ កំលាំងមួយហាក់មកសណ្ឋិតក្នុងខ្លួននាង ធ្វើឲ្យឆវីកម្សត់រីកកាយរួចជឿថា ឪពុកនាងមុខជាទៅកើតនៅឋានសួគ៌បានសប្បាយមិនខានពីព្រោះក្នុងលោកយើងនេះ ក្នុងសង្គមខ្មែរយើងនេះ ចំពោះជនជាតិខ្មែរយើង ឪពុកនាងបានបូជាពលិកម្មគ្រប់យ៉ាងស្រេចអស់ហើយ។

ទឹកភ្នែករីករាយពីរដំនក់ហូរធ្លាក់ពីភ្នែកនាង។ នៅវេលាថ្ងៃបែរបន្តិច ក្តារមឈូសរបស់លោកវិសេសក្លាហានដើរព័ទ្ធជុំវិញប៉ាឆាចំនួនបីជុំ ដូចតែក្តារមឈូសមនុស្សឯទៀត រួចឡើងយឺតៗ ទៅទំនៅលើគំនរឧស។ អគ្គីឆាបឆេះឡើងចោលអណ្តាតឆ្ពោកាន់តែខ្លាំងឡើង។ ភ្លើងឆេះឧសទេ តែដូចឆេះបន្ទូលចិត្តទេវី។ ធីតាគយគន់មើលសព្វគ្រប់ទាំងអស់ តាំងពីកម្ទេចភ្លើងដែលហុយឡើងទៅលើអាកាស ដោយពុំលែងភ្នែកចោលឡើយ។ យុវតីចង់ផុតយំហើយ នាងរង់ចាំស្វាមីសម្លាញ់របស់នាង តែពុំទាន់ឃើញមកសោះ។ភ្លើងឆេះកាន់តែខ្លាំងឡើង នាងទេវីឆ្អួលអាក់អួលកាន់តែខ្លាំងឡើងដែរ។ កល្យាណអាណិតឪពុកនាង ដែលឥលូវដូចគល់ឧសមួយដែរ។ ស្រីជូនលោកមកបានតែត្រឹមប៉ាឆានេះទេ។ ចាប់ពីពេលនេះទៅ នាងអស់បានឃើញមុខលោកទៀតហើយ។ ទឹកភ្នែកដែលខះក៏ស្ទុះបម្រាសបានពីរបីតំណក់ទៀតចេញមកក្រៅជាចុងក្រោយបង្អស់។ នារីហាក់ឃើញព្រលឹងឪពុកនាង ឡើងពីមឈូសទៅតាមផ្សែងភ្លើង។ រួចមានពួកមច្ចុរាជមាឌធំៗ មាំៗ មកនាំឪពុកនាងទៅ។ អគ្គីឆេះរូបវិសេសក្លាហានដែលមានសាច់របេះ ឆេះឮសូរគ្រួឲ្យព្រឺក្បាល។នាងទន្ទេញក្នុងចិត្តថា ឪពុកនាងកើតឡើងជាខ្មែរ បានធ្វើការជូនជាតិខ្មែរ បានរស់ក្រលំបាកដូចខ្មែរអែទៀត រួចបានស្លាប់ទៅវិញជាខ្មែរជាខ្មែរស្នេហាជាតិទៀតយ៉ាងពិតប្រាកដ។ អនុស្សាវរីយ៍និមួយៗ រឿងនីមួយៗ ដែលផុសឡើងក្នុងមនោគតិរបស់នាងទេវីសុទ្ធសឹងជាវត្ថុដ៏ថ្លៃថ្លូវដែលមកទង្គិច និងចំណុចខ្សោយនៃចិត្តរបស់នាង។ភ្លើងឆេះ នាងមើលភ្លើង នាងស្គាល់សូរសាច់ដែលផ្ទុះ នាងរកាំណាស់ តែអនុស្សាវរីយ៍នៃជីវិតឪពុកនាងចេះតែមានមកហូរហែបន្តៗគ្នា។ រឿងនីមួយៗ ដែលនាងនឹកឃើញសុទ្ធសឹងជារឿងដែលទាញទឹកចិត្តឲ្យទោរទន់ល្វីងចត់ប៉ុណ្ណោះ។ ឱ ! ជីវិតមនុស្សគិតទៅអស្ចារ្យមែន កើតមកមានប្រុសស្រី ក្មេង ចាស់ មានស្លាប់ មានកើត មានឈឺ មានជរា។ រីឯសន្តានចិត្តវិញក៏ប្លែកដែរ។ ចិត្តកូនចំពោះឪពុកម្តាយមានជំរៅមួយបែបទៅ។ ចិត្តប្តីចំពោះប្រពន្ធមានទម្ងន់មួយបែបទៅ។ចិត្តគូសង្សារស្រលាញ់គ្នាមានអាថ៌កំបាំងដែលជាក់ជានិច្ច។ ឯចិត្តទាំងអស់នេះប្រទាក់ប្រទងគ្នាយ៉ាងក្រៃអនេក។

នៅលើចំណងដែលជំពាក់គ្នាស្មុកស្មាញនេះមានទង់ពីរ គឺទង់ទុក្ខ និងទង់សុខ។ ទង់ទាំងពីរនេះរលុបរលាយនៅពេលតែមួយដូចៗគ្នាក្នុងគ្រប់រូបមនុស្ស រឺសត្វ គឺសេចក្តីស្លាប់។ អាស្រ័យហេតុនេះអ្នកប្រាជ្ញទាំងឡាយដែលចំណាន ខាងវិជ្ជាគ្រប់គ្រងមនុស្សតើលទ្ធិណា មានជំរៅជាងគេដែលអាចដោះស្រាយបញ្ហាជីវិតមនុស្សឲ្យបានស្គាល់តែសុខមួយមាត់?។ តាមយើងដឹង សព្វថ្ងៃមានលទ្ធិពីរដែលមានទ្រឹស្តីចោទបញ្ហានេះចំពីមុខគឺលទ្ធិមនុស្សដែល មនុស្សធ្វើ និង លទ្ធិព្រះដែលព្រះតែង។ លទ្ធិមនុស្សរកសុខឲ្យមនុស្សដោយប្រឹងប្រែងដោះស្រាយចំណោទសេដ្ឋកិច្ច ប្រើវិទ្យាសាស្ត្របង្កើតផលឲ្យបានបរិបូណ៌ រួចធ្វើវិភាគកម្មចែកផលនោះឲ្យមនុស្សគ្រប់ៗគ្នា មានស៊ី មានផ្ទះនៅ មានសម្លៀកបំពាក់មានថ្នាំពេទ្យ មានសំភារៈប្រើប្រាស់គ្រប់យ៉ាង។ លទ្ធិនេះនឹកស្មានថា ធ្វើបានប៉ុណ្ណោះ មនុស្សបានសុខផុតអស់ទុក្ខហើយ។ សួរថា តើអស់ត្រឹមប៉ុណ្ណោះ រឺអ្វី រឿងមនុស្សនោះ? ឱ ! ទេមិនទាន់អស់ទេ លទ្ធិព្រះគិតដូចខាងលើនេះដែរ តែដល់ពេលនោះ ព្រះបន្តទៀតថា មនុស្សរកសុខមួយទៀត គឺសុខគ្មានទុក្ខពិតៗ មែនៗសុខនេះគឺព្រះនិព្វាន។ ហេតុនេះ មានតែលទ្ធិព្រះទេ ទើបចប់ចុងចប់ដើម គឺឋានព្រះនិព្វានជាឋានគ្មានរូបគ្មានខន្ធ គ្មានតណ្ហា ជាស្ថានសន្តិភាពពិតៗ។ គឺឋានអស់កើត អស់ស្លាប់ អស់ទុក្ខ មានសុខតែមួយជាទីអវសាន។ ទស្សនៈដូចមានខាងលើនេះជាទស្សនៈដែលកើតក្នុងមនោគតិនាងទេវី ព្រោះសមុទ្រទុក្ខធ្វើឲ្យមនុស្សចេះគិត។

លុះល្ងាចជ្រេព្រះសុរិយា នាងទេវីរើសឆ្អឹងខ្មោចឪពុកជាទីស្នេហាមកទុកដាក់អែទីវត្តអារាមតាមសមគួរ។ នៅផ្ទះនាងក្លួងជួយលក់ដូរកេប្រាក់ចញ្ចឹមនាង។ ចំនែកមាននន្ទប្តីនាង បាត់សូន្យមិនឃើញសោះ៕

## រឿងមហាចោរនៅទល់ដែនវគ្គទី៥៖បណ្ដាំបង

### ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

មានន្ទបំផាយសេះយ៉ាងលឿនកន្ដាលទីងងឹតឆ្ពោះទៅកាន់គេហដ្ឋានព្រះកម្ពុត។ ទុក្ខដែលកើតអំពីមរណភាពវិសេសក្លាហាននៅញាំញីចិត្តអ្នកពុំចេះចប់ពុំចេះហើយ។ មរណភាពតែមួយនេះ ធ្វើឲ្យអ្នកអាណិតអាសូរដល់បិតាក្មេកដែលចាកស្ថានទៅផង ឲ្យអ្នកអាណិតដល់នាងទេវីជាភរិយាសំនប់ដែលរស់នៅនោះផង។

ទុក្ខទាំងពីរប្រភេទសឹងមានទម្ងន់ស្មើគ្នា។
អ្នកអាណិតវិសេសក្លាហានដោយបុគ្គលនេះស្លាប់ទៅមានទឹកមុខញញឹមស្រស់ប៉ប្រិម ដូចកក្រ្តព្រះពុទ្ធដែលចូលព្រះនិព្វាន។ អ្នកអាណិតនាងទេវីដោយស្រីធើតឆាយបានបង្ហូរទឹកភ្នែកសស្រាក់ ទឹកភ្នែកនេះហាក់នៅសើមៗក្នុងដួងវិញ្ញាណរបស់អ្នក។ សេះបោលសម្រុកទៅមុខយ៉ាងលឿន កាត់ព្រៃ និង វាល ដូចព្រួញព្រហ្មរបស់ព្រះនរាយណ៍។ គេឮសូរស្លឹកឈើ និង មែកឈើដែលបាក់ប្រាវៗ។ មិនយូរប៉ុន្មានមានន្ទមើលឃើញកំពែងអាសនបិតាខ្លួន។ អ្នកបោះពួយតម្រង់ទៅមាត់ទ្វារ។ អ្នកយាមធ្វើសញ្ញាគោរពយ៉ាងស្វាហាប់។ លុះអ្នកជិះសេះនេះទៅដល់បន្ទាយហើយ ក៏លោតចុះពីលើខ្នងសេះដោយរួសរាន់បន្ទាន់ចិត្ត។ សេនាម្នាក់ក៏ស្ទុះមកគោរពជាលើកទីពីរ។ មនន្ទស្គាល់ក្នុងទីងងឹតថាជាសេនារបស់ខ្លួន ក៏មានវាចាខ្សឹបៗថា៖

- បងកោប បងឯងមានដឹងរឿងអ្វីប្លែកក្នុងផ្ទះខ្ញុំទេ ?

គឺមនុស្សម្នាក់រូបតូច ខ្នងខុបបាក់ជាពីរ ។ មនុស្សនេះឆ្លើយដោយនឹងនួនវិញថា៖

- បាទទេ ! អត់មានរឿងអ្វីទេ ! តែមុននេះបន្តិចមានឃើញទាហានម្នាក់ជិះសេះមកដល់ទីនេះ រួចចូលទៅក្នុងបន្ទប់ឪពុករបស់លោកគ្រូ ។ ខ្ញុំឃើញសេះ និង អ្នកជិះនោះបែកញើសជាបខ្លួន។ ប្រហែលជាមានការអ្វីប្លែកមកពីក្រៅហើយមើលទៅ។
- ឪពុកខ្ញុំនៅទេ ?
- នៅហ្នឹង!
- ចុះបងកោប ឯងមានឮសូរមាត់គាត់និយាយអ្វីទេ ?
- ទេ ! អត់ទេ !
- តាំងពីល្ងាចមក គាត់សម្រាន្តហើយ រឺ នៅ?
- នៅ ! ម៉េចក៏លោកគ្រូសួរដូច្នោះ ?
- ការផ្ទាល់ខ្លួន !
- ការអ្វី ?

មានន្ទទះស្មាកោបមួយផ្ទង សើច ធ្វើដោយមេត្រីភាព៖

- ចាំថ្ងៃក្រោយខ្ញុំនិយាយប្រាប់។ ឥឡូវយកសេះខ្ញុំទៅទុកចុះ។ នាយកោបមិនអស់ចិត្ត ចាប់បង្ហៀរសេះបណ្ដើរសួរបណ្ដើរទៀតថា៖

- ការធំ រឺ ការតូច ? ការចិត្ត រឺ ការនគរ ? ការសប្បាយ រឺ ការច្បាំង ?
- ការចិត្ត តែឥឡូវនេះខ្ញុំប្រញាប់ណាស់ ប្រញាប់ទៅជួប នឹង ឪពុករបស់ខ្ញុំ។
- បានជាខ្ញុំចង់ដឹង ពីព្រោះខ្ញុំចេះតែញាក់ភ្នែកឆ្វេងព្រើតៗ...!
- ឆ្គួត !
- បើមានរឿងអ្វី សូមលោកគ្រូអាណិតប្រាប់ខ្ញុំឲ្យឆាប់ផងណា !..
- យល់ព្រម

មានន្ទក៏ស្ទុះឡើងកាំជន្ទើរទៅលើផ្ទះ។ នាយកោបក៏ដឹកសេះយកទៅទុក។ មានន្ទដើរយ៉ាងមាំមួនចូលទៅក្នុបន្ទប់ព្រះកម្មុត។ គឺជាបន្ទប់មួយធំ ជញ្ជាំងលាបពណ៌បៃតងខ្ចីស្រស់។ នៅជញ្ជាំងនីមួយៗមានព្យួរផ្ទាំងគំនូរចាស់ៗ គូរដោយដៃសិប្បករយ៉ាងចំណាននៃសម័យព្រេងនាយនោះ។ នៅលើក្តារ គឺកម្រាលល្អឆើតឆាយរំលេចដោយរូបភាពសត្វផ្សេងៗ និងរុក្ខាលតាវល្លិប្លែកៗដោយពណ៌ស លឿង ក្រហម បីដូចពណ៌ធម្មជាតិមែនៗ។ ក្រៅពីនេះចក្ខុយើងចាប់ក្លឹកស្ងប់ស្ងែងដល់តុ ទូ កៅវកង ដែលរៀបចំយ៉ាងប្រពៃ។ វត្ថុទាំងអស់សុទ្ធសឹងតែលាងជុសខាត់ស្អាតរលោងរលើបស្ទើរឆ្លុះមុខបាន។ គ្រឿងលំអទាំងពួងមានកែវកងជាដើមសឹងធ្វើអំពីប្រាក់ និង មាសយ៉ាងរុងរឿង។ នៅខាងមុខបន្ទប់ដ៏ស្កុកស្កម្មនេះ ព្រះកម្មុតកំពុងធ្វើការ អង្គុយសរសេរនៅលើតុធំមួយ។ គឺជាមនុស្សម្នាក់ប្រមាណ ៥០ឆ្នាំ ភ្នែកលៀនសក់ស្កូវល្បាយអាចម៍ខ្លា ថ្ងាសខ្ពស់។ នៅពីក្រោយខ្នងស្តេចសឹកនេះ គេសង្កេតឃើញអាវុធគ្រប់បែប គ្រប់យ៉ាងដែលព្យួរនៅជញ្ជាំង មានកាំបិតស្នៀត ដាវ ធ្នូ ព្រួញ ខែល ជាដើម។

មានន្ទដើរបោះជំហានវែងៗចូលទៅរកព្រះកម្មុតជាបិតា។ ព្រះកម្មុតឮសូរជើងមានន្ទស្គាល់ជាក់ថា ជាសូរជើងកូនរបស់ខ្លួន តែព្រះកម្មុតធ្វើពុំឮ គិតតែសរសេរសំបុត្រតូចមួយដោយផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់។ មានន្ទមកដល់ លុតជង្គង់វន្ទាពីមុខព្រះកម្មុតដោយគោរពមួយសន្ទុះក្រោយមក ព្រះកម្មុតដាក់ស្លាបប៉ាកកាចុះ ទឹកមុខមាំមួនហួតខៀមកញ្ចាត់ថ្នាំអុជជក់យ៉ាងព្រងើយ។ មានន្ទឃើញផ្សែងហុយទ្រលោមឡើងទៅលើ។ អ្នកប្រុងស្មារតីនឹកក្នុងចិត្តរកមើល តើគ្រោះថ្នាក់ដែលអ្នកទទួលនោះយ៉ាងណា? ព្រះកម្មុតសម្លក់កន្ទុយភ្នែកមើលទៅមានន្ទ ខាំធ្មេញរួចនៅស្ងៀម។ មានន្ទរិតតែឆ្ងល់អស្ចារ្យក្នុងចិត្ត អំពីអាកប្បកិរិយាដ៏ប្លែករបស់លោកឪពុកអ្នក។ អ្នកនឹកថ្ងៃថា ប្រហែលជាលោកដឹងរឿងរ៉ាវទាំងអស់របស់អ្នកជាមួយអាពាហ៍ពិពាហ៍នាកណ្តាលរាត្រីស្ងាត់នេះ។ តំនក់ញើសហូរពាសពេញខ្លួនអ្នក តែយុវជនប្តេជ្ញាក្នុងចិត្តថា បើឪពុកអ្នកជំទាស់នឹងរឿងនេះ អ្នកនឹងហ៊ានចេញមុខជំទាស់វិញយ៉ាងដាច់ខាត។ នាទីដ៏តឹងតែងនេះ ក៏ចេះតែហូរទៅ មានន្ទក៏រឹតតែថប់ដង្ហើមឡើងៗបុរសគិតរិះរកចំនុចផ្សេងៗ ដើម្បីបានដឹងឆាប់អំពីគោលបំនងនៃការកោះហៅខ្លួនអ្នកមកនេះ ។ នឹងយករឿងនាងទេវីមកនិយាយដោះសាជម្រាបលោកតែម្តងទៅជាការឆ្វេសប្រហែសមួយយ៉ាងធំ។ នឹងរង់ចាំឲ្យឪពុកអ្នកបង្ហើបរឿងមុនឪពុកអ្នកពុំធ្វើសោះ។ មិនតែប៉ុណ្ណោះអាកប្បកិរិយារបស់ព្រះកម្មុត បង្កើតបរិយាកាសកំហែងដល់មានន្ទយ៉ាងខ្លាំងក្រៃពេក។ មានន្ទលូកហោប៉ៅដើម្បីរកកូនកន្សែងមកជូតញើស ស្រាប់តែចុងម្រាមដៃអ្នកបះលើសំបុត្រដីកាកោះ។ រន្ទះនៃសេចក្តីរីករាយមួយមកដាស់ចិត្តឲ្យចាកផុតអំពីរណ្តៅចង្អៀតចង្អល់ ដែលអ្នកជួបប្រទះមកនេះ។ មានន្ទក៏ហុចសំបុត្រដីកានោះជូនព្រះកម្មុតដោយគោរព។

ព្រះកម្ពុតយកសំបុត្រនោះបោះទៅលើតុ រួចសួរដោយសង្កត់សម្លេងយ៉ាងធ្ងន់ៗថា

- ឯងទើបមកពីណា ?

មានន្ទបុកពោះភឹបៗ នឹកថា អីយ៉ា ! រករឿងទេតើ ! ក៏ប៉ុន្តែមុននឹងចេញសម្ដីតវ៉ា អ្នកនឹកឃើញថា ត្រូវតែឆ្លើយទៅតាមលំអានរឿង។

- លោកឪពុកមានការអ្វី ហៅខ្ញុំទាំងយប់ ?

ព្រះកម្ពុត សម្លក់មានន្ទចុងភ្នែកជាថ្មី។

- អញមិនមែនឪពុកឯងទេ ?

មានន្ទភ្ញាក់ដូចគេកន្ត្រាក់នឹងពាក្យនេះ ។ អ្នកបើកភ្នែកធំ បបូរមាត់ឡើងស្វាយ ជង្គង់ឡើងញ័រស្ទើរឈរពុំកើត។ បុរសនឹកថា ម្ដងនេះមុខជាដាច់អស់និស្ស័យហើយ។ អ្នកប្រឹងញញឹម រួចឆ្លើយដោយចំអកថា

- បើលោកឪពុកមិនជាឪពុកខ្ញុំ តើជាអ្វីទៅវិញ ?

ព្រះកម្ពុតក្រោកឡើងគំហកវិញថា

- អញហៅឯងមកសួរឯង មិនមែនហៅឯងមកសួរអញទេ។ តោងឆ្លើយតាមពាក្យអញសួរ។ អញសួរឯងថា តើឯងទៅណាបាត់តាំងពីល្ងាចម្លេះ ?

មានន្ទសើចៈ

- ការផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំពុំអាចប្រាប់លោកឪពុកបានទេ។ ខ្ញុំមកនេះ គឺមកឋានៈជាទាហាន ពីព្រោះដីកាកោះហៅតាមកិច្ចការទាហាន។ បើសិនជាមានការផ្ទាល់ខ្លួន ប្រាកដជាពុំមានដីកាដូច្នេះទេ។ បើដូច្នេះខ្ញុំអាចឆ្លើយជម្រាបលោកឪពុកបាន តែអំពីកិច្ចការខាងទាហានប៉ុណ្ណោះ ដោយសូមទោសលោកឪពុក ខ្ញុំមិនឆ្លើយពីការផ្ទាល់ខ្លួនជាដាច់ខាត។

ព្រះកម្ពុតពេបមាត់ តែងក់ក្បាល។ ឃើញដូច្នោះ មានន្ទបានធូរក្នុងចិត្តបន្តិច។ ព្រះកម្ពុតបឺតខ្សៀបង្កុយផ្សែង រួចដោយនិយាយបន្ទន់សម្លេងថាៈ

- ឯងបំពេញការផ្ទាល់ខ្លួនរបស់ឯងស្រេចហើយរឺនៅ ?

មានន្ទនឹកថា បញ្ហានាងទេវីនៅតែចោទដដែលក្នុងពេលដែលអ្នកស្មានថាបានធូរបន្តិចទៅហើយ។ បញ្ហានេះគ្រាន់តែផ្លាស់បែបចោទប៉ុណ្ណោះ ។ យុវជនឆ្លើយតបវិញថាៈ

- ការផ្ទាល់ខ្លួនពុំអាចមាននរណាបំពេញចប់នោះទេ ។ តែលោកឪពុកសូមជ្រាបថា ការផ្ទាល់ខ្លួនជាការតូចតាចដែលគេអាចទុកចោលមួយកន្លែងបាន។ ឯការដែលធំហើយសំខាន់នោះ គឺការនគរ។

ព្រះកម្ពុតដើរចុះដើរឡើងស្ដាប់មានន្ទអធិប្បាយ។ លុះអធិប្បាយចប់ លោកក៏ដើរទៅជិតតុ ទាញយកសំបុត្រមួយមកហុចឲ្យមានន្ទ ។ វីរបុរសគិតភ័យឡើងសាជាថ្មី ដោយពុំដឹងសេចក្ដីសំបុត្រនោះយ៉ាងណាសោះ។ អ្នកទទួលសំបុត្រ

រួចបត់ដាក់ទៅក្នុងហោប៉ៅយ៉ាងស្រួល។ ឃើញដូច្នោះ ព្រះកម្ពុតបែរមកមើលមុខមាននន្ទស្ទុះមកចាប់ស្មាបុត្រា រួចពោលវាចាឡើងញ័រៗថា៖

- កូនឯងអាចមើលសំបុត្រនេះឥឡូវ។

មាននន្ទហូតសំបុត្រមកពីហោប៉ៅវិញ សម្លឹងមើលមុខឪពុកដោយប្រឹងរិះរកមើលរឿងដែលឪពុកចង់ប្រាប់ខ្លួននោះ ត្បិតទាំងកាយវិការ ទាំងវាចាអ្នកលែងយល់អ្វីឡើយ។ មាននន្ទដាក់ភ្នែកចុះទៅលើសំបុត្រ រួចនិយាយយ៉ាងរហ័សថា

- លោកឪពុកឲ្យខ្ញុំទៅច្បាំងឥឡូវ ?

ព្រះកម្ពុតញញឹម៖

- មិនមែនឪពុកឲ្យកូនទៅទេ គឺនគរ។
- ខ្ញុំបាទសូមមួយអាទិត្យទៀតបានរឺទេ ?

ព្រះកម្ពុតបើកភ្នែកធំៗ តបវិញថា

- ឯងមកនេះគឺមកក្នុងឋានៈ ជាទាហាន ទាហានគ្មានប្រកែកទេ!
- ខ្ញុំសុំដល់ថ្ងៃស្អែក ពីព្រោះ ... !
- គ្មានពីព្រោះទេ ។ តោងឯងដឹងឲ្យច្បាស់ថា សព្វថ្ងៃឪពុកស្រលាញ់កូនលើសលុបរកអ្វីប្រៀបស្មើគ្មាន។ ឪពុកមិនចង់ឲ្យកូនលំបាកវេទនាសោះ។ ឪពុកចង់ឲ្យតែកូនបានសប្បាយរាល់ពេលវេលា។ កូនឯងទាំងរូបកាយ ទាំងចរិយា ទាំងចិត្តក្លាហាន បានធ្វើឲ្យឪពុកពេញចិត្តជាទីបំផុត ក៏ប៉ុន្តែនៅពេលនេះ ប្រទេសមានអាសន្នធំ។ ចំនួនមួយខែមកហើយ កងទ័ពភូមាវាយចូលលុកតាមអានាខេត្តឈៀងម៉ៃ ឆ្ពោះមកក្រុងអយុធ្យា (រាជធានី) កងទ័ពយើងបានចេញតស៊ូយ៉ាងម៉ឺងម៉ាត់ តែចាញ់ដៃខ្មាំងជានិច្ច។ ឥឡូវព្រះរាជាព្រះថៅយើងបានបញ្ជាមកឲ្យកងទ័ពយើងទៅជាប្រញាប់ ដើម្បីជួយក្រុងអយុធ្យាពីភយន្តរាយ។ សរុបសេចក្តីនគរត្រូវការឈាមយើងហើយ។ ក្នុងការរិះរកមេដឹកនាំកងទ័ពយើងទៅនេះ ឪពុកបានរិះរកមើលគុណសម្បត្តិរបស់មេទ័ពទាំងអស់ ឪពុកឃើញមានតែឯងមួយទេ ដែលអាចបំពេញការងារនេះបាន។ ហេតុនេះចូរកូនប្រមូលទ័ពទៅទាំងយប់នេះ។

មាននន្ទដាក់ទឹកមុខ រួចវន្ទាព្រះកម្ពុតថយខ្លួនចេញមក។ ព្រះកម្ពុតស្រែកហៅមាននន្ទថា៖

- មាននន្ទ ! មកនេះសិន ។ ហេតុម្តេចក៏ឯងមានទឹកមុខស្ងួតម្ល៉េះ ? ឯងមិនចង់ទៅទេឬអ្វី ? តោងប្រាប់មកឲ្យឆាប់។ អញទុកចិត្តលើឯង... ។
- ខ្ញុំមានប្រកែកអ្វី ។ ដូចលោកឪពុកជ្រាបស្រាប់ហើយ ខ្ញុំចូលចិត្តចម្បាំងណាស់។ ក៏ប៉ុន្តែក្នុងពេលនេះខ្ញុំព្រួយ ព្រួយព្រោះការដែលខ្ញុំបំរុងនឹងធ្វើនោះធំក្រៃពេក។
- បើដូច្នោះទៅចុះ ។ ទៅឲ្យសុខសប្បាយ។
- សូមលោកពុកនៅឲ្យបានសុខសប្បាយ។

មានន្ទដើរយ៉ាងលឿនចេញទៅក្រៅ។ ស្គរទ័ពក៏លាន់ឮរំពងឡើងក្នុងកណ្តាលរាត្រី។ សូរស្គរទូងៗហាក់វាយទៅលើទងបេះដូងរបស់បុរសយើង។ មិនយូរប៉ុន្មាន ពលរេហ៍មកដល់ណែនណាន់តាន់តាប់ ប្រដាប់ដោយគ្រឿងព្រួញស្នាលំពែងដូចៗគ្នា។ គេឮសូរមាត់មានន្ទដែលបញ្ជាឲ្យប្រមូលគ្នាជាជួរ គេឮសូរមាត់នាយកោបដែលតឿនកូនទាហានឲ្យប្រញាប់ គេឮសូរសេះដែលកញ្ជ្រោលស្រែកយ៉ាងក្តៅក្រហាយ។ សកម្មភាពនេះគួរឲ្យព្រឺក្បាលក្រៃពេកក្នុងក្តីងងឹត គឺសញ្ញានៃស្រុកមានអាសន្ន។ មានន្ទចាត់ការយ៉ាងជ្រះស្រលះល្អណាស់។ ពលរេហ៍ឈរតំរៀបត្រៀបត្រាជាជួរ ក្រាស់មីរដេរដាស ឃើញតែចុងខែល និងលំពែងចំរុះប្រោងប្រាង។ ខាងទ័ពសេះ ក៏ត្រៀមស្រេចតាមសណ្តាប់ធ្នាប់។ មានន្ទដើររាប់កងទាហានបែកញើសរហាម។ ក្នុងពេលនោះរដ្ឋបុរសក្រឡេកឃើញឱពុកអ្នកដែលឈរនៅមុខទ្វារ ទឹកមុខញញឹមពេញចិត្ត នឹងពីធីត្រៀមទ័ពរៀបចេញដំនើរនេះ។ នៅជិតបិតានេះ អ្នកឃើញកាមាប្អូនប្រុសអ្នក។

មាណពនឹកឃើញនាងទេវីស្រីពុំងា ពុំដឹងផ្តាំអ្នកណាទៅឲ្យនាងបានដឹងផងថា អ្នកខ្វាត់ព្រាត់ពីនាងទេវីទៅហើយ។ ប្តីជីតាបែររកមើលអ្នកឯទៀតដែលពុំទៅ ក្រែងជួបអ្នកណាដែលអ្នកផ្ញើពាក្យទៅដល់នាងផងពុំឃើញសោះ។ បុរសស្ទុះទៅខ្សឹបដាក់ត្រចៀកនាយកោបថា៖

- ឯងទៅហៅកាមាប្អូនអញឲ្យមកជួបនឹងអញមួយភ្លែត។
- បាទ

កាមាមកដល់។ មានន្ទចាប់ស្មាកាមាពោលពាក្យថា៖

- កាមា ប្អូនឯងជាប្អូនរបស់បងមែនរឺទេ ?

កាមាដំបូងនឹកឆ្ងល់ដោយពុំដឹងរឿងអ្វី រួចធ្វើទាំងប្រថុយវិញថា៖

- បាទ ខ្ញុំជាប្អូនបង្កើតរបស់បង។
- ឈាមដែលហូរក្នុងសរសៃប្អូន ដូចឈាមដែលហូរក្នុងសរសៃបងទេ?
- បាទដូចគ្នា។
- ប្អូនស្រលាញ់បងទេ ?
- មិនចាំបាច់សួរទេ ! ខ្ញុំសព្វថ្ងៃមានជីវិតមួយនឹងបង ?

មានន្ទសើចយ៉ាងរីករាយ រួចបន្តកិច្ចសន្ទនាទៅទៀតថា៖

- បងពេញចិត្តនឹងពាក្យឆ្លើយនេះណាស់ ។ ប៉ុន្តែ តើបងអាចប្រគល់របស់អ្វីមួយឲ្យប្អូនជួយបីបាច់រក្សាឲ្យបងផងបានទេ។
- មានអីបង របស់អ្វី ? ប្រាប់មក ! មិនអីទេ ខ្ញុំរក្សាទុកជូនបងមិនឲ្យខូចទេ។ បើខូចក្រែងតែជីវិតខ្ញុំស្លាប់។
- ក្នុងជាតិនេះ បងមានរបស់មួយយ៉ាងថ្លៃថ្លា ដែលបងស្រលាញ់ខ្លាំងណាស់ ស្រលាញ់នឹងចិត្ត ស្រលាញ់នឹងឈាម ស្រាលាញ់នឹងសាច់ ស្រលាញ់ស្មើជីវិត។
- វត្ថុនេះជាអ្វីបង នៅឯណា?

- ឥឡូវបងទៅច្បាំង។ បងពុំទាន់ទុកចិត្តអ្នកណាក្រៅពីប្អូនឯងទេ បងសូមផ្ញើវត្ថុនេះទុកនឹងប្អូនសិន ទម្រាំបងវិលត្រលប់មកពីច្បាំងវិញ បងនឹងយកវិញ។
- មិនអីទេបង ! ប្អូនរក្សាទុកជូនបងប្រាកដដូចមានព្រះអាទិត្យ ព្រះចន្ទដូច្នោះឯង។
- វត្ថុនោះគឺមនុស្ស។
- អី គឺមនុស្ស ?
- អឺ ! គឺពិតជាមនុស្ស ហើយមនុស្សស្រីថែមទៀត !
- យីមនុស្សស្រីនោះនៅឯណា ?
- នៅជិតៗនេះឯង ។ បងសូមប្រាប់រឿងប្អូនឲ្យអស់ទៅចុះ។ ពីរម៉ោងមុននេះ បងបានរៀបការហើយ!
- នែ ! ការនឹងអ្នកណា ?
- ការនឹងនាងទេវី កូនស្រីវិសេសក្លាហាន។
- យី ! អីបងការហើយ ?
- កុំឲ្យប្អូនឆ្ងល់ឲ្យសោះ នាងទេវី និង បង ស្រលាញ់គ្នាយូរណាស់មកហើយ ។ ឥឡូវបងសែនជាមួយនាងរួចជាស្រេច។
- តែអភ័ព្វណាស់ គ្រាន់តែសែនរួច ឪពុកនាងក៏ស្លាប់ទៅ ... ។
- អី វិសេសក្លាហានស្លាប់ហើយ ?
- ប្រាកដដូចមានព្រះអាទិត្យ ព្រះចន្ទដូច្នោះមែន។ នាងកំព្រាម្នាក់ឯង ហើយម្យ៉ាងទៀតនាងមានទម្ងន់ផង។
- អូ ! អីនាងមានទម្ងន់ផង ?
- ពីរខែហើយ ។ កាមាប្អូន។
- បាទ!
- ការដែលប្អូនត្រូវធ្វើ គឺៈ
    - ជួយទុកដាក់ឪពុកក្មេកបងឲ្យស្រួលបួល
- ជួយការពារនាងទេវី កុំឲ្យសត្រូវមើលងាយ
- ជួយផ្តល់ម្ហូបអាហារ អង្ករស្រូវ សំលៀកបំពាក់ លុយកាក់ដល់នាង។ តើប្អូនអាចទទួលបណ្តាំទាំងបីយ៉ាងនេះបានទេ ?
- បាទ ! បាទ មានធ្ងន់ស្រាលអីបង។ បណ្តាំបងងាយណាស់ មិនអីទេ ចូរបងកុំព្រួយឲ្យសោះ ប្អូនអាចជួយបងបាន។
- ប្អូនហ៊ានស្បថឲ្យបងទេ ?

កាមាថយបីជំហានក្រាក លើកដៃទៅលើ។

- ខ្ញុំសូមស្បថជូនបង បើខ្ញុំពុំធ្វើដូចបណ្តាំបងទេ សូមឲ្យអារក្ខទេវតា និង អាកាសទេវតាបំផ្លាញខ្ញុំឲ្យលោយដូចអំបិលត្រូវទឹក និងដូចក្រមួនត្រូវថ្ងៃ។

- កាមាទៅចុះ។ បងសូមលាប្អូនមួយពេលសិនហើយ។ បងទៅនេះគឺទៅដោយរីករាយបំផុត ព្រោះបងសង្ឃឹមថា បានប្អូនស្នងក្នុងកិច្ចរក្សាការពារនាងទេវីជាទីស្នេហារបស់បង។

ថាហើយមានន្ទស្ទុះទៅឱបកាមា រួចបងប្អូនទាំងពីរក៏បែកគ្នាទៅ។ មានន្ទឈរនៅមុខកងទ័ពបញ្ជាឲ្យពលទាហានប្រុង រួចកងទ័ពដើរទៅមុខយ៉ាងសម្បើមកក្រើកភពផែនដី។

## រឿងមហាចោរនៅទល់វគ្គទី៦៖ភ្លើងរាគៈ

### ដោយសព្វវចនាធិប្បាយសេរីគីគីឌា

ក្រោយពីរាត្រីកំសត់ដែលសម្បូរទៅដោយព្រឹត្តិការណ៍ចំលែកៗ ដែលបោះចំណុចធំៗ លើជីវិតនាង នាងទេវីយោគសោកាយ៉ាងខ្លាំងក្រៃអនេក។ ស្ត្រីអស់កម្លាំងពន់ប្រមាណ ដោយពុំបានចូលនិទ្រាក៏តិចតួចសោះ។ ឪពុកនាងស្លាប់ នាងបានប្រឹងប្រែងទុកដាក់ជាស្រេចបាច់អស់ហើយ។ តែទុក្ខមួយថ្មីទៀតដែលមានទម្ងន់ធ្ងន់ក្រៃណាមកគ្របជន្លប់នាងថែម គឺទុក្ខព្រាត់ស្វាមីជាទីស្នេហា។ មាណវីរង់ចាំស្ងួនភ្ងាតាំងពីយប់អស្ចារ្យនោះមក រួចនាងត្រូវរង់ចាំទៅមុខទៀត។ ចាំៗ ... ឱ ! ចាំដោយពុំដឹងមានរឿងអ្វី ចាំដោយពុំដឹងអ្នកទៅណា ចាំដោយពុំដឹងហេតុអ្វីបានជាបាត់ម្ល៉េះ ចាំមួយថ្ងៃជាពីរថ្ងៃ ចាំមួយខែជាពីរខែ... ចាំៗ ចាំរងកម្មរហូត។

ក្រោយមក ដោយពុំឈ្នះនឹងចាំ នាងបានឲ្យនាងក្លួងជាមាតាទៅស៊ើបសួរគេ ទើបនាងដឹងថា ប្ដីកល្យាណអ្នកមានដំនើរទៅឆ្ងាយណាស់ទៅហើយ។ នាងយំ យំជានិច្ច ត្បិតជីវិតនាងជាជីវិតសម្រាប់តែយំទៅហើយ។ ឱ! ប្រុសប្រសើរ ! អ្នកទៅ ទៅក៏ទៅចុះ តែទៅដោយគ្មានដំណឹង ទៅដោយធ្វើកន្តើយ ហាក់ដូចគ្មាននាងសោះក្នុងជីវិតរបស់ប្រុសតែមួយនេះ។ គេទៅ .. ឱ ! គេទៅ ពាក្យនេះអីក៏មានជម្រៅក្រៃម្លេះ? គេទៅបាត់ ... ឱ ! ពាក្យនេះធ្វើឲ្យព្រឺសព្វសាច់អីម្ល៉េះទេ បាត់ស្ងាត់សូន្យៗលើភពផែនដី សូន្យក្នុងភូមិ សូន្យពីចក្ខុនាង។ ពុំងានឹកស្ដាយ ស្ដាយត្រង់មុនទៅស្រីពុំដឹងខានមិនបានមើលមុខប្រុសឲ្យជាក់ច្បាស់ ដើម្បីចាំទុកឲ្យច្បាស់ក្នុងចិត្ត ... ស្ដាយត្រង់ពុំបាននិយាយគ្នា លាគ្នា ចាប់ដៃគ្នាជាចុងបង្ហើយ។

ជីវិតឥតគូ ជាជីវិតសាបសូន្យ ជីវិតធេងធោង គ្មានគោល គ្មានប៉ោលទេ គ្មានត្រើយ គ្មានទីដៅ គ្មានអុត្តមគតិ ជាជីវិតកំព្រា វង្វាសង្វេគ។ គឺក្នុងគ្រាព្រាត់នេះហើយ ដែលមនុស្សមានមនោគតិច្រើនៗ រហូតដល់ទៅគ្មានវង្វាស់វង្វាល់។ គឺក្នុងគ្រាព្រាត់គ្នានេះហើយដែលមនុស្សមានមនោសញ្ចេតនាគ្រប់បែប គ្រប់យ៉ាងឥតគណនាបានឡើយ។ ខ្យល់ដែលបក់ បក់មកប៉ះសាច់ គឺរលកនៃចិត្តស្នេហាដែលមកដាស់អារម្មណ៍ឲ្យនឹកឃើញអនុស្សាវរីយ៍ចាស់ ដែលធ្លាប់នៅជាមួយគ្នា។ ស្លឹកឈើដែលជ្រុះ ជ្រុះលើសន្ដានចិត្តគូកំសត់ ធ្វើឲ្យនាងនឹកស្ទើររលេះរលួយអស់ប្រមាត់បេះដូង។ ភ្លៀង ផ្គរ រន្ទះ ជាតុទាំងនេះញាំញីទឹកចិត្តឲ្យខ្វល់ខ្វាញ់ដែលទាញទឹកភ្នែកឲ្យហូររហាមជានិច្ច។ សត្វដែលយំ យំក្នុងទ្រូងរៀបរាប់ទុក្ខសុខរបស់គូសង្សារដែលព្រាត់ទៅម្នាក់ឯង។ អំពិលអំពែកដែលហើរៗ រាយមាយ ហើរពេញភ្នែកជនដែលស្រលាញ់ដែលនឹក។

នាងទេវីនឹកដល់ប្រុសខ្លាំងពេក ទៅជាស្រមៃឃើញអ្នកកាន់ទ័ពដើរកាត់ព្រៃលំបាកវេទនា ឥតដេកពួន ឥតបាយទឹក។ ស្រីស្រងេះស្រងោចគ្រវីក្បាលថា៖ *ឱ ! គេមានការធ្វើច្រើនណាស់ គេពុំមានពេលនឹកនាងដូចនាងនឹកគេទេ។ ការគេ បំភ្លេចគេ។ ចំនែកនាងវិញ នាងមានការដែរ គឺលក់ដូរអីវ៉ាន់ មានដូង ស្លា ម្លូ សាច់ត្រី ស្រូវ អង្ករជាដើម ដើម្បីចិញ្ចឹមជីវិតជាមួយនាងក្លួង តែក្នុងការនីមួយៗ ក្នុងវត្ថុនីមួយៗ មានទឹកចិត្តស្នេហាប្ដីលាយទៅជាមួយផង ដែលបណ្ដាលឲ្យនាងនឹកគេជានិច្ច។ គិតទៅចិត្តប្រុសឆាប់ដាច់ពីស្រីណាស់។

នឹកឃើញដូច្នោះ នាងយំម្នាក់ឯង។ ថ្ងៃមួយព្រះអាទិត្យរះជ្រះស្រឡះមេឃ នាងទេវីកំពុងរៀបចំផ្ទះ ស្រាប់តែនៅមាត់ទ្វារនាងភ្ញាក់ខ្លួនព្រើតមុខឡើងស្លាំងដោយឃើញកាមាជាប្អូន ដែលសើចរកនាងយ៉ាងក្អាកក្អាយដូចមុន។ ទេវីភ័យញ័រអស់សព្វសព៌ាង្គ។

- ម៉េចសុខសប្បាយជាទេ ?

ថាហើយ កាមាចូលជិតស្រីដែលថយក្រោយក្រាក។

- សុខនិងទុក្ខមានជាធម្មតា!

បុរសអង្គុយលើកៅអីយ៉ាងខែងញញឹមស្រស់។

- ខ្ញុំមកនេះមានការបន្តិច។
- ការអី ?
- ខ្ញុំសូមជម្រាបថា បងមានន្ទស្លាប់ហើយ !
- យី ! អីបងមានន្ទស្លាប់ ?

នារីយំខ្សឹកខ្សួល បន្តពាក្យទៅទៀតថា

- អីបងមានន្ទស្លាប់ ! ឱបង ! ប្អូនមុខជាស្លាប់ផងហើយ។

កាមាសើច នារីស្ទើរទន់ជង្គង់ អង្គុយចុះលើក្តារ។

- ទេ! អ្នកមិនត្រូវស្លាប់ទេ។ ដូចអ្នកជ្រាបស្រាប់ហើយ។ បងមានន្ទបានផ្តាំថា ឲ្យខ្ញុំជួយបីបាច់រក្សាអ្នក។ ក្នុងពេលនេះដំណឹងប្រាកដ គឺមានន្ទស្លាប់បាត់ទៅហើយ។ គាត់ស្លាប់ព្រោះគាត់ជាមនុស្សអាក្រក់ឃោរឃៅចិត្តឫស្យាណាស់ កាប់សម្លាប់មនុស្សរាប់រយពាន់នាក់ដុតផ្ទះសម្បែងគេ ដែលជាមនុស្សស្លូតត្រង់ បង្រាសពង្រាត់ប្រពន្ធកូនគេ លួចប្លន់គេឯងក្នុងព្រៃ។ ថ្ងៃនេះខ្ញុំសូមចិត្តអ្នក សូមនិយាយនឹងអ្នកឲ្យអស់ទៅចុះ គឺខ្ញុំសូមដណ្តឹងអ្នកជាភរិយាស្មោះស្ម័គ្រដើម្បីរក្សាអ្នកតរៀងទៅ។ តើអ្នកមានយោបល់យ៉ាងណា ?
- ទេៗ សូមទោសលោកចុះ ខ្ញុំជាស្រីមេម៉ាយហើយ។
- អ្នកៗ ស្តាប់ឲ្យបាន ! ខ្ញុំពុំបានធ្វើបាបអ្នកទេ គឺខ្ញុំបម្រុងយកអ្នកធ្វើជាប្រពន្ធពិតៗ របស់ខ្ញុំ ព្រោះថា កាលពីបងមានន្ទនៅរស់ ខ្ញុំក៏ពុំដែលមានពាក្យអ្វីដូច្នេះដែរ តែបើឥឡូវបងមានន្ទស្លាប់បាត់បង់ជីវិតទៅហើយ គប្បីពាក្យស្នើរបស់ខ្ញុំបានសំរេចផងដែរ។ អ្នកនៅទំនេរធ្វើអ្វី នាំឲ្យសត្រូវមើលងាយទេ។
- ខ្ញុំទម្ងន់ជិតគ្រប់ខែទៅហើយ។
- មិនអីទេ កូនបងមានន្ទក៏ដូចកូនខ្ញុំដែរ។ ខ្ញុំធានាបីបាច់រក្សាកូននេះឲ្យដូចកូនខ្ញុំបង្កើត។
- ខ្ញុំកំពុងមានទុក្ខព្រួយនឹងប្តីខ្ញុំខ្លាំងណាស់។
- កាលណាអ្នករៀបការនឹងខ្ញុំទៅ ទុក្ខនេះនឹងវិនាសទៅឯងហើយ។
- ខ្ញុំជាស្រីមេម៉ាយទៅហើយ។
- រឿងនេះខ្ញុំគ្មានប្រកាន់អ្វីទេ។ ខ្ញុំដឹងថាអ្នកមេម៉ាយហើយ!

- ម្ដេចលោកមិនគិតទៅរករៀបការនឹងគេឯទៀតទៅ ?
- ក្នុងជាតិនេះខ្ញុំបានសន្មតយ៉ាងដាច់ខាតក្នុងចិត្តថា ខ្ញុំស្រលាញ់តែអ្នកមួយទេ។ ហេតុនេះ ខ្ញុំសូមប្តូរជីវិតនឹងអ្នកតែមួយ។
- សូមលោកកុំស្រលាញ់ខ្ញុំ ខ្ញុំជាមនុស្សអភ័ព្វណាស់ . . . ។
- វាសនាមនុស្សមើលមិនឃើញទេ។ តែទោះអភ័ព្វយ៉ាងណាក៏ខ្ញុំសុខចិត្តលំបាកវេទនារងគ្រោះជាមួយដែរ។
- ខ្ញុំមិនចង់បានប្ដីទៀតទេ។ អាណិតខ្ញុំទៅ។

នារីសំពះកាមា ដូចគេសំពះព្រះពុទ្ធមួយអង្គ។ បុរសខ្លោចចិត្តអាណិតនាង តែភ្លើងរាគរឹតតែឆួលពេញដើមទ្រូងអ្នក។ អ្នកស្ទុះទៅចាប់ចុងដៃនាង។ ស្រីគ្រលៀសចេញយ៉ាងប្រញាប់។

- សូមលោកកុំពាល់ខ្ញុំ!
- អ្នកៗ អ្នកមិនឲ្យខ្ញុំពាល់ឯណាបាន បើខ្ញុំស្រលាញ់អ្នកដល់ម្ល៉េះ។

នារីក្រោកឡើងគេចទៅម្ខាងតុ។ កាមាដេញតាម។ នាងយំស្រែអង្វរថា៖

- លោកៗ អាណិត អាណិតខ្ញុំទៅ!

កាមាឈរគ្រញៀងខ្លួន ដាក់មុខជ្រប់ ខាំធ្មេញ ភ្នែកឡើងក្រហម និយាយម្នាក់ឯង៖

- ឯងស្រលាញ់អស់ប៉ុណ្ណឹងហើយ ។ ឱ ! ខ្ញុំមានតែទុក្ខទេជាតិនេះ ទុក្ខៗ ព្រោះស្រីតែមួយ។ ឯងបានអង្វរគេយ៉ាងគោរព គេមិនស្តាប់ខ្ញុំ។

ថាហើយ បុរសស្ទុះភ្លែតទៅចាប់នាង ចាប់ឱបរិតនាងយ៉ាងខ្លាំង។ នារីប្រឹងបំរះយ៉ាងណា ក៏មិនរួចពីកន្ទាប់ដៃយក្ខកំនាចនេះ។ ភ្នែកដែលនាងយំ អ្នកមើលឃើញរឹតតែល្អឡើង។

- អ្នក ! ខ្ញុំពិតជាស្រលាញ់អ្នកមែន!
- ទេៗ !
- ខ្ញុំសុខចិត្តអ្នក . . . !
- ទេ . . . ទេ . . . ទេ . . . !
- ខ្ញុំសូមរួមវាសនានឹងអ្នក ។
- ទេ . . . ទេ . . . កុំធ្វើដូច្នោះ !

កាមាខឹងយ៉ាងខ្លាំង ក៏ច្រាននាងមួយទំហឹងដៃទៅមុខ ដួលខ្ទាកលើក្តារ។ នាងទេវីភ្ញាក់ងើបឡើង កាមាស្ទុះទៅទៀតចាប់នាងប្របាច់យ៉ាងខ្លាំងនឹងម្រាមដៃ។

- ម្ដេចមិនស្រលាញ់អញទេវី ?
- ខ្ញុំសូមលោកអត់ទោសចុះ!

- យី ! មីនេះអញសម្លាប់ចោលឥឡូវ។
- លោកអើយអាណិតខ្ញុំទៅ!

ភ្នែកនាងហាក់ដូចធំៗក្រៃលែង ។ ដៃដែលចាប់នាងហាក់ដូចដៃដែកលាយភ្លើង ។ នារីទន់ខ្លួនបន្តិចម្ដងៗ រួចបាត់វិញ្ញាណទៅ។ កាមាទម្លាក់រូបនេះលើក្ដារប្រេស រួចក្រោកឡើងយកជើងរុញហើយដើរចេញទៅ។ គាប់ជួនពេលនោះនាងភួងមកពីផ្សារវិញ ឃើញនាងទេវីដេកដួលលើក្ដារ ក៏ស្ទុះទៅឱបបីនាងឡើង។

- យី ! លោកអើយធ្វើបាប ធ្វើកម្មអីកូនខ្ញុំ។

នាងភួងយំសស្រាក់។

- ហាងឯងស្គាល់អញទេ ?
- ឱ ! កូនសំលាញ់មាសម្ដាយ ម្ដាយស្លាប់ជាមួយកូនទៀត ។ ហើយ លោកអើយ! កូនខ្ញុំស្លាប់ហើយ។
- ឲ្យវាស្លាប់ទៅ ស្លាប់ឲ្យអស់ទៅបានវាសមមុខវា។
- លោកៗ អីក៏មានចិត្តអាក្រក់ម្ល៉េះ ?
- យី ! ថាអញអាក្រក់ ?

កាមាទាត់យាយភួងមួយជើងពីប។ នាងភួងផ្កាប់មុខ ។ ស្រីចាស់ប្រឹងស្ទុះ មកវិញចាប់នាងទេវីឱបជាប់នឹងដើមទ្រូង ។ កាមាដើរតន្ត្រំជើងទូងៗទៅបាត់ទៅ។ នាងភួងឱបនាងទេវីយំស្រែកហៅៈ

- កូនៗ កូនមាសម្ដាយ។

យូរបន្តិចក្រោយមក នាងទេវីបើកភ្នែកបន្តិចម្ដងៗ ។ ស្រីទាំងពីរយំទៅយំមកដាក់គ្នា។ ជីវិតនារីទាំងពីរស្ថិតនៅលើគំនរទុក្ខជាដរាប។ យូរៗ កាមាមកម្ដង និយាយពាក្យដដែលៗ ចែចង់ដែលៗ ធ្វើបាបដដែលៗ គ្មានឈប់ឈរ។ វេលាក្រោយមក កាមាបណ្ដេញទេវីឲ្យទៅទីណាឆ្ងាយផុតពីភូមិខ្លួន។ នាងទេវីក៏នាំនាងភួង ទៅនៅទីភូមិក្រោមចំងាយប្រមាណប្រាំគីឡូម៉ែត្រពីទីកន្លែងធ្លាប់នៅ។ កល្យាណរងទុក្ខវេទនាអនេកទាំងពីរប្រាណ។ រាត្រីមួយនាងទេវីឈឺពោះ ។ នាងភួងក៏ភ័យរត់ដាស់គេឯងមកជួយទាំងយប់ ។ យាយម៉បនៅក្នុងភូមិ មេត្តាករុណាមកជួយផងដែរ ។បុត្រីមួយក៏ប្រសូតឡើងក្នុងពេលនោះ ។ កូននោះមានរូបឆោមលោមពណ៌ល្អឯក ថ្ពាល់សទ្រលុកៗ គួរជាទីស្នេហាក្រៃពេក។ នាងទេវីមើលមុខបុត្រីនាងញញឹមដោយរីករាយ។ ប៉ុន្មានថ្ងៃក្រោយមក នាងទេវីបានចេញពីភ្លើង។ មានបងប្អូនជិតខាងជាច្រើន ខ្លះយកអង្ករមួយកញ្ឆេម្នាក់មកចងដៃកូនថ្មី ខ្លះយកសំពត់ថ្មីៗ មកជូន ខ្លះបានត្រីសាច់មកជូន រួចនាងទេវីក៏បានជូនអំណរអរគុណទៅគេវិញយ៉ាងអស់ពីដួងចិត្ត៕

# រឿងមហាចោរនៅទល់ដែនវគ្គទី៧៖បាត់កូន

## ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

នាងទេវី និង នាងក្លួងបានបីបាច់រក្សាកូនស្រីយ៉ាងហ្មត់ចត់ ។ នាងទាំងពីរបានដាក់ឈ្មោះកុមារីថា បទុម ។ រាល់ថ្ងៃ នាងទេវីឱបក្រសោបនាងបទុមជាប់នៅនឹងដើមទ្រូង។ ធីតាពុំឲ្យបុត្រីកំព្រានេះឃ្លាតមួយវ៉ាសបានឡើយ។ នាងតែងបំពេកែវជាបុត្រីឲ្យគេងលក់ស្កប់ស្កល់រាល់ថ្ងៃ ដោយបានបំបៅស្រីឲ្យបានឆ្អែតឆ្អល់ជានិច្ច។ នាងតែងបបោសអង្អែលកូន ក្រែងមានសត្វស្រមោចសង្កាខាំ។ នាងថើបស្រី ជាបុត្រភ្ងា។

ជីវិតនាង និង ជីវិតកុមារី រួមចូលគ្នាជាផ្លូងមួយដែលវេញគ្នាយ៉ាងត្របាញ់អស្ចារ្យ ។ បុត្រីនេះជាព្រលឹងរបស់ធីតា ។ ក្នុងរូបដ៏តូចច្រឡឹងនេះទេវីហាក់ឃើញជីវិតនាងបន្តសង្ខារទៅមុខទៀត។ បុត្រីនេះហើយ ជាថ្នាំទិព្វមួយដែលរំលាយទុក្ខ បំភ្លេចសេចក្ដីព្រួយរបស់នាង រួចធ្វើឲ្យរស់រៀងតទៅ។ កុមារីចេះញញឹមយ៉ាងស្រស់ប្រិមប្រិយហើយ។ កែវចេះឆ្លើយឆ្លងបន្តិចៗ នឹងនាងដែលជាហេតុរឹតតែឲ្យនាងស្រលាញ់ថែមទៀត។ ឱ ! សេចក្ដីស្នេហានៃមាតាចំពោះបុត្រគ្មានវត្ថុក្នុងនាលោកនេះអាចប្រៀបផ្ទៀបបានឡើយ។ តាំងពីបានបុត្រីកំសត់នេះមក នាងទេវីកើតទុក្ខតែនាងសប្បាយយ៉ាងអនេក ។ នាងកើតទុក្ខក្នុងសង្គម ព្រោះនាងព្រាត់ប្រាស់ឪពុក ព្រាត់ប្រាស់ប្ដីសម្លាញ់ ។ ម្យ៉ាងទៀត ព្រោះកាមាជាមនុស្សបានមកយាយីដល់រូបនាងរាល់ពេលវេលា រហូតដល់បណ្ដេញនាងឲ្យចេញពីភូមិឋានផ្ទះសំបែង។ នាងសប្បាយ សប្បាយព្រោះក្នុងសង្គមដដែលនេះ អរុណមួយថ្មីរះក្នុងជីវិតនាង គឺនាងបទុមតែមួយនេះ។

មែននាងសប្បាយមែន សប្បាយប្រហែលលើសអស់មាតាទាំងពួង។ ណាមួយកុមារីប្រកបដោយសុខភាពបរិបូណ៌ មានសំណើចស្រស់ចិញ្ចាច មានសាច់សស្អាត មានសម្ដីអាក់អេលបន្តិចផង គួរជាទីស្នេហាប្រាកដ។ បទុមបានមួយខែហើយ។ ថ្ងៃនេះនាងទេវីបំបៅបុត្រី ។ នាងដាក់កូនទៅក្នុងអង្រឹង រួចមាតាកម្សត់ដេកយោលកូនដែលលក់ស្កប់ស្កល់។ មិនយូរប៉ុន្មាន នារីជាមាតាក៏លង់លក់ទៅជាមួយកូនដែរ។ ស្រីយល់សប្ដិឃើញមានន្ទជាប្ដីនាងមកឱបក្រសោបនាង។ ធីតាយំដាយរព្ញកប្ដីខ្លាំងពេក។ ទេវីលង់លក់ក្នុងដំណេក។ លុះដល់នាងភ្ញាក់ដឹងខ្លួនឡើង ព្រះសុរិយាជ្រៀងជ្រេណាស់ទៅហើយ។ នាងទាញអង្រឹងយោលបទុមជាបុត្រី ។ តែ ! អ្វីក៏ដូច្នោះ ? អង្រឹងទ្រង់ស្រាលស្ញើក។ ធរីក្រោកឡើងដូចគេកន្ត្រាក់។ បាត់បុត្រីទៅណាហើយកែវកូនអើយ។ កែវល្អស្ទុះចេញទៅក្រៅស្រែកហៅមីងក្លួង តែខាងក្រៅស្ងាត់ឈឹង ។ យាយក្លួងទៅផ្សារពុំទាន់មកផង។ នាងនឹកថា ប្រហែលយាយក្លួងមកលើកកូនយកទៅមុជទឹកងស្ទឹងហើយ ។ ស្រីរត់ទៅរកស្ទឹង តែគ្មានឃើញអ្វីសោះ។ នាងសួរអ្នកឯទៀតដែលនាងជួបប្រទះថា «ឃើញអ្នកណាមកយកកូនខ្ញុំទេ ?» គេឆ្លើយថា «ទេ ! . . . យ៉ាងណាដូច្នោះ ?»។ ទេវីកំសត់ពន្យល់ប្រាប់គេវិញពុំទាន់ចប់ផង នាងរត់ទៅសួរអ្នកជិតខាងទៀត។ នារីឆ្វេឆ្វា បីដូចមេមាន់រកពង។ មុខនាងឡើងស្លាំងត្បិតអ្នកទាំងពួងឆ្លើយមកនាងវិញតែពាក្យដដែល។ មិនយូរប៉ុន្មានមនុស្សក្នុងភូមិជួយចោឡោរកបុត្រីរបស់នាងទេវី ។ នាងក្លួងមកដល់ទៀត ក៏ជួយរកទៀត។ ទឹកភ្នែកហូរសស្រាក់ នាងទេវីស្រែកទ្រហោយំថា៖

- ឱ ! ម្ចាស់ថ្ងៃអើយ លោកអ្នកណាយកកូនខ្ញុំទៅ ? ខ្ញុំលង់ដំណេកភ្ញាក់ឡើងស្រាប់តែបាត់កូន។ ឱ! អ្នកណានោះអីក៏ចិត្តអាក្រក់ម៉្លេះ ? លួចអីមិនលួច ៗកូនខ្ញុំ។ កូនទើបបានមួយខែ ថ្ងៃនេះផង។ ឱ ! តើនាងបានអីបៅ តើគេយកថ្លៃទៅសម្លាប់ចោលរឺអ្វី ? ។ កូន ៗ ! ទើបបានឃើញពន្លឺព្រះអាទិត្យមិនបានប៉ុន្មានថ្ងៃ

ផង ស្រាប់តែវិនាសទៅវិញ។ នាងពុំទាន់ចេះនិយាយ ចេះគិតគូរផង ស្រាប់តែបាត់ទៅ។ ឱ ! លោកអ្នកអើយជួយកូនខ្ញុំផង ខ្ញុំស្លាប់ក្នុងពេលនេះជាប្រាកដហើយ ។ ពូមឹងអើយ ! ជួយយោងជីវិតខ្ញុំផង។ ខ្ញុំគ្មានទ្រព្យធនអ្វីទេ។ ខ្ញុំមានតែកូនមួយនេះ។

នាងទេវីដើរបណ្ដើរ យំបណ្ដើរ ពីផ្ទះមួយទៅផ្ទះមួយ រៀបរាប់សព្វគ្រប់ ។ អ្នកផងដែលស្ដាប់ក៏ជួយយំផងគ្រប់ៗគ្នា។ រាត្រីក៏ដណ្ដប់ពិភពលោកធ្វើឲ្យងងឹតស្លុង ។ នាងទេវីរឹងរឹតតែខ្លោចផ្សាទៅទៀត ។ នាងដើរពេញភូមិសួរគេ។ ដោយពុំឃើញ នាងដើរទៅដល់ព្រៃក្រោយផ្ទះ ត្រចៀកប្រុងស្ដាប់ក្រែងឮសូរមាត់កូនយំ ។ ស្រីអុជចន្លុះដើរឆ្វេលក្រោមគុម្ពផ្កា តាមគៀនរបង តាមរូងរន្ធផ្សេងៗ ក្រែងអ្នកណាយកកូននាងទៅលាក់នៅទីនោះ។ ជីតាយកឈើមួយកំណាត់ដើរវែកព្រៃល្បោះទាំងពួង ដើម្បីឲ្យកូននាងភ្ញាក់ឡើង យំឡើង ឲ្យនាងឮសូរសម្លេង នឹងអាលនាងបានរត់ទៅលើកឱបកូននោះមកវិញ។ កល្យាណបានយកចែវច្រវាទៅកូរក្នុងជងស្ទឹងក្រែងអ្នកណា យកកូននាងទៅចោលក្នុងទឹក។ នាងលួចសំលឹងដីណាថ្មីៗ ក្រែងគេកប់កូននាង។ លុះដល់កូនដំបូកណាមួយ ជីតាឡើងលើដំបូកនោះក្រែងបានឮសូរ រឺបានឃើញកូននាង។ កន្លែងត្រង់ណាខ្មៅស្រទំគួរសង្ស័យ នាងរុកចូលទៅខំកកាយ ញែកវែករកបទុមកូនសម្លាញ់។

រាត្រីកន្លងទៅ បុត្រីនាងនៅតែបាត់ដដែល។ ថ្ងៃមួយមកជំនួសរាត្រីសង្វេគនេះទៀត ស្រីនៅតែដើររកកូននាង ទឹកភ្នែកដែលហូរ ឈប់ហូរអស់រលីងនៅតែទឹកចិត្តទេដែលហូរតទៅទៀត។ ថ្ងៃមួយទៀតកន្លងមក ពីរថ្ងៃទៀតកន្លងមកគ្មានលេចឮដំណឹងអ្វីមួយពីបុត្រសង្សារនាងសោះ ឱ ! ស្ងាត់អ្វីក៏ស្ងាត់ម្ល៉េះ ។ នាងទេវីអស់សង្ឃឹម។ នាងពុំដេកពួនសោះ។ ដោយអស់កំលាំងខ្លាំងពេក មាតាទុក៌តចូលទម្រេតខ្លួនលើគ្រែប្របនាងក្បួងដែលអស់កំលាំងដូចគ្នា។ កាលនាងនឹកដល់បុត្រី នាងឃើញមុខស្រីកល្យាណនៅតែនឹងភ្នែក មុខមូលក្រលង់ញញឹមស្រស់ ។ ស្រីមើលទៅឆ្វេងស្រមៃឃើញកូនកម្សត់មើលទៅខាងស្ដាំឃើញរូបកូន មើលលើតុហាក់ឃើញកូន មើលគ្រប់ទិសឃើញកូនដរាប។ រូបកូនបែងចែកគ្រប់ទិសានុទិស។ ជីតាឈោងដៃចាប់ កូនថយទៅ។ នាងដើរតាម កូនថយទៅទៀត។ នាងថយមកវិញ កូនដើរតាមមក ។ ស្រីអង្គុយសំពះឲ្យកូន នៅស្ងៀមមួយកន្លែង រួចសើចគ្រហាញមករកនាងវិញ។ ឱ ! រកាំក្នុងចិត្តអ្វីម្ល៉េះទេ ជីតារមួលអស់ទាំងខ្លួន។ ទេវីជិតតែនឹងទៅជាឆ្កួតទៅហើយ។ កែវរលក្ខណ៍ដើរមួយៗ ទៅយកកាំបិតស្នៀតមកកាន់ថើបអាវុធពីក្រៅស្រោម ឱបអាវុធជាប់នឹងទ្រូង សើចដាក់អាវុធ រួចនាងយំដាក់អាវុធ រួចទឹកភ្នែកស្រក់តក់ៗ។ មួយៗ នាងហូតកាំបិតចេញពីស្រោម ។ នាងយកមេដៃស្ទាបមុខកាំបិត ។ នាងមើលចុងកាំបិត។ ឱ ! កាំបិទមុត ៗ មែនចុងស្រួច។ ស្រីកម្សត់និយាយតិចៗថា៖

- ថ្ងៃនេះ ខ្ញុំផុតអស់ទុក្ខហើយ ។ កាំបិតនេះហើយជាមិត្ត ជាទីអវសានរបស់ខ្ញុំ។ កាំបិតនេះជាថ្នាំដែលស្រាយចំណងខ្ញុំឲ្យមានសេរីភាពពិតៗ ក្នុងវដ្តសង្សារ ។ ជីវិតមនុស្សហាក់វេទនាណាស់ មានតែទុក្ខ គ្មានសុខមែន ! !

ជីតានឹកទៀតថា តើរស់នៅធ្វើអ្វី បើចិត្ត បើថ្លើមស្លាប់អស់ទៅហើយ។ ទេវីថើបចុងកាំបិទហាក់ដូចស្រលាញ់ណាស់។ នាងយកដៃបេះឡេវអាវ រួចមើលទៅចុងដង្ហើមខ្លួន។ នាងយកចង្អុលដៃចុច ១ចុងដង្ហើមនាងនេះ ដើម្បីរកមើលកន្លែងដែលចុងកាំបិតត្រូវលូកចូលទៅ។ កញ្ញាលុតជង្គង់សំពះដល់ទេវតា សុំកុំឲ្យយកទោសនាង ១នឹងសម្លាប់ខ្លួន

ក្នុងពេលនេះហើយ ។ ចុងកាំបិតក៏ចុចលើចុងដង្ហើមគ្មានបង្អង់។ ស្រីប្រាថ្នាថា កើតជាតិនានា កុំឲ្យមានទុក្ខដូចជាតិនេះទៀត។ កាំបិតស្ទៀតរុញទៅមុខ ស្រាប់តែអ្នកស្រុកម្នាក់ស្ទុះចូលមកពីក្រោយនាង ស្រែកយ៉ាងរីករាយថា៖

- ខ្ញុំទើបបានដំណឹងមួយថា លោកមេទ័ពមានន្ទពុំទាន់ស្លាប់ទេ នាងទេវីលួចលាក់កាំបិទដ៏មុតថ្លានោះ សៀតនៅចង្កេះបង្កប់ក្នុងអាវដែលនាងបិទឡេវវិញយ៉ាងស្រួលបួល។ កែវបែរយ៉ាងស្លួតមករកពូនោះ៖
- ពូដឹងពីណាមក ?
- យី ! អាសូរវាមកដល់ហើយ។

នាងហាក់បានកើតម្តងទៀត ។ នាងសើចទាំងទឹកភ្នែក។

- កាលណាបានបងមកដល់ ?
- អាសូរវាថា បីថ្ងៃទៀត។
- ម្តេចបងមិនមកថ្ងៃនេះ ?
- ថាចាំរៀបទ័ពហែក្បួនឲ្យបានសង្ហាបន្តិច។
- ខ្ញុំត្រេកអរណាស់ពូ ! ឱ ! ពូអើយខ្ញុំផុតអស់ទុក្ខហើយ ប្អូនសូម . . . ឱ ! ពូអញ្ជើញទៅវិញហើយ ?
- បាទ ! ហេតុតែសំណាងនាង។
- ចា៎ះ ! អរគុណពូណាស់ អញ្ជើញចុះ។

នាងទេវី រីករាយយ៉ាងក្រៃលែងនឹងដំណឹងនេះ។ នាងរត់ទៅប្រាប់នាងភួង ដែលអរ កខិបកខុប ។ នាងទៅមុជទឹកលុបលាងកាយ ដុសសាប៊ូ លាបល្មៀតយ៉ាងស្អាត។ បើជនណាដែលពុំស្គាល់នាង មុខជាចាត់ថានាងនៅក្រមុំមិនខាន។ ចំនួនយូរខែមកហើយ នាងពុំដែលតុបតែងខ្លួនសោះ។ ទើបតែថ្ងៃនេះនាងហៅយាយភួងសិតសក់នាង ឲ្យជួយលាបម្សៅនាង។ ឆវីញញឹមដោយឃើញថា នាងនៅតែល្អស្រស់ដដែល។ សំណើចនាងធ្វើឲ្យឃើញធ្មេញសស្គុស។ ធីតាពាក់អាវល្អ សំពត់ល្អ។ នាងបេះផ្កាមកចងជាបូដាក់លើសក់ នាងប្រុងខ្លួនចាំទទួលប្តី ប្តីដែលនាងនឹកជាយូរមកហើយ ប្តីដែលជាគូកម្សត់ព្រាត់យូរថ្ងៃខែមកហើយ ប្តីដែលស្រលាញ់នាងវិញយ៉ាងពេញចិត្ត។

មាណវីនឹកថា ត្រូវនាងតុបតែងខ្លួន កុំឲ្យជុំឆ្អេះឆ្អាបទៅលើប្តីដែលព្រួកនាងដែរ។ ឱ ! បីថ្ងៃទៀត មុខជានាងបាននិត្យនៅជាប់នឹងដើមទ្រូងប្រុសសម្លាញ់នេះហើយ គឺនឹងបាននិយាយរៀបរាប់ប្រាប់ទុក្ខនាង ប្រាប់ការកំព្រាដែលនាងបានឆ្លងរួចមក ប្រាប់អំពីកំនើតបុត្រី ប្រាប់អំពីបុត្រី។ មកដល់ត្រង់នេះ នាងទេវីហូរទឹកភ្នែករហាមវិញ។ សេចក្តីសប្បាយទាំងប៉ុន្មានរត់ចេញអស់ពីចិត្តនាង។ សេចក្តីរីករាយរបស់នាងហាក់របេះមួយម្តងៗ ធ្លាក់ទៅក្នុងរណ្តៅជ្រៅមួយ។ ស្រីនឹកថា បើបុត្រីជាទីស្នេហានៅម្ល៉េះ សមនឹងបានពបុត្រីនេះទៅបង្ហាញប្តី ឲ្យប្តីថើបបុត្រនេះផង។ តែឥឡូវដៃនាងទទេ ។ នាងហាក់ស្រាលខ្លួនស្ទើក។ ក្នុងពេញមួយថ្ងៃនេះ ធីតាប្រឹងរៀបចំផ្ទះសម្បែង បោសសំអាត ដុសលាងវត្ថុនានា ខាត់តុបតែងយ៉ាងឱឡារិក រួចចាត់ការទិញម្ហូបអាហារធ្វើនំ ទុកចាំប្តីមានទិញចានល្អៗ ទុកសម្រាប់ដាក់ឲ្យស្វាមីបរិភោគអាហារ និងទិញកន្ទេលថ្មីៗ ឲ្យអ្នកប្រុសសំរាន្ត។ ឱ !នាងចេះតែនឹកឃើញចំណុចឯទៀតៗ ជាច្រើនណាស់តែនាងពុំអាចធ្វើតាមចិត្តដែលនាងនឹកឃើញទាំងអស់នោះឡើយ ពីព្រោះស្រីក្រណាស់។ គំនិតនិមួ

យៗ ដែលផុះលេចឡើងក្នុងវិញ្ញាណរបស់នាងក្នុងមួយពេលនេះគឺផុះលេចមកឯងៗ រួចគំនិតនីមួយៗ ជាសន្តាន
ចិត្តនាងដែលស្មោះចំពោះលើស្វាមី៕

# រឿងមហាចោរនៅទល់ដែនវគ្គទី៨៖ត្រលប់ពីច្បាំង

## ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

ព្រះអរុណថ្ងៃនេះរះឡើងយ៉ាងត្រចះត្រចង់។ ប្រជាជនគ្រប់រូបភ្ញាក់ពីព្រលឹមខុសពីធម្មតា ។ ម្នាក់ៗ សំរេចចិត្តចាំមើលក្បួនទ័ពមានមានន្ទដែលវិលត្រលប់ពីច្បាំង។ យើងរាល់គ្នាស្លៀកល្អ ពាក់ល្អ ឈរកុះករនៅនឹងផ្សារ។ មិនយូរប៉ុន្មានក្បួនទ័ពមកដល់។

ដំបូងគេឮស្គរជ័យយ៉ាងអ៊ឹកធឹក ។ បន្តិចក្រោយមកអង្គទ័ពមកដល់។ ទាហានដើរជាជួរសម្បើមដោយអាវុធដែលកាន់គ្រប់ៗដៃ គឺមានខែល លំពែង ស្នា ព្រួញ ដាវជាដើម។ ពលរេហ៍ដើរកក្រើកផែនដី។ បន្ទាប់មកគឺទ័ពសេះដែលសង្ហាជាងគេ ។ ម្នាក់ៗ អង្គុយលើខ្នងអាជានេយ្យ ត្រង់ខ្លួនគ្មានងាកទៅណាឡើយ ។ ដាវដែលព្យួរនៅចង្កេះឃើញគួរស្ញើប។ ក្រោយមកទៀត មានទ័ពខាងដំរីដែលតុបតែងដោយគ្រឿងអលង្ការនៅភ្លុក នៅលើក្បាល និងទៅលើខ្នងមើលឃើញរុងរឿងបីដូចក្នុងរឿងមួយពាន់មួយយប់ ។ នៅលើខ្នងដំរីនេះ អ្នកឈរមើលពលរេហ៍ គឺមានន្ទមេទ័ព។

មានន្ទឈរផ្ទើង ដាវដែលហូតហើយ ដែលកាន់នៅដៃនោះមានរស្មីចាំងនឹងព្រះអាទិត្យភ្លឺព្រាតៗ ។ ដោយគ្រឿងសម្លៀកបំពាក់ ដោយមាឌមាំ វីរបុរសហាក់មានអំណាចឥតឧបមា។ មានន្ទនាំទ័ពដែលមានចំនួនប្រមាណប្រាំពាន់នាក់ ។ រួចគេឮសូរសម្រែកយ៉ាងខ្លាំង បញ្ជាឲ្យពលរេហ៍ឈប់។ តាមរបងប្រជាជន ក្មេង ចាស់ ប្រុស ស្រី ដែលឈរមើលក៏បន្លឺនូវសម្រែកថា ជយោលាន់ឮរំពងឡើង។ ឱ! តាំងពីកាលណាមក ពុំដែលមានព្រឹត្តិការណ៍ដ៏រីករាយដូច្នោះទេ ក្នុងអាណាខេត្តសេរីសោភ័ណយើង។ មនុស្សម្នាក់ៗ សប្បាយគ្រប់ៗគ្នា។ អ្នកលក់ដូរក៏ចេញទៅលក់ព្រោងព្រាត ។ អ្នកដើរមើលក្បួនទ័ពក៏ច្រើន ណែនណាន់តាន់តាប់ ដើរចុះឡើងប្រជ្រៀតប្រជែងគ្នា។ ទ័ពក៏ហែព័ទ្ធជុំវិញបន្ទាយព្រះកម្តត ចំនួនបីជុំ ឆាកហោជយោលាន់ឮរណ្ដំគ្នាអឹងកង ។ ភ្លេង និង ស្គរឲ្យចង្វាក់ដល់ទាហានដែលដើរ។ ក្មេងៗរត់តាមមើលប្រញាយ កាន់ដៃគ្នារណោង។ នាងទេវីនៅផ្ទះតែងខ្លួនស្អាតបាត។ ធីតាចង់ទៅទទួលប្ដី តែនាងពុំហ៊ានទៅទេ ព្រោះខ្លាចក្រែងគេសើចនាង ។ ស្ត្រីបារម្ភក្រែងនាងយំនៅមុខគេឯង នាំឲ្យខ្មាសគេ។ ទេ! នាងពុំទៅទេ ព្រោះប្រាំបីខែមកហើយ ពុំដឹងប្រុសប្រែប្រួលយ៉ាងណា។ បើនាងទៅទទួលគេ ហើយស្រាប់តែគេធ្វើពុំស្គាល់នាងក៏ពុំដឹង នោះនាងមុខជាដាច់ខ្យល់ស្លាប់ភ្លាមក្នុងពេលនោះមិនខាន។ កល្យាណនឹកទៅទៀតថា បើគេស្មោះចំពោះនាង ស្រលាញ់នាងពិតៗ ប្រាកដជាគេមករកនាងហើយ ។ អាស្រ័យហេតុនេះ នាងសម្រេចថាត្រូវរង់ចាំប្ដីអែផ្ទះទើបត្រូវ។ ស្រីនៅផ្ទះមែន តែនាងលួចស្ដាប់សូរស្គរ និង សូរមាត់គេដែលស្រែកទ្រហឹងអឹងកង។ នាងស្រៀវក្នុងចិត្តចង់ទៅឲ្យឆាប់បានឃើញមុខប្ដី។ ចំណង់នេះរកទប់ស្ទើរពុំឈ្នះ។ ដើម្បីបំភ្លេចសេចក្ដីទន្ទឹង នាងដើរចុះដើរឡើង តែក្នុងផ្ទះម្នាក់ឯង ក្នុងការទន្ទឹងរង់ចាំនេះ មួយនាទីយូរដូចមួយសតវត្ស។ មនុស្សម្នាក់លោតចូលតាមបង្អួចឮសូរគ្រឹប។ នាងទេវីភ្ញាក់ងាកទៅ ស្រាប់តែឃើញកាមាជាប្អូនមានន្ទមកដល់។ នាងភ័យតក្កមា ស្ទើរស្លុតស្មារតី។ កាមាដើរទៅរកនាងឈរជំទាញជើង ដៃទាំងពីរកាន់ដាវ ដែលហូតទុកជាស្រេច។

- ថ្ងៃនេះជាថ្ងៃចុងក្រោយបំផុតដែលខ្ញុំប្រើវិធីឃោរឃៅ . . . ។ ខ្ញុំបាននិយាយនឹងអ្នកឲ្យមានចិត្តស្មោះស្ម័គ្រនឹងខ្ញុំ ព្រោះខ្ញុំបានស្រលាញ់អ្នកស្មើជីវិត។ ពាក្យដែលខ្ញុំនិយាយទៅអ្នក អ្នកឥតស្ដាប់ខ្ញុំសោះ។ ខ្ញុំដាក់ខ្លួន

ហេតុដល់ទៅហ៊ានអង្វរចិត្តអ្នក ។ ឥឡូវខ្ញុំឈប់និយាយ ឈប់អង្វរទៀតហើយ ។ ខ្ញុំចាប់ប្រើវិធីអកុសល ប្រាកដ ។ ខ្ញុំស្តាយណាស់ដោយអ្នកបង្ខំឲ្យខ្ញុំលេងវិធីដ៏លាមកនេះដែលខ្ញុំពុំចង់លេងឡើយ។ តែខ្ញុំធ្វើនេះ គឺ ប្រាកដធ្វើដោយចិត្តចង់ ដោយចេតនា ដើម្បីលុបលាងអាម៉ាស់របស់ខ្ញុំចំពោះអ្នក ដែលខ្ញុំបានវាយលើ កំណាត់ជីវិតរបស់ខ្ញុំជាមួយនឹងអ្នក ។ ថ្ងៃនេះ ជាថ្ងៃផ្តាច់ព្រាត់របស់ខ្ញុំ។

កាមានិយាយដោយពាក្យធ្ងន់ៗ ។ នាងទេវីចំហមាត់ បើកភ្នែកធំៗស្តាប់ ។ សេចក្តីភិតភ័យមួយយ៉ាងធំមកគ្របដន្ដប់ ដួងចិត្តនាងជាប់។ នាងយំអង្វរថា ៖

- ទេ ! លោក ៗ កុំធ្វើបាបខ្ញុំ . . . ។

កាមាគំហកវិញថា៖

- ខ្ញុំធ្វើល្អណាស់ហើយជាមួយនឹងអ្នក។ អ្នកពុំព្រមយល់ ពុំព្រមធ្វើតាម ពុំព្រមជឿខ្ញុំ។ នែ ! ទេវីស្រីវរលក្ខណ៍ មើលនុ៎ះហ្ន៎ !

កាមាចង្អុលទៅបង្អួចដែលចំហនៅផ្ទះធំមួយទៀត។ នាងទេវីមើលតាម ឃើញកូនស្រីរបស់នាងគេងលក់ស្កប់ស្កល់។ នាងស្ទុះក្រោក តែចុងដាវកាមាចុចជាប់ត្រង់កនាងកន្លែងជីពចរមិនឲ្យស្រីកម្សត់ក្រោកបាន។ ដោយតឹងទ្រូងពេក ធីតាទ្រហោយំ ហើយពោលយ៉ាងអាក់អួលថា៖

- កូន ៗ មាសម្តាយ កូន ! ម្តាយនឹកកូនណាស់ កូនមកនេះមក។ កូនមកពីណាបាត់យូរម្ល៉េះ ? កូននឹកម្តាយ ទេ ?។ ឱ !កូនគេងលក់ទេ ? ម្តាយស្មានតែកូនស្លាប់ទៅហើយ។ កូនទៅណាបាត់ប៉ុន្មានថ្ងៃ? កូនបានអ្វី បៅ ? លោក ! ខ្ញុំសុំកូនខ្ញុំមកវិញ។

កាមាគំហកទៀតថា៖

- នៅឲ្យស្ងៀម មើលទៅទៀតមើល!

នាងទេវីចោលភ្នែកទៅទៀត នាងស្រែកយ៉ៃឡើង ដោយនាងបានឃើញមនុស្សម្នាក់មាឌធំ ចាប់លើកបីកូននាង ដែលនៅក្នុងពូកឡើង។ មនុស្សមោហនេះយកចុងដាវដាក់លើកូននាងដែលដេកលក់ ហាក់បម្រុងនឹងប្រហារជីវិត។

- អែ ! ធ្វើយ៉ាងនេះស្លាប់កូនខ្ញុំហើយ។ លោកធ្វើអ្វីយ៉ាងហ្នឹង អាណិតកូនខ្ញុំទៅកុំធ្វើបាបគ្នា។ ឱ ! ស្លាប់ឥឡូវ ហើយ ព្រះម្ចាស់ថ្លៃអើយ ! កុំ ៗ លោកជួយខ្ញុំផង កុំៗ។

នាងទេវីញ័ររន្ធត់អស់អង្គប្រាណ។ កល្យាណបម្រះននៀលរមួលខ្លួន។ ចុងដាវធ្វើឲ្យនាងតក់ស្លុតត្រជាក់ចុងដៃ និង ចុងជើង។ នាងដាក់ភ្នែកចុះ ពុំមែនកែវពុំហ៊ានមើលទេ តែស្រីអាក្នុងចិត្តក្រៃពេក។ នាងយំឮយឺសៗ។ កាមាពេប មាត់និយាយថា៖

- ទេវី ! វាមិនទាន់ស្លាប់ទេ ។ ចូរអ្នកជ្រាបថា គឺខ្ញុំនេះហើយដែលបានលួចយកកូនអ្នកទៅ។
- ចាំះ ! លោក ! ឱ ! លោកយកកូនខ្ញុំទៅឬ ? ចាំះ !
- ឥឡូវនេះអ្នកចង់បានកូនអ្នកវិញទេ?

- ចា៎ះ លោក ចង់បាន សុំអាណិតខ្ញុំទៅ ខ្ញុំអង្វរ . . . !
- តើអ្នកស្រលាញ់កូនអ្នកទេ ?
- ចា៎ះ លោក ស្រលាញ់ ហ៊ី ! ស្រលាញ់ណាស់ . . . ពេក ស្រលាញ់ផុតអស់របស់ដែលមានក្នុងលោកនេះ។
- តើអ្នកចង់ឲ្យកូនអ្នកស្លាប់ ឬ រស់ ?
- ចា៎ះ ! ចង់ឲ្យរស់!
- អើ ! បើចង់ឲ្យកូននេះរស់ ងាយណាស់ !
- ឲ្យខ្ញុំធ្វើយ៉ាងណា ? ចា៎ះ ខ្ញុំចង់ឲ្យរស់ ធ្វើយ៉ាងណាលោក ខ្ញុំធ្វើទាំងអស់។ ជម្រាបប្រសាសន៍មកខ្ញុំធ្វើ។

កាមាសើច មើលមុខកល្យាណយ៉ាងកំណាច។ បុរសបន្តវាចាទៅទៀតថា៖

- កិច្ចអ្នកត្រូវធ្វើងាយទេ។ បន្តិចទៀត ប្ដីអ្នកមុខជាមកដល់ទីនេះហើយ ។ ដើម្បីឲ្យកូនរស់ ដើម្បីឲ្យបានកូនមកដៃអ្នកវិញ ដល់ប្ដីអ្នកមក ឲ្យអ្នកនៅស្ងៀមធ្វើថ្លង់ ធ្វើដូចគ កុំនិយាយឲ្យសោះ។
- គ្រាន់តែកុំនិយាយឲ្យសោះប៉ុណ្ណោះ ឬ លោក ?
- អើ ! ទោះជាមួយមាននួ ក៏កុំនិយាយដែរ។
- ទេ ! ខ្ញុំនឹកប្ដីណាស់ ខ្ញុំសុំនិយាយរកគាត់បានបួនដប់ម៉ាត់ អាណិតខ្ញុំទៅ ខ្ញុំនឹកគាត់ណាស់។
- មិនបាន ! បើអ្នកហ៊ានតែហើបមាត់មួយម៉ាត់ កូនអ្នកមុខជាស្លាប់មិនខាន អ្នកឃើញទេខ្ញុំនៅទីនេះ បើអ្នកហ៊ាននិយាយមួយម៉ាត់ ខ្ញុំគ្រាន់តែធ្វើសញ្ញាបន្តិចទៅ អ្នកដែលកាន់កូនអ្នកនោះសម្លាប់កូនអ្នកចោលមិនខាន ។ ម៉េចអ្នកយល់ទេ ?
- ចា៎ះ ! ខ្ញុំយល់ហើយ ហ៊ី ! លោកគ្មានមេត្តាដល់ខ្ញុំសោះ ម៉េចក៏លោកមិនចង់ឲ្យខ្ញុំនិយាយនឹងប្ដីខ្ញុំ ? ខ្ញុំធ្វើដូចលោកមិនកើតទេ សូមលោកអត់ទោសចុះ ។ ឱប្ដីអើយ ! ឱកូនអើយ ! ខ្ញុំស្លាប់ហើយ។
- មើលហ្ន៎ ! ឃើញទេ ?
- អស់ ! ឱ ទេៗ កុំសម្លាប់កូនខ្ញុំ ទេ! លោកអើយ លោកអើយ ឱ!
- ម៉េចធ្វើតាមខ្ញុំឬទេ ឆាប់ៗឡើង ?
- ហ៊ឺស លោកអើយ!
- ថាឲ្យភ្លាមមក !
- ចា៎ះ ! ខ្ញុំធ្វើតាមទាំងអស់ហើយ!
- ម៉េចអ្នកធ្វើតាមខ្ញុំទេ ? និយាយឲ្យត្រង់ទៅ!
- ចា៎ះ ខ្ញុំយល់ព្រមហើយលោក!
- អើ ! អ្នកត្រូវនៅឲ្យស្ងៀមមួយកន្លែងនេះ។
- ចា៎ះ ! ខ្ញុំធ្វើបាន . . . តែកាលណាទៅបានលោកឲ្យកូនមកខ្ញុំវិញ។
- មិនអីទេ ចាំខ្ញុំយកមកឲ្យ។
- កាលណាទៅ ទើបខ្ញុំអាចនិយាយបាន ?
- ចាំខ្ញុំជូនដំណឹងជាក្រោយ តែមិនយូរទេ មួយភ្លែតប៉ុណ្ណោះក៏បានហើយ

- ចាះ ! ខ្ញុំត្រេកអរណាស់ ខ្ញុំមិនភ្លេចទេ ខ្ញុំធ្វើតាមលោកមិនឲ្យខុសទេ គឺនៅស្ងៀមមួយកន្លែងនេះ រួចមិននិយាយមួយម៉ាត់សោះ ។ អូ តិចលោកច្រឡំធ្វើសញ្ញាអ្វីទៅ។ គេសម្លាប់កូនខ្ញុំហើយ។
- ទេ ! ទេ ! ខ្ញុំមិនច្រលំទេ!
- អោ ! កូនកំសត់អើយ . . . ។

ជើងសេះមួយលាន់ឮរំពង ឯវាលស្រែ។ សូរជើងសេះនេះកាន់តែមកជិតដល់។ នាងទេវី ព្រឺព្រួចក្នុងក្នុងចិត្ត។ កាមាមើលតាមបង្អួចទៅឃើញប្រាកដជាបងរបស់ខ្លួន គឺមានន្ទនោះឯង។

- ឥឡូវនៅស្ងៀមឈប់និយាយ។

នាងទេវីក៏ប្រុងស្មារតី ដៃទាំងពីរសំពះឱនមុខលុតជង្គង់ ។ ធីតាឮសូរជើងសេះដែលធ្វើឲ្យនាងព្រឺអស់ទាំងខ្លួន។ នាងភ័យផងអរផង។ នាងនឹកឆ្ងល់ថា អាកាមានេះវាឲ្យនាងធ្វើដូច្នោះ តើមានប្រយោជន៍អ្វី ? នាងបំបែរដៃនាងដែលសំពះឲ្យចំមាត់ទ្វារ ព្រោះកែវរលក្ខណ៍ដឹងថាគឺតាមច្រកទ្វារនោះហើយដែលប្តីនាងបម្រុងនឹងចូលមក។ មានន្ទមកដល់មុខខ្ទម លោតចុះពីលើខ្នងសេះយ៉ាងរហ័ស។ អ្នករត់តម្រង់ទៅមាត់ទ្វារខ្ទម។ លុះទៅដល់មាត់ទ្វារអ្នកទុចង៉ក់ មើលឃើញកាមានៅឈរច្រត់កែងដៃនឹងបង្អួច ឃើញនាងទេវីសំពះអ្នកយ៉ាងស្មោះស្ម័គ្រ។

- កាមា រឿងអី ?

កាមាសើចនិយាយយ៉ាងស្ងួតថា៖

- ខ្ញុំសូមជូនបងស្រីដែលបងបានផ្ញើខ្ញុំ ថែរក្សានោះមកបងវិញ។

មាន្ទននៅស្ងៀមស្តាប់កាមា រួចនិយាយថា៖

- ម្តេចក៏ឯងនិយាយសើចហាក់ខ្ចើមរអើមម្ល៉េះ ?
- ហាស់ ៗ ពីព្រោះជារឿងដែលខ្ញុំពុំគួរនឹងជម្រាបបងសោះ។

មានន្ទខាំធ្មេញក្រឹត។

- រឿងអីកាមា ? កាមាប្រាប់មកឲ្យឆាប់ !
- កាមាដើរធ្វើវាយមាយនៅជិតបង្អួចនោះ
- អើ ! សមណាស់ហើយ ប្រពន្ធបងនោះ ។ សមមុខបងឯងណាស់ហើយ ។ កាលបងផ្តាំផ្ញើខ្ញុំ ៗ នឹកស្មានថាជាស្រីមួយល្អគួរគោរព ។ តែដល់ចុងបង្ហើយ ហ៊ី ! ខ្ញុំមិនចង់និយាយទៀតទេ។

មាន្ទនស្ទុះទៅចាប់កាមា ញញធ្មេញ មុខឡើងក្រហម។ ទេវីរលត់អស់ស្មារតី។

- កាមានិយាយ តោងនិយាយប្រាប់បងឲ្យឆាប់មក!
- រឿងនេះក្រែងបងខឹងជ្រុលណា!
- រឿងអ្វី ? កាមារឿងអ្វី ? យី ! កាមាតោងនិយាយមក។

- ដោយបងតឿនឲ្យខ្ញុំនិយាយហើយ ខ្ញុំក៏និយាយទៅចុះ ប្រពន្ធបង ខ្ញុំបានបណ្ដេញចេញពីភូមិយើង។ ខ្ញុំសូមទោសបងទៅចុះ។ តែបានជាបណ្ដេញនេះ ពីព្រោះទេវីជាស្រីមួយយ៉ាងអាក្រក់បំផុត នាងលួចមានសហាយ។
- យី ! អីទេវីមានសហាយ ? ទេវីក្បត់អញ ?
- បាទ !
- សហាយនឹងអ្នកណា ? អាណាមួយហ៊ានសហាយជាមួយប្រពន្ធអញ ? ប្រាប់មកៗ អូនប្រាប់បងមក។
- បើបងដឹងបងធ្វើអាសហាយនោះយ៉ាងណាទៅ ?
- ហ៊ឹស កាមាអូន ! ដាវៗ កាត់ហុតឈាម!
- ហ៊ីៗ សហាយវានេះមិននៅឆ្ងាយទេ គឺនៅជិតៗនេះ។ គឺជាមនុស្សម្នាក់ខែងសម្ដីលើក ឫកពាខ្ពង់ខ្ពស់ បុណ្យស័ក្តិធំ ប៉ុន្តែបងទៅចងពៀរនឹងអាសហាយនោះបានជាការអ្វី ? ស្រីវាខូចទេតើ ?
- អញផ្ដាន្ទាទោសទាំងពីរហ្នឹង ។ កាមា ! អញឲ្យឯងជួយរក្សា ឯងគ្មានបានការអើទេ។
- ខ្ញុំមើលអស់ប៉ុណ្ណឹងហើយ!
- កាមា អាណាមួយមានបណ្ដាសក្តិធំ ហ៎ ? តើអាណាមួយ . . . បងចង់ស៊ីសាច់ហុតឈាមវាឥឡូវ កាមាប្រាប់មងមក វានៅជិតៗនេះវី ?

កាមាសើច និយាយមួយៗថា៖

- មនុស្សអប្រិយកំណាចចិត្តទាបអាម៉ាស់នោះ គឺ . . . គឺ . . . គឺ . . . ខ្ញុំ ។
- ប្អូនឯង ? យី ! អីប្អូនឯងសហាយនឹងប្រពន្ធបង ?
- បាទ គឺខ្ញុំនេះឯង !
- យី ! កាមា ! ប្អូនសំលាញ់ . . . នែ! ម្ដេចទេវីអូន ! ម្ដេចអូនធ្វើដូច្នោះ? ទេវីអូន ! បងស្រលាញ់អូនប្ដូរជីវិត គ្មានតក់ គ្មានណាយ គ្មានភ្លេចមួយពេល។ បងអាណិត ប្អូនរាល់វេលា។ ទេវីអូន ! បងស្រលាញ់ហៅពេញបង់ចិត្ត អូនក្បត់ចិត្តបង។ បើអូនទៅស្រលាញ់អ្នកណា ក្រៅពីប្អូនរបស់បង ។មិនថាអ្វីទេ នេះប្អូនស្រលាញ់ប្អូនប្រុសរបស់បង។ ក្ដៅណាស់ ក្រហាយណាស់ ឈឺណាស់ ! ទេវី ! ទេវីអូន ! ហេតុម្ដេចយ៉ាងហ្នឹង ? អូននិយាយមកមើល ប្រាប់មក ពន្យល់មក។
- មើលហ្ន៎ ! សត្វនេះវានៅស្ងៀមឈឹង ។
- ទេវី ៗ !យើងព្រាត់គ្នាពីពេលនេះហើយ។

មែន ! នាងទេវីព្រាត់មែន ព្រាត់ព្រោះនាងនិយាយពុំរួច កម្រើកខ្លួនពុំបាន។ ជីតាមានតែទឹកភ្នែកដែលហូរប៉ុណ្ណោះ។ ដៃនាងឡើងញ័រ ចិត្តនាងតឹងៗជាងជាប់ចំណងប្រាំប្រការទៅទៀត ។ ពាក្យរបស់កាមាមួយម៉ាត់មានពាក្យថា នាងបានសហាយនឹងវា ធ្វើឲ្យចិត្តនាងធ្លាក់ក្តុកយ៉ាងខ្លាំង។ ពាក្យនេះចាក់ដោតដួងចិត្តនាងយ៉ាងកាចបំផុត រួចមុតដូចកាំបិតដែលចាំងរំលំព្រឹក្សានៃសេចក្តីសុខរបស់ស្រី។ ឱ ! ប្ដីនាងពុំដឹងរឿងនឹកស្មានថាការនេះជាការពិត។ មានន្ទបែរទៅនិយាយជាមួយកាមាថា

- ថ្ងៃបែរគេងភ្នំ ប្អូនឯងទៅជួបនឹងបងនៅក្រោមដើមពោធិ៍កុំខាន។

កាមាសើចក្អាកក្អាយងក់ក្បាលតបវិញ៖

- បាទបង ! ថ្ងៃបែរគេងភ្នំជួបគ្នាក្រោមដើមពោធិ៍។

រួចមានន្ទបែរមកមើលនាងទេវីជាចុងក្រោយបង្អស់។ អ្នកមួម៉ៅក្ដៅក្រហាយក្នុងចិត្តជាពន់ពេក។ ពីដើមរូបនាងទេវីជាទីត្រជាក់ចិត្ត ឥឡូវរូបដដែលនេះក្លាយទៅជាភ្លើងទៅវិញ។ អ្នកខឹងយ៉ាងខ្លាំង ហួតដល់លែងមើលមុខនាងទៀត អ្នកនិយាយជាទីបង្ហើយថា៖

- ទេវី ស្រីកាលកាឡកណ្ណីឫស្យា អញលែងបានឃើញឯងទៀតហើយ។

ថាដូច្នោះស្រេច មានន្ទស្ទុះចេញពីផ្ទះ រត់ឡើងលើខ្នងសេះទៅ។ ព្រលឹងនាងទេវីស្ទុះតាមបណ្ដាលឲ្យរូបនាងដួលដេកស្ដូកលើក្ដារ។ លើខ្នងសេះ មានន្ទឈឺចាប់ក្នុងចិត្តជាពន់ពេក។ ភ្នែកលែងមើលអ្វីឃើញ ត្រចៀកលែងឮអ្វី នេះហើយដែលជាស្ថានភាពដែលអ្នករស់ក្នុងកេសារបស់អ្នកហាក់មានអ្វីវិលស្លុង នាំឲ្យនឹកអ្វីពុំឃើញ គិតអ្វីក៏ពុំយល់ មានតែរឿងនាងទេវីកាឡកណ្ណីប៉ុណ្ណោះទេដែលមកបុកដើមទ្រូងអ្នក ញាំងៗ គ្មានត្រាប្រណី។ បុរសនឹកឃើញកាលគ្រាមុន អ្នកស្រលាញ់ស្ត្រីនេះយ៉ាងអស់ពីពោះ។ អ្នកបានប្ដេជ្ញាថា រស់ស្លាប់ជាមួយទេវីតែមួយរហូតរៀងទៅ ដោយជឿថា ជីវិតអ្នកមុខជាបានរស់និត្យនៅជាមួយនាងមិនខាន។ ហើយស្មានទៀតថា នាងមុខជាធ្វើឲ្យអ្នក បានសប្បាយជានិច្ចវិញ។

មាណពប្រឹងត្រិះរិះរកឃើញថា កាលស្រលាញ់គ្នានោះ នាងនេះបាននិយាយនឹងអ្នក រួចកាលនិយាយគ្នានោះ នាងបានបង្ហាញឲ្យឃើញថា នាងស្មោះត្រង់មែនស្ទើរហ៊ានចាត់ទុកថា គ្មាននារីណាមួយមកប្រៀបបានឡើយ ពីព្រោះគ្រប់ពាក្យដែលនាងចេញស្ដី នាងគ្មានបានគិតទេ ស្រីនិយាយរអិលរអិចទាក់។ រីឯពាក្យមួយម៉ាត់ៗ បុរសជាសង្សារសង្កេតឃើញទឹកចិត្តមែនៗ នៃសេចក្ដីស្នេហា។ មកដល់មួយពេលនេះ ទេវីស្រីដាច់ចិត្តមានសហាយទៀត ភ្លេចអ្នកជាប្ដី ភ្លេចអស់ពាក្យសម្ដី ភ្លេចអស់អំពើដែលធ្វើទៅវិញទៅមកតាំង ពីអំពើតូចតាច បន្តិចបន្តួចរហូតដល់ទៅលូកដៃចោលខ្លួនទាំងស្រុងចូលក្នុងរង្វង់ដៃគ្នាទៅវិញទៅមក រហូតដល់រួមរស់ រួមមេត្រីនៃបរិត្យគ្នាជាប្ដីប្រពន្ធ។ មានន្ទនឹកឃើញសព្វគ្រប់ដូច្នោះ អ្នកអស់កម្លាំងចិត្តហេវនឹងរកជឿស្រីណាទៀតមិនបាន។ ក្នុងពេលនោះ អ្នកចាត់ស្រីទាំងអស់ជាភេទអប្បលក្ខណ៍ អាក្រក់រកគ្មាន។ ភេទមោហៈ នេះជាភេទស្រើបស្រាល នឹងកាមរាគ ចិត្តមិនធ្ងន់ មិនចេះអត់ មិនស្គាល់ខុសត្រូវ អាក្រក់ល្អ ស្រេកឃ្លាននឹងកាមគុណ ឃ្លាន ! ឃ្លាន ! . . . ណាស់ឃ្លានរហូតទៅក្បត់។ មានន្ទខាំធ្មេញ ដោយហាក់មើលឃើញនាងទេវីធ្វើឫក ធ្វើពារកកាមាជាសហាយ។ កម្លោះហាក់ឃើញនាងញញឹមដោយឥតអៀនខ្មាស ដាក់ប្រុសថ្មី ហាក់ឃើញនាងបើកទ្វារឲ្យគេចូលមក ដោយស្ទុះទៅទទួលគេ ចោលខ្លួនទាំងស្រុង ទៅក្នុងកណ្ដាប់ដៃគេ បណ្ដោយឲ្យគេឱបរឹតដូចកាលនាងបានធ្វើជាមួយអ្នកដែរ ។ ស្រីឫស្យានេះនិយាយរកគេ ដូចបាននិយាយនឹងអ្នកជាប្រាកដ។

មានន្ទនឹកទៀតថា បើអ្នកមកទាន់ក្នុងពេលនោះ អ្នកមុខជាហូតដាវវាត់ឲ្យដាច់ចង្កេះទាំងពីរនាក់ឲ្យស្លាប់ ជាមួយគ្នាមួយរំពេចមិនខាន ។ ក្រោយពីសុបិននេះ មានន្ទសន្មតថា ស្រីដែលមានរូបល្អជាស្រីមានចិត្តអាក្រក់ ។ រូបវាល្អណាស់ វាអាងរូប ចង់ឲ្យតែគេរាល់គ្នាស្រលាញ់វា។ ឱ ! ទេវី ! ស្រីទាំងអស់អាក្រក់គ្មានសល់មួយនាក់ ទោះមានរូប

មិនល្អក៏ដោយ គឺថាណាមួយក៏ដូចណាមួយ។ អាស្រ័យហេតុនេះ មានន្ទនឹកដល់ព្រះពុទ្ធអង្គលោកបានហៅចំដាកំពូលមនុស្សមែន។ លោកយល់រឿងនេះ រួចបានលះបង់ទាំងអស់ដើម្បីព្រះនិព្វាន ដែលជាឋានផុតទុក្ខ។

ជិះលើខ្នងសេះមានន្ទវង្វេងអស់ស្មារតី។ នឹកម្តងឃើញថាត្រូវសម្លាប់ស្រីៗឲ្យអស់។ នឹកម្តងឃើញថា ត្រូវសម្លាប់ប្រុសៗដែលអាក្រក់ ទៅស្រលាញ់ប្រពន្ធគេឲ្យអស់បានត្រូវជាង។ នឹកតទៅទៀតឃើញថាទេ! កុំវល់ នេះហើយជាជីវិត មានទុក្ខ មានសុខ មានក្បត់ មានស្រលាញ់ មានស្អប់ . . . ។ល។ សំរេចសេចក្តី មានន្ទនៅតែមានទុក្ខដដែល។ វាលដែលអ្នកកំពុងជិះសេះកាត់ធំល្វឹងល្វើយ បីដូចវាលវដ្តសង្សារដែលអ្នកកំពុងឆ្លងកាត់។ អ្នកឃើញថា អ្នកប្រឹងទៅមុខតែម្នាក់ឯងត្បិតគូស្នេហាគេចោលអ្នកហើយ។ វាលនេះមើលយូរបន្តិចទៅ ក្លាយទៅជាមហាសាគរមួយដ៏ធំក្រៃលែង ដែលរកមើលជើងមេឃពុំឃើញ ។ ខ្យល់ដែលបក់រវិចៗ ក្លាយទៅជាខ្យល់ព្យុះព្យោមាយ៉ាងខ្លាំងអនេក ។ សេះដែលអ្នកជិះក្លាយជាកូនទូកតូចមួយ ដែលឃ្លេងឃ្លោងៗ កណ្តាលសមុទ្រ បោកបក់ដោយជំនោរខ្យល់។ តែកូនទូកនេះ គឺមានន្ទដែលភ័យប្រឹងតស៊ូនឹងខ្យល់ កុំឲ្យលិចទូកបាន។

ទឹកភ្នែកក៏ហូរចេញពីភ្នែកមានន្ទធ្លាក់ដល់ដី។ អតីតសង្សារនាងទេវីនឹកសង្វេគខ្លួនពន់ពេក។ បុរសពុំដែលយំសោះ តែក្នុងពេលនេះអ្នកយំ ។ អ្នកនិយាយក្នុងចិត្តថា៖

- ទេវីអូន ! បងព្រាត់ពីអូនតាំងពីពេលនេះហើយ ! អូនជាគូកម្ម នឹងបងទេ ។ បងមិនធ្វើអ្វីដល់អូនទេ ! កុំព្រួយ ។ បងមិនចងពៀរទេ។ សូមអូនទៅរស់ជាមួយគូថ្មីរបស់អូនចុះ រស់ឲ្យបានសប្បាយតាមបំណងចិត្តអូនចុះ។ បងមិនខឹងទេ ពីព្រោះបងធ្លាប់ដែលបានរួមរក្សរូបអូនហើយ ។ បងមានជ័យជំនះលើអូនជានិច្ចមានតែអូនទេដែលចោលបងនោះ ចាញ់បង ។ បងឈប់ស្រលាញ់អូនទៀតហើយព្រោះអូនស្រលាញ់គេ។ បងមិនស្តាយអូនទេ ព្រោះអូនមិនស្តាយបង។ ពីពេលនេះទៅអូនដើរផ្លូវមួយ បងដើរផ្លូវមួយ ព្រោះផ្លូវយើងដើរនោះវាបែកគ្នា ។ អូនមានសង្សារថ្មី បងដើរទៅមុខតែម្នាក់ឯង គ្មានសង្សារ ។ អូននៅតែមានទុក្ខ បងផុតអស់ទុក្ខហើយ ។ អូននៅតែមានចំណងចង បងទៅណាក៏បានធ្វើអ្វីក៏បាន ដេកត្រង់ណាក៏បាន បាយត្រង់ណាក៏បាន តាមចិត្តឥតចំណង បងមានប្រៀបលើអូនជានិច្ច ព្រោះថាបើប្តូរប្រុសរបស់អូននឹងបង គង់ឃើញថាបងគ្រាន់បើជាងប្រាកដ ទាំងផ្លូវចិត្ត ទាំងផ្លូវលើសីលធម៌ ទាំងផ្លូវមនុស្សធម៌ ទាំងផ្លូវតម្រិះវិជ្ជា ទាំងផ្លូវបុណ្យសក្តិ ទាំងផ្លូវថ្លៃថ្នូរ។ លើពិភពផែនដីនេះ តើអូនរកមនុស្សណាឲ្យបានដូចបងទៀតទេ ? ។ បងជាមនុស្សចេះជួយសង្គ្រោះគេ ដោយមិនគិតគ្រោះខ្លួន ចេះគោរពស្រលាញ់គេជាងស្រលាញ់ខ្លួនឯង ចេះឈឺឆ្អាលដល់រឿងគេដោយឥតគិតដល់រឿងខ្លួនហួសហេតុ ចេះជួយកិច្ចការឲ្យគេ ហ៊ានធ្វើការឲ្យគេ ទោះតែម្នាក់ឯងក៏ហ៊ានធ្វើដែរ។ ឱ ! អូនទេវី ! អូនស្រលាញ់គូថ្មីព្រោះអ្វី ? ព្រោះប្រាក់មែនទេ? ព្រោះគេ

ចេះសប្បាយហ៊ឺហា ព្រោះគេចេះបញ្ឆោត ចេះបោកផងមែនទេ ?។ ទេវីអូន ! បងពុំចេះដូចគេទេ ។ ហេតុនេះ សេចក្តីសំរេចវាសនាអូន គឺអូន។ បងទុកឯកសិទ្ធិនេះលើអូនចុះ តែបងគ្រាន់តែអាណិតអូនដោយស្រីមើលតំលៃមនុស្សខុស។ ទេវីអូន ! បងខំបំភ្លេចរឿងអូន និង បងឲ្យភ្លេចសូន្យពីពេលនេះទៅ។

ព្រះអាទិត្យជ្រៀងជ្រេគងលើភ្នំស្វាយហើយ។ ពពកក្រហមឆ្អៅនៅផ្តុំរាយមាយត្រង់នេះ ត្រង់នោះ ។ ឃើញមេឃចិត្តកើតក្តីសង្វេគដោយនឹករឭកដល់ពេលដែលទ្វីបលោកត្រូវធេះកល្បទៅអនាគត។ គឺក្នុងពេលចុងបំផុតនេះហើយ

ដែលមនុស្សត្រូវរលាយរូប រលាយខន្ធ ប្រាសចាកអស់ទុក្ខផងទាំងពួង។ ឱ ! គឺថ្ងៃគងភ្នំនេះហើយដែលលោកអ្នកចាំបានថា មាននួសន្យាជួបកាមាជាប្អូន។ មាននួស្ទុះលោតលើខ្នងសេះ បំផាយត្រង់ឆ្ពោះទៅដើមពោធិ៍កណ្តាលស្រែ ដែលបាននិយាយទុក។ តាំងពីព្រឹកមក អ្នកលេបបាយពុំរួច ដេកពុំលក់ចេះតែរសាប់រសល់។ លុះដល់ទីកំណត់អ្នកលោតចុះពីលើខ្នងអាជានេយ្យដែលអ្នកចងនៅជិតនោះ។ បុរសច្រត់កែងដៃទាំងពីនៅចង្កេះដើរចុះដើរឡើង មើលនាយអាយរួចឈរគិតរឿងដដែលតែមួយ គឺរឿងនាងទេវីជាភរិយាក្បត់ចិត្តអ្នក។

នៅជើងមេឃ សេះមួយទៀតផាយកាន់តែជិតមក។ មាននួឈប់ឈរនៅស្ងៀមមើលសេះនេះ។ លុះបានមកដល់ជិត អ្នកជិះសេះលោត ចុះមកដីលែងសេះឲ្យបរិភោគស្មៅទើបមកគោរពមាននួយ៉ាងគួរសម។ ដោយឥតមាននិយាយមួយម៉ាត់ មាននួហូតដាវខ្វាកប្រាប់ថា៖

- កាមាប្អូនប្រុងខ្លួន ពីព្រោះបងបានសន្យាថាសំលាប់អាចោរលួច ប្រពន្ធគេឲ្យអស់ពីដែនដីខ្មែរ។
- មានជាការអីបង !

កាមាញញឹម ក៏ហូតដាវវិញ ដាវមាននួកាប់ឆ្វេងឮផាំងៗ រន្ទើនគ្នារន្តំដូចលាចផ្ទុះ។ តែកាមាកាត់ឮច្រែស ៗ ដូចសូរផាវ។ មាននួកាប់ខាងស្តាំបុាំង ៗ សូរជាប់ប្រកិតគ្នា ។ កាមារងជាប់យ៉ាងអង់អាច។ មាននួគ្រវាសដាវកាប់ពីលើបុាំងៗ។ កាមាវាសដាវរងបានទៀត មាននួចាក់បណ្តើរសើចបណ្តើរ

- យើ ! ប្អូនឯងគ្រាន់បើឥឡូវ!
- បាទ ! ល្មមតែស៊ីសងបានដែរ ។ ហ៊ឺ សុំជូនបងវិញម្តង!

ក្នុងពេលនោះ ដាវកាមារហ័សដូចរន្ទះ ស្ទុះវាត់មាននួខាងឆ្វេងត្រឹមចង្កេះ រួចរត់វឹងទៅរះខាងស្តាំ រួចលោតមកពីលើវិញ។ បើភ្នែកពុំរឹង ស្មារីតីពុំបាន ប្រហែលជាពុំអាចរងនឹងមុខដាវទាំងពីរយ៉ាងដែលមានទម្ងន់មហិមានេះទេ។ តែមាននួវៃណាស់ រងទាន់ឮប៉ែសៗ បែកព្រាយព្រិចៗ។ កាមាសើចនិយាយម្តងថា៖

- យើ ! គ្រាន់បើដែរ។

មាននួសើចតបវិញ

- មិនអ្វីទេ !

លំដាប់នោះគេឮសូរតែដាវរីតៗ ផាំងៗ គួរស្ញើបក្រៃពេក។ ជនទាំងពីរសុទ្ធសឹងតែចំណានក្នុងវិធីកាន់អាវុធ។ ជនទាំងពីរជួនកាល ជួបជិតគ្នា ស្អិតដូចតាំងម៉ែ ជួនកាលថយឆ្ងាយពីគ្នា។ ជួនកាលមាននួជាបងជំពប់ជើងដួល កាមាស្ទុះទៅបម្រុងសម្លាប់ចោល តែមាននួគេចផុត បណ្តាលឲ្យកាមាជ្រុលខ្លួនដាំទឹង នឹងដី។ រួចក្រោកឡើងទាំងពីរវិញបន្ទាន់បន្ទាប់គ្នា ចុងដាវក៏ប្រកៀកប្រកិតគ្នាជាថ្មី។ កាមាដួលវិញ មាននួស្ទុះទៅសង្កត់ពីលើ ប្រឹងរមួតដៃទប់គ្នាកុំឲ្យចុងដាវផ្ទាប់ជាប់នឹងកខ្លួន រួចជាក់គ្នាដួលផ្កាប់ផ្ងារ ។ មាននួដួលវិញ កាមាស្ទុះទៅចាក់បុកជញ្ជ្រាំពីលើដូចគេរុតត្រី។ តែមាននួគេចឆ្វេងស្តាំ . . . ផុត។ រួចផ្លែដាវទាំងគូមកប្រកួតគ្នាវិញដដែលយ៉ាងស្វិតស្វាញ។

មានន្ទមានវាចាថា៖

- អញទុកចិត្តឯង។ អញជឿសម្បថឯង ព្រោះឯងស្បថឲ្យអញ ឯងមកក្បត់អញវិញ។

កាមាសើច

- ហ៊ឺៗ មនុស្សក្បាលខ្មៅ គ្មានសម្បថឯណា គ្មានពាក្យសច្ចាឯណាធំជាងចិត្តទេ។
- អញប្រដៅឯងឲ្យដឹងបន្តិច!
- ឥតប្រយោជន៍ទេបង ! ខ្ញុំប្រដៅបងឲ្យចេះស្រលាញ់ស្រី កុំឲ្យទុកចិត្តស្រី។
- បើក្នុងពេលនេះ អញសំលាប់ឯងមិនបាន អញសុខចិត្តស្លាប់។
- ប្រាកដហើយ!
- អញយកឈាមឯងលាងអាម៉ាស់ដែលឯងបានប្រព្រឹត្ត។
- តាមចិត្ត!
- អញកាត់ក្បាលឯងដោតឲ្យអ្នកផងមើល។
- តាមត្រូវការ!
- ឯងនេះហៅចំជាព្រហើន!
- ពិតមែន អ្នកណាមិនស្គាល់កាមា ? បងឯងនេះជាមនុស្សយ៉ាប់ណាស់ បានប្រពន្ធមួយ ប្រពន្ធនោះក្បត់ហាស់ៗ ។
- លុះកាមានិយាយដូច្នោះ មានន្ទនឹកខឹងនាងទេវីក្រៃពេក។ រូបនាងលេចចេញនៅចុងដាវ លេចចេញនៅមុខអ្នក ខាំធ្មេញដាក់អ្នក សម្លក់អ្នក រូបនេះញញឹមដាក់អ្នក សំពះអ្នក អង្វរអ្នក។ មានន្ទភ្លេចនឹកដល់អាវុធដែលកំពុងកាន់ ស្រាប់តែ . . . អុ ! ស្រាប់តែចុងដាវរបស់កាមា ស្ទុះរឹតមកបុកចំដើមទ្រូងអ្នក។ បុរសផ្អៀងខ្លួនតែពុំផុត ចុងដាវរុកចូលក្នុងស្មាស្ដាំ ឈាមហូរខ្វាយក្រហមឆ្អៅ។ ចុងដាវធ្វើឲ្យអ្នកចុកពើតក្រៃលែង។ កាមា បានឱកាសនេះវាយផ្ដាច់ព្រ័ត្រ កាប់ឆ្វេងស្ដាំ ពីចំហៀង មានន្ទប្រឹងរងគេចយ៉ាងត្រដរ។ ក្នុងពេលនោះមានន្ទដឹងខ្លួនឡើងថា អ្នកកំពុងតស៊ូដើម្បីរស់ ទើបអ្នកផ្លាស់ដាវមកកាន់ដៃឆ្វេងវិញ ចាក់តទៅទៀត។

កាមាសើចយ៉ាងរីករាយ។

- ម៉េចបង បងថាយកឈាមខ្ញុំ ឥឡូវគឺបងទេដែលហូរឈាម . . . ។
- អត់ទាន់អីទេ ! ប្អូន !

សូរដាវក៏លាន់ឮរន្លើនយ៉ាងខ្លាំងឡើងវិញដដែល។

និយាយពីអ្នកស្រុកដែលដឹកគោបញ្ចូលក្រោល ដើរជិតនោះ កាលបើបានឃើញមានន្ទ និងកាមាប្រកាប់ប្រចាក់គ្នាដូច្នោះ មានសេចក្ដីភិតភ័យយ៉ាងខ្លាំង រត់ទៅភូមិប្រាប់អស់ញាតិមិត្តឲ្យមកជួយជាប្រញាប់។ តែព្រះអាទិត្យលិចបាត់ទៅហើយ។ ពន្លឺព្រះចន្ទក៏បំភ្លឺឡើងស្រាងៗ។ អ្នកស្រុកខ្លះអុចចង្កៀង ខ្លះអុជចន្លុះរត់មកទីសមរភូមិនៃបងប្អូនទាំងពីរនោះ មានចំនួនច្រើនអនេក ។ តែគ្មានអ្នកណាមួយហ៊ានចូលឃាត់សោះ ពីព្រោះដាវទាំងពីរនៅតែប្រកៀកជាប់គ្នាជានិច្ច ។ ដល់ឃើញអ្នកស្រុកមកកាន់តែច្រើនឡើង មានន្ទប្រកិតដាវរបស់កាមាជាប់ រួចនិយាយថា៖

- ចូលប្អូនប្រុងខ្លួនឲ្យមែនទែនហ្នា !
- ខ្ញុំអត់ភ័យទេ បងឯងចាក់ដៃឆ្វេងនោះ!
- ដៃឆ្វេងបង ក៏ប្រើការបានដូចដៃស្តាំ ប្រុងអូន !

ដាវមានន្ទបុករុញៗទៅមុខប៉ាច់ៗ ដូចព្រួញដែលដេញកាមាជាប់។ កាមាភ័យនឹងចុងដាវនេះដែរ ពីព្រោះឃើញថា បងផ្លាស់ស្នៀតថ្មីហើយទម្ងន់ដៃឃើញថា ខ្លាំងជាងធម្មតារកទប់ស្ទើរពុំរួច តែកាមាប្រឹងធ្មក់រកឱកាសល្អ។ ក្រោយមកស្រាប់តែដាវមានន្ទវាត់ក្រឡាច់ចំពាក់កណ្តាលដើមទ្រូង កាមាធ្វើឲ្យកាមាដួលតូង ក្រាបស្រប៉ាបលើដីឈាមហូរគគុក។ កាមាប្រឹងក្រោកឡើងទៀត តែដួលទៅវិញ ។ អ្នកស្រុកលាន់មាត់ស្រែកថា អូយគ្រប់ៗគ្នា។ កាមាប្រែខ្លួនធ្វើអ៊ឹះៗ។ មានន្ទដែលអស់កម្លាំងណាស់ទៅហើយ លុះឃើញកាមាអស់តដៃបាន ក៏ជូតដាវដែលប្រលាក់ឈាម ស៊ កចូលក្នុងស្រោមវិញ ដើរទាំងធេងធោងៗ ទៅរកសេះ។ ដល់ហើយ អ្នកឡើងលើខ្នងអស្សពាហ៍បំបោលទៅខាងទិសឯត្បូងក្នុងងងឹតបាត់ទៅ។

អ្នកស្រុកដែលទៅមើលទាំងប៉ុន្មាន ក៏លើកកាមាឡើង ខ្លះជួយជូតឈាមខ្លះជួយស្រែកហៅ តែកាមាសន្លប់បាត់ស្មារតីយូរណាស់ទៅហើយ ។ អ្នកសួរដោយភិតភ័យថា៖

- ស្លាប់ហើយ ឬអី ?
- ទេ ! មិនទាន់ស្លាប់ទេ!
- របួសតិច រឺខ្លាំង ?
- របួសខ្លាំងណាស់ មិនដឹងជាស្លាប់ ឬរស់ទេ!

អ្នកទាំងអស់គ្នាក៏សែងកាមាយកទៅគេហដ្ឋានព្រះកម្ពុតទាំងយប់ឥតបង្អង់ឡើយ៕

## រឿងមហាចោរនៅទល់ដែនវគ្គទី៩៖រត់តាមប្ដី

### ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

នាងទេវី ដែលដួលសន្លប់ ស្តូកស្តឹងលើគ្រានោះ ក៏បានបើកភ្នែកឡើង។ នាងមើលឃើញ មុខនាងក្ហួង ដែលមានទឹកភ្នែក ហូរហោម។ ជីតាឱបនាងក្ហួងយំ ហើយពោលយ៉ាងរវើរវាយថា៖

- បង ! បង ! បង ! . . . នេះប្អូន !

នាងក្ហួងឃើញដូច្នោះ ខំបមបីស្រីថែមទៀត។

- កូន ! កូន ! នេះម៉ែ ! ម៉ែណា !
- ចាំ៎ះ ! ម៉ែ!
- អី ! នេះម៉ែ!
- ចាំ៎ះ បង ! បងទៅណាហើយ បងគាត់ខឹងខ្ញុំទេ ? ទេប្អូនឥតក្បត់បងទេ ! ប្អូនស្រលាញ់បង នឹកបងណាស់។

នាងភ័យរឹតតែខ្លាំងឡើង ។ ស្ត្រីជាម្តាយញ័រ អស់សព្វសព៌ាង្គកាយ នាងទេវីបិទភ្នែកជិតស្លុង មាត់ចេះតែនិយាយៗទៅ គ្មានដឹងខ្លួនប្រាណសោះ។

- ម៉ែ ! ម៉ែ ! បងគាត់ទៅណាហើយ ? អូ ! ប្រហែលគាត់ខឹងនឹងខ្ញុំមែនហើយ ។ អូ ! គាត់មិនដឹងរឿងទេ . . . ។
- កូន !ទេវី ! កូនមាសម្តាយ ! កូននិយាយអី ដូច្នោះ ? កូន ! កូន !

នាងក្ហួងអង្រួន នាងទេវីយំរឹតតែខ្លាំងឡើង។

- ទេ ! កុំៗ សម្លាប់កូនខ្ញុំអី ! ទុកជីវិតកូនខ្ញុំ ឲ្យរស់នៅសិន ! ហ៊ឺបង! កុំជឿពាក្យគេ។ ទេ . . . កូន . . . លោកឱស ៗ ស្លាប់ខ្ញុំហើយ ! ទេខ្ញុំចង់រស់ . . . !

នាងក្ហួងគ្រវីក្បាល ហួសចិត្ត មិនដឹងគិតយ៉ាងណា ដើម្បីឲ្យកូនសម្លាញ់របស់គាត់ និយាយត្រឹមត្រូវវិញ។

- កូនៗ កុំនិយាយ ! កូនទៅឲ្យស្ងៀម !
- ចាំ ! ខ្ញុំមិនហ៊ាននិយាយទេ ខ្ញុំខ្លាចកូនខ្ញុំស្លាប់។ តែមិនឲ្យខ្ញុំនិយាយឯណាបាន បងគាត់ខឹងនឹងខ្ញុំងាប់ហើយ។ ...បង បង..! បង កុំជឿតាមគេណា ! អាណិតប្អូនទៅ កុំជឿតាមគេ។

ញើសហូរចេញពីថ្ងាសនាងទេវី ផ្លោតៗ ។ នាងក្ហួងយកកូនកន្សែងជូតញើសនោះបណ្តើរ និយាយបណ្តើរ៖

- ឱ! ព្រះម្ចាស់ថ្លៃអើយ ! សូមជួយកូនខ្ញុំផង កុំឲ្យកូនខ្ញុំនិយាយច្រើនពេក ។ កូន ៗ ! កូនសម្ងំឲ្យលក់ទៅ ។
- ចាំ៎ះ !
- អឺ ! កូននៅឲ្យស្ងៀមកុំនិយាយអី ។
- ចាំ៎ះ !

- បើកូនស្លាប់ ម៉ែក៏ស្លាប់ដែរ ។
- ចាះ !
- កូនមិនស្លាប់ទេ ព្រោះមានម៉ែ ។
- ចាះ !

មួយស្របក់ក្រោយមក នាងទេវីក៏ដេកលក់ ស្កប់ស្កល់។ ដល់នាងភ្ញាក់ឡើង ធីតាហាក់មានកម្លាំងកំហែង។ កល្យាណក្រោកដើរទៅមុជទឹក រួចទើបនិយាយ ទៅកាន់នាងភួងទៀតថា៖

- ម្ដាយអើយ ! ក្នុងជាតិនេះ កូនអភ័ព្វណាស់ ។ បងមានន្ទមកទីនេះ អំបាញ់មិញ។ កូនមិនហ៊ានមើលមុខបងទេ ពីព្រោះអាកាមា វាសម្លាប់កូនរបស់ខ្ញុំ។ ម្ដាយមាសម្ដាយ ! បើម្ដាយឃើញបទុមកូនខ្ញុំ ម្ដាយមុខជាស្លាប់មិនខាន។ អាកាមា វាឲ្យមនុស្សអសិរពិសម្នាក់ យកដាវដាក់ចំកកូនខ្ញុំ ដើម្បីបង្ខំកុំឲ្យខ្ញុំនិយាយអ្វី ធ្វើអ្វី។ ក្នុងពេលនោះ អាកាមា វាបង្កាច់ថាខ្ញុំនឹងវា សហាយគ្នា។ ឱ អ្នកម្ដាយ ! កូនស្លាប់តែក្នុងថ្ងៃនេះឯង ជាប្រាកដហើយ។ កូនឈឺចិត្តណាស់ អាកាមាវាធ្វើបាបកូនដល់ហើយ . . . ។ ឱ! ឥឡូវកូនខ្ញុំទៅណា បាត់ពីបង្អួចនោះហើយ . . .? អំបាញ់មិញ ខ្ញុំមើលឃើញកូនខ្ញុំ ពីទីនេះទៅ។ វាយកកូនខ្ញុំ ទៅទៀតហើយ។ កូនខ្ញុំដេកលក់ គ្មានដឹងថាជីវិត នៅនឹងចុងដាវគេទេ មានតែខ្ញុំទេ ដឹងភ័យ ស្រៀវ ទុក្ខ ។ នាងដេកលក់ ព្រងើយ។ ឯខ្ញុំ ស្ទើរស្លាប់ខ្លួន។ ឱ! ម្ដាយអើយ ! កូននឹករលឹកបងមានន្ទខ្លាំងណាស់។ កូនប្រុងកាយប្រុងចិត្តថា កូនផុតទុក្ខ ថ្ងៃនេះហើយ។ តែឥឡូវ កូនរឹតតែមានទុក្ខទៅទៀត កូនឃើញគេមក កូនស្ទើរស្ទុះទៅឱបជើងគេ ។ កូនឃើញតែជើងគេទេ។ កូនឥតបានឃើញមុខគេទេ។ គេខឹងនឹងកូនហើយ។ គេនិយាយមករកកូនដែរ តែកូនពុំហ៊ានឆ្លើយ។ គេគំហកកូន តែកូននឹកថា បើគ្មានអាកាមាទេ គេគំហកយ៉ាងណា ក៏កូនមិនថាដែរ កូនមុខជាឲ្យគេគំហកតាមចិត្ត ឲ្យតែកូនបានឮសម្លេងគេ បានស្ដាប់សម្ដីគេ ទោះសម្ដីនោះ ទ្រគោះបោះបោកយ៉ាងណាក៏ដោយ។ ម្ដាយអើយ ! ហេតុតែកូនស្រលាញ់គេ។ ឥឡូវគេមិនដឹងរឿង គេទៅបាត់ ទុកតែស្នាមជើងនៅទីនេះ។ កូនសូមថើបធូលីជើងគេហើយ អ្នកម្ដាយកុំថាឲ្យកូន កុំសើចកូន។ ចាះ ! កូនថើប ដោយឥតអៀនខ្មាសទេ។ ឥឡូវកូនក៏បាត់ ប្ដីបាត់ តើឲ្យកូនទៅណា? ធ្វើអ្វី ?គិតអ្វី? កូនអស់រលីងហើយ។ អ្នកម្ដាយៗ ជួយគិតគូរកូនផង។ ឱ ! . . . !

ក្នុងពេលនោះ មនុស្សម្នាក់ មាឌមាំ អាយុប្រមាណហាសិបប្លាយឆ្នាំ ចូលមក បីកូនមកផង។ នាងទេវីស្គាល់ជាក់ ជាកូនខ្លួន ក៏ស្ទុះរត់មកលុតជង្គង់ ពីមុខបុរសពុំស្គាល់នោះ លាតដៃទាំងពីរ . . . ។ បុរសអង្គុយចុះ ទឹកមុខញញឹម ហុចកូនទៅឲ្យនាង។

- លោក ៗ កូនខ្ញុំមែនទេ?
- បាទ ! កូននាងហើយ !
- ឱ! ព្រះម្ចាស់ថ្លៃអើយ ! កូនខ្ញុំមែន !
- ខ្ញុំលួចគេយកមកជូននាងវិញ។
- ចាះ ខ្ញុំសូមអរគុណលោកណាស់ វាលាក់កូនខ្ញុំឯណាលោក ?
- មិនសំខាន់ទេ សំខាន់ត្រង់ខ្ញុំយកកូនមកជូននាងវិញ។

- ចាំះ ! លោកខ្ញុំអរគុណលោកណាស់ រកអ្វីមកប្រៀបគ្មានទេ។ ឱ ! លោកហៅ ចំជាមានគុណនឹងខ្ញុំមែន តែខ្ញុំក្រណាស់ លោក

ចង់បានអ្វីពីខ្ញុំ ឲ្យតែខ្ញុំមាន ខ្ញុំជូនលោកទាំងអស់។

- ទេ ! ខ្ញុំធ្វើនេះឥតមានចង់បានអ្វីពីនាងទេ។
- ចាំះ ! ចាំះ ! លោកមានចិត្តអ្វីល្អម្ល៉េះទេ។ លោកឈ្មោះអី ? នៅឯណា ? ដើម្បីឲ្យខ្ញុំបានដឹង ឲ្យខ្ញុំបាននឹកគុណអស់មួយ

ជីវិតខ្ញុំ។

- ខ្ញុំជាមនុស្សឥតឈ្មោះ ឥតទីលំនៅ ឥតគ្រួសារទេ . . . ។
- ហ៊ី ! លោកកុំខ្លាចខ្ញុំ កុំលាក់ខ្ញុំ ប្រាប់ខ្ញុំមក!
- ទេ ! ខ្ញុំឥតខ្លាចអ្វីទេ គឺជាការពិតដូច្នោះឯង។
- ចាំះ ! លោកជាមនុស្សអីប្លែកម្ល៉េះទេ។
- បើដូច្នោះ កិច្ចខ្ញុំសម្រេចហើយ ខ្ញុំសូមលាអ្នកហើយ។
- ចាំះ ទេ ! សូមចាំអញ្ជើញពិសាបាយ នឹងខ្ញុំសិន។
- បាទទេ ! ខ្ញុំសូមអរគុណណាស់ហើយ។ ខ្ញុំមានការប្រញាប់បន្តិច ។
- ហ៊ី ! លោកមានការអ្វី ?
- ការផ្ទាល់ខ្លួន។ ខ្ញុំសូមលាអ្នក សូមអ្នកនៅឲ្យសុខសប្បាយណ៎ា !
- ចាំះ ! លោកអញ្ជើញទៅណាមកណា សូមអាណិតចូលលេងផ្ទះខ្ញុំផងកុំខាន។
- បាទ ! អរគុណនាងណាស់!
- ចុះលោកស្គាល់ប្ដីខ្ញុំទេ ?
- បាទស្គាល់ តែឥឡូវអ្នកស្រុកប្រាប់ថា ឈ្លោះគ្នាយ៉ាងខ្លាំងជាមួយមេទ័ពកាមា ចាក់គ្នាឯវាលស្រែឯណោះតាំងពីល្ងាចម្ល៉េះ រួចកាមាក៏ចាញ់ទៅ។ ឥឡូវ ឮថាជិះសេះទៅខាងត្បូង បាត់ទៅហើយ។ មិនដឹងជាទៅណាផង។
- តាមស្មានប្រហែលទៅណា ?
- ប្រហែលទៅបាត់ដំបង!
- ឱ ! ចាំះ សូមអរគុណលោកហើយ អញ្ជើញចុះឲ្យសុខសប្បាយ ឲ្យមានជ័យជំនះឈ្នះអស់មារ សត្រូវៗទាំងប្រាំបីទិស។

មនុស្សមិនស្គាល់មុខនេះ ក៏លោតលើខ្នងសេះទៅបាត់ទៅ។ នាងទេវី ក៏ក្រសោបបុត្រីថើប។ នាងនិយាយថា៖

- កូនៗ ! ម្ដាយនឹកកូនណាស់ ម្ដាយស្មានតែពុំបានជួបមុខកូន ពុំបានឃើញកូនទៀតទេ ។ កូនកុំដេកអី ភ្ញាក់ឡើង។

នាង បទុមក៏ភ្ញាក់ ដោយនាងទេវីញាក់ញ័រខ្លាំងពេក។ នាងសើចគ្រហាញដាក់ម្ដាយ ដែលធ្វើឲ្យនាងទេវី រឹតតែសប្បាយចិត្តទៅ ទៀតនាងយំបណ្ដើរផង។

- កូន ! កូនអត់ត្រូវគេធ្វើបាបអ្វី ទេឬ? កូននៅសុខសប្បាយទេ ? ម្ដាយមិនស្មានដូច្នោះសោះ នឹកខុសថាប្រហែលគេញាក់ញី អារ

សាច់ ហុតឈាមទៅហើយ។ ម្ដាយយំខ្លាំងណាស់ប៉ុន្មានថ្ងៃនេះ។ ទៅកូន ! ទៅជាមួយម្ដាយ ទៅរកឪពុកកូនឯងទៀត។

ថាដូច្នោះហើយ នាងទេវីរកកន្សែងដណ្ដប់ឲ្យនាងបទុម រួចប្រាប់នាងក្លូងថា៖

- ម៉ែ ! ចាំផ្ទះណា ខ្ញុំទៅរកបងមានន្ទមួយភ្លែត ។ សុំកុំឲ្យម៉ែ ទៅណាចោលផ្ទះឲ្យសោះ។

ថាហើយ នាងទេវីឱបបុត្រីជាប់នឹងដើមទ្រូង បើបកូនបណ្ដើរ រត់ទៅមុខបណ្ដើរ។ នាងតម្រង់ទៅ គេហដ្ឋានព្រះកម្ពុត ទាំងកណ្ដាលរាត្រី។ ធីតាលែងនឹកខ្លាច លែងនឹកនាអ្វីទៀតហើយ។ នាងរឹករាយក្រៃពេក ស្រីឆោមឆ្លងកាត់ផ្នូរខ្មោច តែនាងឥតដឹងខ្លួនសោះ។ ញើសនាងហូររហាម តែនាងឥតគិត មកដល់សោះ។ មុខនាងឱន តែទៅលើមុខបុត្រី របស់នាង ដែលនាងព្រាត់យូរមកហើយ។

លុះមកដល់ភូមិស្វាយ នាងស៊ើបសួរគេរកប្ដីនាង។ គេប្រាប់តាមដំនើរ ដើមទង។ កញ្ញាឱបកូន រត់តាមទៅទៀត។ កល្យាណតម្រង់ ទៅខាងស្រុកមង្គលបុរី ដែលសព្វថ្ងៃ មានចម្ងាយប្រាំបួនគីឡូម៉ែត្រ ពីភូមិស្វាយ។ យប់ងងឹតស្លុង។ ធរីទៅតាមផ្លូវរទេះ ប៉ះជន្លង់ឈើ ព័ន្ធជើងដួល ធីតាក្រោកឡើង រត់ទៅទៀត ដើម្បីឲ្យទាន់សេះរបស់មានន្ទជាប្ដី បន្តិចមក មានសេះមួយ បំផាយមកពីក្រោយនាង។ អ្នកជិះសេះស្រែកសួរថា៖

- អ្នកណាហ្នឹង ?
- ចា៎ះ ! ខ្ញុំលោក ឱ ! លោកដ៏មានគុណឬ ?
- ចុះនាងអញ្ជើញទៅណា មកណា ទាំងយប់ដូច្នេះ ?
- ចា៎ះ! ខ្ញុំទៅតាមប្ដីខ្ញុំ។ គេថាប្ដីខ្ញុំ ទៅតាមផ្លូវមង្គលបុរីនេះឯង។
- យីនាងមិនខ្លាចទេ ?
- ចា៎ះ ! ទេខ្ញុំមិនខ្លាចទេ។
- មានខ្លាណា៎ តាមផ្លូវ !
- ចា៎ះ ! ខ្ញុំមិនខ្លាចខ្លាទេ។
- នាងរត់ម្ដេចទាន់ បើគេជិះសេះ នាងដើរដូច្នោះ !
- ខ្ញុំទាន់ត្រឹមណា ឈប់ត្រឹមនោះ។
- យើយកសេះខ្ញុំជិះទៅ។
- ឱ! ចា៎ះទេ ! អរគុណសោកណាស់ លោកមានគុណនឹងខ្ញុំណាស់ . . . ខ្ញុំទៅហើយ ។

- ឈប់សិន និយាយគ្នាឲ្យអស់សិន។
- ចាំះ ! អត់ទោសខ្ញុំប្រញាប់ណាស់។ លោកអញ្ជើញទៅចុះ កុំគិតដល់ខ្ញុំ។

បុរសជិះសេះប្រឹងជំរត់សេះ ឲ្យទាន់ធីតាកម្សត់ ដែលពុំព្រមឈប់និយាយសោះ។

- អ្នកមានស្គាល់គេទេ ឯមង្គលបុរីនោះ ?
- ចាំះ ទេ!
- ចុះ ឯបាត់ដំបង ?
- អត់ស្គាល់អ្នកណាទេ។
- យី ! បើដូច្នោះ អ្នកអញ្ជើញទៅផ្ទះអ្នកណា ? បើរកប្ដីអ្នកមិនឃើញ ?
- ចាំះ ! មិនអីទេ ខ្ញុំទៅនៅត្រង់ណាក៏បានដែរ។
- មិនបានទេ ! មិនបានទេ ។ អ្នកមានប្រាក់កាស ជាប់ខ្លួនទេ ?
- ទេខ្ញុំអត់ប្រាក់ទេ។

បុរសចម្លែកនេះ លុះបានឮដូច្នោះ ក៏លូកថង់យាម បោះប្រាក់មួយថង់ធំ មកឲ្យនាង។ នាងទេវី លុះដឹងថាប្រាក់ ក៏ប្រឹងរត់តាមសេះ ហើយស្រែកថា៖

- ទេៗ លោកៗ យកទៅវិញចុះ។

តែអ្នកជិះសេះ បំផាយយ៉ាងលឿន ទៅបាត់ទៅ។

នាងទេវី ឃើញប្រាក់នោះ ប្រាំណែន។ ធីតា មានសេចក្ដីអរគុណ នឹងបុរសមិនស្គាល់មុខនេះ ជាអនេកកប្បការ។ លុះដល់មង្គលបុរី នាងទេវី ដើរពីផ្ទះមួយទៅផ្ទះមួយ រកប្ដី តែគេបិទទ្វារដេកលក់អស់។ នាងឃើញផ្ទះមួយ នៅពុំទាន់បិទទ្វារ។ ចង្កៀងប្លុងៗ នាងរត់តម្រង់ទៅសួរគេ ៗឆ្លើយថា៖

- អំបាញ់មិញនេះ មានមនុស្សជិះសេះម្នាក់ មកសុំទឹកផឹក មនុស្សនោះរបួសផង ប្រហែលមានរឿងអ្វី ជំដុំហើយមើលទៅ។
- មនុស្សនោះទៅណាហើយមីង ?
- ចាំះ ! ខ្ញុំសួរ គេថា គេមានការ ទៅបាត់ដំបងទាំងយប់ នេះឯង។ ខ្ញុំឃាត់ដែរ តែគេពុំព្រមនៅសោះ។
- ទៅយូរហើយឬអ្វី ?
- ចាំះ ! ទេ ! ទើបនឹងទៅអំបាញ់មិញនេះឯង។
- ខ្ញុំអរគុណហើយមីង ខ្ញុំសុំទឹកមួយផ្តិលដែរ។
- យី ! តើនាងពកូនទៅណា ? ម្ចាស់ម្ដាយអើយ !
- ចាំះ ! ខ្ញុំអត់ទៅណាទេ!
- អ្នកជិះសេះនោះ ត្រូវជាយ៉ាងម៉េចនឹងនាង ?
- ចាំះ ខ្ញុំចង់ជួបគេមានការបន្តិចបន្តួចទេ។
- នាងនៅឯណា ?

- ខ្ញុំនៅស៊ីសុផុន។
- អូ ! ចុះមកធ្វើអ្វីទាំងយប់ម្ល៉េះ ?
- ខ្ញុំមានការរកអ្នកមីង!
- យី ! ខ្ញុំសូមអរគុណអ្នកមីងណាស់ហើយ ។ ខ្ញុំសុំលាអ្នកមីងហើយ។
- ចាំះ ! លើកដៃថ្វាយព្រះ ចុះនាងទៅណាទៀត ?
- ខ្ញុំទៅមុខទៀត!

នាងទេវីបានទឹក ក៏ផឹកក្អឹកៗ រួចលាមីងនោះរត់ទៅទៀត។ កល្យាណ ហាក់ដូចជាមានកម្លាំងឡើងវិញ សាយពេញខ្លួន។ នាងបែកញើសសស្រាក់ ត្រជាក់អស់ទាំងខ្លួន។ លុះរត់មួយសន្ទុះទៅ នាងឮសូរជើងសេះ នាងស្រែកហៅះ

- បង ! បង ! ចាំខ្ញុំផង បងមានន្ទ . . . បងមានន្ទ !

គេឮសូរ តែមាត់នាង ដែលអណ្តែតទៅក្នុងព្រៃស្ងាត់បាត់ឈឹង គ្មានឮសូរអ្វី ឆ្លើយមកវិញឡើយ។ រីឯជើងសេះ ក៏លាន់ឮកាន់តែល្វើយទៅៗ លុះត្រាតែបាត់សូន្យជាអចិន្ត្រៃយ៍។

ពីរថ្ងៃក្រោយមកទៀត នាងទេវី និង បុត្រីបានដើរទៅជិតអ្នកលក់បន្លែម្នាក់ នៅទីផ្សារបាត់ដំបង។ នាងដើរតាមស៊ើបសួរ រកប្តីនាង តែមិនលេចឮដំណឹងអ្វីសោះ។ នាងដើរតាមសំយាបផ្ទះចិន តាមរោងចក្រផ្សេងៗ តាមរោងលក់ម្ហូបអាហារ ចំនី តាមផ្ទះអ្នករាជការ តូច ធំ គយគន់ រកមើលគូកម្សត់។ ជីតាពកូនយំបណ្តើរ ដើរបណ្តើរ តែរាល់ថ្ងៃដូច្នោះឯង៕

រឿងមហាចោរនៅទល់ដែនវគ្គទី១០៖ស្តេចខ្វាល់

## ដោយសព្វវចនាធិប្បាយសេរីគីគីឌា

ល្ងាចថ្ងៃ ដែលមានការវិវាទ រវាងមានន្ទ និង កាមានេះ ព្រះកម្ពុតជាបិតា ពុំបានទៅណាទេ។ នៅក្នុងដំណាក់ គេឮសូរ តូរ្យតន្ត្រីរងំ។ យូរៗ ចម្រៀងកញ្ញាម្នាក់ លាន់ឮឡើងគ្រលួច រួចគឺសូរមាត់អ្នកសើចហ៊ោកញ្ជៀវ សប្បាយ។ ព្រះកម្ពុត លង់ក្នុងសេចក្តីសប្បាយ នេះឯង។ អង្គុយលើកៅអីដាំត្បូង ទ្រង់សំលៀកបំពាក់មួយ ដ៏ល្អឆើតឆាយ ព្រះកម្ពុតទះដៃ សើចក្អាកក្អាយ ពីមុខស្រី ដែលរេរាំយ៉ាងស្រស់អស់ពីចិត្ត។ ក្នុងនោះ ទាហានម្នាក់ចូលមក ព្រះកម្ពុតរាដៃ ឲ្យពួករបាំឈប់។ របាំក៏ឈប់ស្ងាត់សូន្យ ។ អ្នករាំក៏លបៗ ចូលទៅកៀន។ ព្រះកម្ពុត ឱនសួរទៅទាហាន ដែលឈរត្រង់ខ្លួន នៅពីមុខលោកថាះ

- មានការអ្វី ?
- ព្រះបាទម្ចាស់ កាមាត្រូវរបួសជាទំងន់។

ព្រះកម្ពុតឮចំលើយយ៉ាងនោះ បើកភ្នែកធំៗ ញេញធ្មេញសួរតទៅទៀតថាះ

- រឿងអី វានៅឯណា ?
- ព្រះបាទម្ចាស់នៅខាងមុខ មានរឿងជាមួយមានន្ទ។

- យី ! ឯណា ជូនអញទៅ

ព្រះកម្ពុតក៏ដើរចេញពីកៅអីកិត្តិយស ដោយមានទាហានអមទាំងសងខាង ចេញទៅផង។ អ្នកភ្លេង អ្នករាំទាំងប៉ុន្មាន ឆ្ងល់នឹងរឿងនេះក្រៃពេក តែពុំមានអ្នកណាមួយ ហ៊ានមាត់កអ្វីឡើយ។ លុះដើរទៅដល់ ឃើញជាក់ជាកាមាមែនហើយ ព្រះកម្ពុតមានទឹកមុខឡើងក្រហម លោកបញ្ជាដូចតទៅៈ

- យកវាទៅថែរក្សាទៅ ! ទៅឆាប់ ៗ!

សេនាជំនិតទាំងអស់ ក៏គ្រាហ៍កាមាយកទៅ។ ព្រះកម្ពុតដកដង្ហើមធំសម្លឹងទៅក្រៅ ឃើញមនុស្សម្នាក់ក្មេង មុខកាចសក់រួញ ក៏ហៅបុរសនោះ ឲ្យចូលមក។

- និលៗ ឯងដឹងរឿងរ៉ាវអ្វីទេ ?
- ព្រះបាទម្ចាស់ ដឹងខ្លះដែរ។
- អាមានន្ទ និង អាកាមា វាមានរឿងអីនឹងគ្នា ?
- ព្រះបាទម្ចាស់មានរឿងពីស្រី។
- ស្រី ? ស្រីអី?
- មានន្ទមានប្រពន្ធមួយ ឈ្មោះនាងទេវី កាមាក៏ស្រលាញ់នាងនេះដែរ។
- ទេវី ? កូនវិសេសក្លាហាន ដែលទើបស្លាប់ទៅនោះឬ ?
- ព្រះបាទម្ចាស់!
- អាមានន្ទ វាការគ្នាពីកាលណា ?
- បាទទានប្រោស ការរួចប្រហែលមួយឆ្នាំហើយ។
- យី ! អានេះ ចិត្តធំមែន ! ចុះអាកាមា ម្តេចក៏វាស្រលាញ់នាងទេវីដែរ ?
- ព្រះបាទម្ចាស់ស្រលាញ់ដែរ។
- ស្រលាញ់មុន ឬ ក្រោយអាមានន្ទ?
- ព្រះបាទម្ចាស់ស្រលាញ់ក្រោយទេ។
- រួចវាដណ្តើមគ្នា ?
- ព្រះបាទម្ចាស់ ប្រហែលដូច្នោះហើយ បានជាកាប់គ្នាថ្ងៃនេះឯង។
- ហ៊ឺ ! គិតទៅកូនៗ វាមើលងាយឯងមែន។ អាអស់នេះ សមតែកាត់ក្បាលវាចោល។ អាកាមាចុះវានៅក្មេង ចុះអាមនន្ទក្បាល

កញ្ចាស់ ក៏វាព្រើលដែរ រួចវាស្រលាញ់អ្នកណាមិនស្រលាញ់ ទៅស្រលាញ់មីទេវី កូនអាចង្រៃវិសេសក្លាហាន នោះទៀត។ ហ៎ា ៗ! វាដឹងថាអញស្អប់វិសេសក្លាហាន រួចវាស៊ុមគ្រលុំគ្នាមិនប្រាប់អញ។ តើឥឡូវ អាមានន្ទវាទៅណាហើយ ?

- ព្រះបាទម្ចាស់ ឮថា ជិះសេះទៅខាងមង្គលបុរី។

- យើ ! អានេះរត់ហើយតើ។ វាដឹងខ្លួនវាហើយ ។ ទៅនិលឯងយកទាហាន ១២នាក់ជិះសេះ ទៅចាប់វាចង នាំមកឲ្យខ្ញុំ យ៉ាងប្រញាប់។
- ខ្ញុំព្រះបាទសុំចុតហ្មាយ ទានប្រោស។
- អើ ៗ !
- ព្រះកម្ពុតសរសេរចុតហ្មាយដូចតទៅ៖

ចុតហ្មាយឲ្យចាប់ខ្លួន
យើងព្រះកម្ពុត ចៅហ្វាយខេត្តសិរីសោភ័ណ បង្គប់ឲ្យមេកងនិល ពេជ្រ ចេញមកចាប់មេទ័ពមានន្ទ។
បើឈ្មោះនេះរឹងទទឹង និលពេជ្រអាចសម្លាប់ចោលបានពេញច្បាប់។
ព្រះកម្ពុត

លុះសរសេររួចហើយ ព្រះកម្ពុតហុចលិខិតឲ្យទៅនិលពេជ្រ ដែលគេតែងហៅ មេកងនិលៗ ប៉ុណ្ណោះឯង។ ព្រះកម្ពុតបន្ថែមថា៖

- ទៅចាប់អាមានន្ទឲ្យប្រុងប្រយ័ត្នបន្តិច ព្រោះដូចឯងដឹងស្រាប់ហើយ វាក្លាហានណាស់។
- ខ្ញុំព្រះករុណាធ្វើតាមបន្ទូល ទាន។
- តែនិលពេជ្រឯងក៏ជាជើងឯកមួយដែរ បានជាអញបញ្ជូនទៅនេះ។
- សូមព្រះតេជគុណទុកចិត្តលើខ្ញុំបាទចុះទាន ។ ខ្ញុំបាទសូមរើសយកពលណា ដែលធ្លាប់មានថ្វីដៃបំផុតទៅជាមួយ។
- អើ ! រើសចុះតាមចិត្ត ទាំងសេះ ទាំងមនុស្ស គ្រឿងប្រដាប់ ឲ្យគ្រប់គ្រាន់ណា។
- ព្រះបាទម្ចាស់។

និលពេជ្រ ក៏គំនាប់ព្រះកម្ពុត ហើយស្ទុះចេញទៅ។ ក្នុងពេលនោះ មនុស្សម្នាក់ចាស់ អាយុប្រមាណហុកសិបប្លាយឆ្នាំ តែមាឌនៅរឹងប៉ឹង ដូចក្មេងអាយុម្ភៃឆ្នាំ ចូលមកដល់។ គាត់ចាប់អាវនិលពេជ្រ រួចនិយាយថា៖

- ទៅណា ?
- បាទ ! ព្រះតេជគុណ ឲ្យទៅចាប់មានន្ទ លោកតា។
- ចូលមកវិញ និយាយគ្នាសិន។
- បាទ !

មនុស្សចាស់នេះមានទឹកមុខមាំ ចូលមកដល់ព្រះកម្ពុត ព្រះកម្ពុតឃើញ ក៏ឲ្យអង្គុយកៅអីដោយគួរសមយ៉ាងគោរព ។ តែមនុស្សចាស់នេះ ទាញកៅអីក្រាក ដោយគំរិះគំរុះ ទៅកៀនជញ្ជាំង មុខបែរទៅរកបង្អួច ឥតមើលមុខព្រះកម្ពុតឡើយ ។ ព្រះកម្ពុតប្រឹងពន្យល់ ថា៖

- សូមលោកជ្រាប គួរអីព្រហើនម្ល៉េះ ?

- ព្រហើនអី ?
- បាទ ទាន ! វាលួចការប្រពន្ធឥតឲ្យខ្ញុំដឹង។
- ដឹងទៅបានការអី ?
- បាទទេ ! ខ្ញុំជាឪពុកវា គួរតែវាប្រាប់ខ្ញុំមុននឹងសម្រេចការអ្វីនីមួយៗ។
- វាដឹងថា លោកមិនធ្វើតាមវាពិត បានជាវាមិនប្រាប់ ។ ឈប់និយាយ ! ចុះឥឡូវលោកធ្វើអ្វី ?
- ខ្ញុំឲ្យទាហានទៅចាប់វាមក។
- លោកជាឪពុក លោកធ្លាប់ស្គាល់ខ្ញុំជានិច្ចរៀងដរាបមក។ ខ្ញុំស្រលាញ់លោកចិត្តមួយ ថ្លើមមួយ។ ខ្ញុំចាស់ហើយ តែខ្ញុំធ្លាប់កប់

ប្រទះ នឹងរឿងរ៉ាវច្រើនណាស់ ខ្ញុំដឹងរឿងអស់នោះ ។ ខ្ញុំជាទីប្រឹក្សា របស់គ្រប់ចៅហ្វាយខេត្តទាំងអស់ ដែលមានចំនួនបួននាក់ មកហើយ គឺ មានលោកនេះជាក្រោយបង្អស់។ ខ្ញុំសូម កុំឲ្យលោកចាត់ទៅចាប់វា ធ្វើអ្វី។ តាមខ្ញុំយល់ គឺគួរបង្រួញរឿងនេះ ឲ្យខ្លី កុំពង្រីក ឲ្យវែងទៅៗ នោះ។

- ចុះ ឲ្យខ្ញុំធ្វើយ៉ាងណាវិញ ?
- មានន្ទវាមានទៅណា វាជាកូនលោកស្រាប់ តែបន្តិចទៀតវាមកវិញហើយ។ ចាំបាច់ទៅព័ទ្ធចាប់វាធ្វើអ្វី ?
- សូមទោស គិរីមេរុ ឥឡូវព្រះកម្ពុត ចាត់ការនេះហើយ ព្រះកម្ពុតមិនអាចដកពាក្យទេ ។ ខ្ញុំស្តាប់លោកជានិច្ច ខ្ញុំគោរពលោក

ជានិច្ច តែក្នុងពេលនេះ ខ្ញុំត្រូវតែផ្តន្ទាទោសអាមានន្ទ ឲ្យអស់ចិត្តខ្ញុំខឹង។ ខ្ញុំខឹងណាស់ សូមប្រាប់លោកឲ្យត្រង់។ ទៅ និលពេជ្រទៅ!

និលពេជ្រ ក៏ចេញទៅតាមពាក្យព្រះកម្ពុត។ តាគិរីសុមេរុ ពេបមាត់ សម្លឹងមើលក្តារ ឥតនិយាយមួយមាត់។ តាគិរីសុមេរុនេះ ជាអ្នកចម្បាំងជើងចាស់ ដែលរស់ប្រាំរាជស្តេច មកហើយ។ គាត់គ្មានខ្លាចអ្នកណាទេ ទោះព្រះកម្ពុត ក៏គ្មានខ្លាចដែរ។ តែព្រះកម្ពុត គោរពគាត់ជាចាស់ទុំដរាប។ កាលព្រះកម្ពុតនៅក្មេង គាត់បានចិញ្ចឹមបីបាច់រក្សា រួចក្នុងសង្គ្រាមនានា គាត់បានជួយជីវិតព្រះកម្ពុតនេះ ឲ្យរួចពីក្តីមរណៈ ជាច្រើនលើក ច្រើនគ្រា។ ដើម្បីតបស្នង សងគុណតាគិរីសុមេរុវិញ ព្រះកម្ពុត បានអញ្ជើញគាត់ ឲ្យមកនៅជាមួយ។ គិរីសុមេរុ ជាមនុស្សមានបញ្ញាវៃឆ្លាត ហើយពូកែស្ទិតស្ទាញ ខាងកាន់គ្រឿងអាវុធ រកអ្នកណាមួយ ប្រៀបផ្ទឹមពុំបានឡើយ។ គិរីសុមេរុ ក្រោកឈរច្រានកៅអីដួលផ្កាប់ផ្ងារ រួចដើរចេញទៅខាងក្រៅ។ ព្រះកម្ពុតមានសេចក្តីបារម្ភ នឹងអាកប្បកិរិយានេះដែរ តែដឹងចិត្តតាគិរីសុមេរុ ...។ ទោះជាយ៉ាងណា ក៏បុគ្គលនេះ ជាមនុស្សផុតចាប់ទោស អួសដំណើរដែរ។ ព្រះកម្ពុតមុខឡើងស្លាំងអង្វរថា៖

- អញ្ជើញលោកតាពិសាតែសិន!

គិរីសុមេរុស្រលាញ់មានន្ទណាស់ ហេតុនេះហើយបានជាគាត់ មិនចង់ឲ្យព្រះកម្ពុត តាមរកមានន្ទនោះ។ លុះដើរចេញមក ដល់ក្រោបន្ទាយ គាត់ក្រលេកមើលនាយអាយ រួចស្ទុះទៅចាប់ស្មានាយកោប ជាប់ពីក្រោយ។

- លោកតាៗ ! សួស្តីលោកតា !
- អាចំកួត មានន្ទទៅណាហើយ ?

- បាទ ! ខ្ញុំបាទមិនដឹងដែរ។
- ចុះម្ដេចអាឯង នៅប៉ែលប៉ោលទីនេះទៀត ?
- ឲ្យខ្ញុំធ្វើយ៉ាងណាលោកតា ?
- អាឯងឆ្កួត ឬជា ?
- បាទ ! ជាលោកតា!
- អាឯងស្រលាញ់មានន្ទ ទេ ?
- ស្រលាញ់ដែរ!
- មានន្ទមានទុក្ខ ម្ដេចអាឯងសប្បាយនៅនេះ?
- បើដូច្នេះ ខ្ញុំទៅរកឥឡូវ។
- អើ ! ទៅ ! ទៅប្រាប់វាថា គេតាមចាប់ ឲ្យប្រយ័ត្នខ្លួន ...។
- បាទ !
- ឯងដឹងមានន្ទនៅឯណាទេ ?
- ទេ !
- បើឯងមិនដឹងធ្វើម្ដេច ទៅរកឃើញ ?
- ការនេះស្រេចនៅលើខ្ញុំ ខ្ញុំជ្រែកដីរាវទឹក កកូរអាកាសរកទាល់តែឃើញហ្នឹង។ យ៉ ! វាទៅណា កំបាំងភ្នែកអាកោប។

គិរីសុមេរុ សើចទះស្មានាយកោបះ

- ប្រយ័ត្នតែឯងមិនឃើញវិញ តើឲ្យអញធ្វើម៉េច ?
- ឲ្យពុះក្បាលកោបជាប្រាំពីភាគ។
- បីភាគបានទេ ?
- តិចណាស់ មិនស្លាប់កោបទេ កោបធ្លាប់ទទួលបួនរួចមកហើយ ៗឥតអី។
- បើដូច្នោះ អញសុំតែមួយសិនបានទេ ?
- គ្នាឯង អ្នកណាដែលឲ្យលេងអញ្ចឹង។
- អាកោប អញសួរឯងបន្តិចបានទេ ?
- បាន ! យី ! លោកតាសួរចុះ សួររឿងព្រះ ឬរឿងជាតិ ឬរឿងព្រះឥសូរ ...។
- អើ ! កាលណាបានឯងយកប្រពន្ធ ?
- ដល់លោកតាយក បានខ្ញុំយកដែរ។
- ហាស ៗ អាចំកួត!
- ទៅគិតអីរឿងប្រពន្ធកូននោះ?
- ចុះឯងគិតអីវិញ ?
- រឿងជាតិ!

- អូ ! អាខ្មោច លោជា ឯងចេះគិតពីរឿងជាតិដែរ។
- យី ! សិស្សមានន្ទណ៌ា ខ្ញុំ!
- ឱ ! ឯងចេះគិតជាតិ ព្រោះឯងជាសិស្សគេទេឬ ?
- ឱស ៗ តែ ខ្ញុំគិតរឿងជាតិ ព្រោះខ្ញុំជាខ្មែរ។
- បើអញ្ចឹងទៅចុះ!

នាយកោបហួច ឮសូររើតៗ។ សេះមួយ កញ្ឆៀវឯចម្ងាយ។ មិនយូរប៉ុន្មាន សេះនេះលូនមកដល់ ពីមុខនាយកោបភ្លាម ដែលស្ទុះទៅយកអាន និង បង្ហៀរមកដាក់ ដោយរួសរាន់។ តាគិរីសុមេរុឃើញយ៉ាងនេះ មានចិត្តស្ញើចនាយកោបមួយអន្លើដែរ តែពុំចេញស្តីអ្វី ឲ្យវាដឹងចិត្តគាត់ឡើយ។ នាយកោបស្ទុះលោតភ្លែត ឡើងលើខ្នងសេះ គំនាប់តាគិរីយ៉ាងគួរសម រួចបំផាយសេះ ទៅខាងទិសមង្គលបុរី ទៅ។ តាគិរីឈរមើលសេះនាយកោប ដោយញញឹមគ្មានដាច់ ទាល់តែបាត់ឮសូរជើង ទើបឈប់មើល។ បន្ទាប់ក្រោយពីនេះបន្តិច ហ្វូងសេះរបស់និលពេជ្រ ក៏ចេញដំនើរតាមយ៉ាងកក្រើកដី នាំឲ្យរាត្រីនោះ រន្ធត់ញាប់ញ័រជាពន់ពេក៕

## រឿងមហាចោរនៅទល់ដែនវគ្គទី១១៖តដៃដោះខ្លួន

### ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

កាលមានន្ទ បានទឹកផឹកឆ្អែតឆ្អន់ហើយ អ្នកបំផាយសេះ ទៅភូមិរហាត់ទឹក ដោយបោលកាត់តាមវាលស្រែ ដ៏ធំល្វឹងល្វើយ។ អ្នកបានប្រាប់គេថា អ្នកធ្វើដំណើរទៅបាត់ដំបង ។ ប្រាប់យ៉ាងនេះ ដើម្បីបង្វែងដានទេ។ ដល់ចុងភូមិរហាត់ទឹកនេះ បុរសបំបោលសេះ តម្រង់ទៅផ្ទះមួយតូច ដែលសង់ដាច់ពីគេនៅកៀនព្រៃ។ បុរសម្នាក់ អាយុប្រមាណសែសិបឆ្នាំ កាន់ចន្លុះមួយ ចេញមក។ លុះឃើញស្គាល់ជាក់ថា អ្នកជិះសេះជាមានន្ទ អ្នកកាន់ចន្លុះ ក៏គ្រវីចន្លុះឡើង រីករាយ ហើយស្រែកថា៖

- អា ! ជយោលោកគ្រូ ! ជយោលោកគ្រូ មកពីណា ?

ក្នុងសេចក្ដីរីករាយនេះ ទាំងកាយ ទាំងវាចា របស់អ្នកកាន់ចន្លុះ គេសង្កេតឃើញ នូវការគោរពស្រលាញ់ យ៉ាងខ្ជាប់ខ្ជួន ជ្រាលជ្រៅ។ មានន្ទសំរូតចុះពីលើខ្នងសេះ ដោយអស់កម្លាំងខ្លាំងពេក។ មាណពស្ទុះទៅឱបសហជីវិនចាស់ របស់អ្នក យ៉ាងខ្លាំង ដោយក្ដីរលឹក។ មិត្តចាស់នេះ ឈប់ធ្មឹង បាត់សើចសប្បាយវិញ រួចសួរយ៉ាងស្លុតថា៖

*ឱ ! លោកគ្រូរបួសផង ?

- ថាហើយអ្នកម្ចាស់ផ្ទះ ស្ទុះទៅគ្រាហ៍មានន្ទ ដោយថ្នាក់ថ្នម។

មានន្ទញញឹមឆ្លើយថា៖

- អឺ ! ខ្ញុំរបួស!
- អ្នកណា អាចកាប់លោកគ្រូ ត្រូវយ៉ាងនេះ ?

មានន្ទញញឹមទៀត ។ បុរសកាន់ចន្លុះផ្លាស់ទឹកមុខ ពីស្រពោន ទៅចងចិញ្ចើម។ សម្លេងមួយ បន្លឺលាន់ឮឡើង តិចៗថា៖

- ក្នុងភូមិភាគនេះ មានតែលោកគ្រូមួយទេ ម្ដេចក៏មករបួសយ៉ាងនេះ មកឆាប់អញ្ជើញលោកគ្រូចូលខាងក្នុងភ្លាម។
- អឺ ! ឆាប់ឡើង!
- មានការឬទេ ?
- ប្រហែលមាន បងគីឯងសុខសប្បាយជាទេ ?
- សុខ និង ទុក្ខ ជាធម្មតា តែកុំអាលសិន សម្រាន្តលើគ្រែនេះផ្អែកទៅនឹងខ្នើយ ចាំខ្ញុំដាំទឹក លាងឈាមឲ្យស្អាត រួចចាំខ្ញុំរុំរបួសឲ្យស្រួល មើលៗ តើមុខរបួសធំទេ !
- មិនអីទេ ?
- ឱ ! ព្រះអើយ ! ធំដែរ ម្ដេចឈឺទេ លោកគ្រូ ឈឺខ្លាំង ឬ ?

មានន្ទប្រឹងធ្វើមុខជូរ តែអ្នក ខំប្រឹងញញឹម ឲ្យសហជីវិនរបស់អ្នក បានធូរទ្រូង។

- មិនជាអ្វីទេ!
- លោកគ្រូ សម្រាន្តនៅឲ្យស្ងៀម ទុកខ្ញុំធ្វើការនេះ។

នាយអគ្គីឆ្លេឆ្លា រហ័សជើង ស្ទុះចូលទៅក្នុងផ្ទះបាយ ដុតភ្លើង ដាំទឹក ឆេះឲ្យទង្គោល រួចមកប្រាប់ដៃជើងឲ្យមានន្ទ។ នាយអគ្គីនិយាយ ស្ទើរយំ ថា៖

- ខ្ញុំនឹកលោកគ្រូណាស់។ យើងព្រាត់គ្នាយូរមកហើយ លោកគ្រូបានសុខសប្បាយជាទេ សូមនិយាយរឿងប្រាប់ខ្ញុំផង។
- បងគីឯងជាមិត្តជីវិតមួយ នឹងខ្ញុំ ។ ខ្ញុំក៏នឹករលឹកបងណាស់ដែរ តាំងពីយើងបែកគ្នាមក។ ថ្ងៃនោះ តើបងគីភ្លេចហើយឬនៅ?
- អឺ! គ្មានអ្នកណាអាចភ្លេចបានទេ ភ្លៀងស្រិបៗ ខ្យល់រូវៗ គេដេញបាញ់យើង។ បងគីឯងបែកទៅខ្ញុំ តដៃនឹងខ្មាំង សម្លាប់អស់ជាច្រើន ដល់មានឱកាសល្អ ខ្ញុំគេចផុតឆ្ងាយពីសត្រូវ។ ខ្ញុំរត់រកបងគីឯងគ្រប់កន្លែង ស្រែកហៅ តែពុំឃើញ ខ្ញុំខ្លោចចិត្ត នឹកថា បងគីឯងស្លាប់បាត់ទៅហើយ។ ផុតពីនោះ ខ្ញុំក៏ចូលទៅនៅសិរីសោភ័ណ។ ខ្ញុំសុខសប្បាយជាទេ ពីនោះមក ខ្ញុំមានប្រពន្ធ . . .។

បុរសឈ្មោះអគ្គី កាលឮមានន្ទថ្លែងថាមានប្រពន្ធ ក៏ប្រែជាសប្បាយសើចយ៉ាងស្រស់វិញ។

- យី ! អីលោកគ្រូមានប្រពន្ធហើយ ?

តែមានន្ទធ្វើទឹកមុខស្មើដដែល។

- អឺ ! កុំអរ . . កុំសើច . . គឺជារឿងកម្សត់ . . ខ្ញុំស្រលាញ់គេ គេស្រលាញ់ខ្ញុំ គ្មានសេចក្តីស្នេហាឯណា អាចមកប្រៀបធៀប នឹងសេចក្តីស្នេហា របស់យើងទាំងពីរនោះទេ ។ នាងនោះមានរូបល្អ ។ ឱ! ល្អមែន . . .។

នាយគីទះដៃដោយត្រេកអរ។

- លោកគ្រូមានសំណាងណាស់!

មានន្ទសញ្ចឹងគិត ខាំធ្មេញ ជ្រួញភ្នែក សម្លឹងមើលទៅលើ។

- ទេ ! មិនដូច្នោះទេ ! ក្រោយមកស្រីនេះ......ឱ ! បង អើយ.... ស្រីនេះក្បត់ខ្ញុំ គេលួចមានសហាយ។
- អឺ....បង បង មានសហាយ . . . ?

នាគីប្រែទឹកមុខ ស្រឡាំងកាំង បើកភ្នែកធំ។

- យី ! ម៉េចក៏ដូច្នោះ ?

មានន្ទ ដោយទឹកមុខស្ងួតដដែល និយាយដោយសម្លេងមូលដដែល ថា៖

- កុំឆ្ងល់ ស្រីខូច ស្រីកាឡកណ្ណី ស្រីអប្បលក្ខណ៍។

នាយគីងាកក្បាលសម្លឹងគិត រួចសួរថា៖

- អ្នកណាជាសហាយ ?
- ខ្ញុំនិយាយទៅវាស្លាក់ ខ្ទាក់ទៅវាស្លែង គឺ . . . សហាយនោះគ្មានអ្នកឯណាក្រៅពីខ្ញុំទេ គឺសាច់ខ្ញុំ . . . ឈាមខ្ញុំ សរសៃខ្ញុំ . . .
- អ្នកណា ? អ្នកណា ?

មាននួនៅស្ងៀម យកដៃម្ខាងកាន់ស្មានាយគី ។ អាកប្បកិរិយានេះ ធ្វើឲ្យនាយគី រឹតតែឆ្ងល់ទៅទៀត ។ ភ្នែក ដែលនាយគីមើល ចំមុខមាននួ ភ្នែកទាំងពីរនេះបញ្ចេញនូវរស្មីអង្វរមួយ ដែលធ្វើឲ្យបុរសកើតមានចិត្តអាណិត ស្រងាកក្នុងចិត្ត ។ មាននួ បន្ថែមទៀតថា៖

- កុំចង់ដឹងអី !
- ទេលោកគ្រូ !
- ជារឿងហួសអស់ទៅហើយ។
- ទេ លោកគ្រូ !
- ជារឿងឥតប្រយោជន៍។

នាយគីដាក់ភ្នែកចុះ តែគំនិតរិះគិតរកចំនុចខ្សោយរបស់មាននួ ដែលនិយាយទៅអាច ឲ្យមាននួប្រាប់ខ្លួន ដ្បិតអ្នកមានប្រយោជន៍ នឹងដឹងរឿងរបស់មិត្ត ដ៏ពិសេសថ្លៃថ្លានេះណាស់។ នាយគីស្រលាញ់មាននួនេះ គឺស្រលាញ់ពេកទាល់តែចង់ដឹង នូវអស់រឿងរបស់មាននួ ទោះរឿងនោះជារឿងកំទេចកំទី ក៏ដោយ ឲ្យតែមាននួព្រមនិយាយរឿងឲ្យស្តាប់។ ខាងក្រៅខ្យល់បក់រវិចៗ នាយគីនិយាយស្ងួត ហើយដោយ តិចៗថា៖

- លោកគ្រូប្រហែលមិនទុកចិត្តខ្ញុំហើយ បានជាមិនព្រមនិយាយប្រាប់ខ្ញុំសោះ។

ពាក្យនេះមានសំនួនខ្លាំងមែន ដ្បិតមាននួ បែរមកកាន់ដៃនាយគីជាថ្មីម្តងទៀត រួចប្រាប់ថា៖

- កាមាប្អូនប្រុសខ្ញុំ . . .។
- យី ! កាមាហ៊ានដល់ប៉ុណ្ណឹង ?
- អឺ ! វាហ៊ានលួកថ្លើមខ្ញុំ តែឥឡូវខ្ញុំចាក់វាត្រូវមួយដាវយ៉ាងទម្ងន់ ប្រហែលវាស្លាប់ហើយ ឯខ្ញុំក៏ត្រូវរបួសនេះឯង។
- ឱ ! ព្រះម្ចាស់ថ្លៃអើយ !
- កុំឲ្យខាតពេល ! អឺ កុំឲ្យខាតពេល កុំយំ កុំសើច ខ្ញុំនៅរស់នៅឡើយទេ ។ តែត្រូវដឹងថា ពីពេលនេះទៅជីវិតយើងមានគ្រោះរដឹក រហូតតាមផ្លូវហើយ។
- បាទ ៗ ខ្ញុំក៏សុខចិត្តស្លាប់ រស់ជាមួយលោកគ្រូដែរ។
- ប៉ុន្តែបើស្លាប់ ឬ រស់ក៏ល្អមើល។
- បាទ ! បាទ !

មាននួចាប់បាតដៃនាយគី ប្របាច់យ៉ាងខ្លាំង ជាសញ្ញាយល់ព្រមប្តូរជីវិតជាមួយគ្នា។ បុរសបន្តសេចក្តីទៅទៀត ដូចតទៅ៖

- ទុក្ខយើងជាទុក្ខខ្មែរទាំងអស់គ្នា ។ ខ្ញុំមានគ្រោងការណ៍មួយយ៉ាងធំ។
- គឺអ្វី ?
- គឺ លាងទុក្ខខ្មែរ ធ្វើជនជាតិយើងឲ្យបានរុងរឿងឡើងវិញ។
- ធ្វើយ៉ាងណា ?
- តស៊ូ ! ដូចខ្ញុំតែងនិយាយប្រាប់បងមុនៗ ស្រាប់ហើយ។
- បាទ ! ខ្ញុំក៏តស៊ូដែរ!
- អឺ ! ត្រូវតែយើងតស៊ូ វាយខ្មាំង វាយរបបគ្រប់គ្រង វាយគំនិតខ្ញុំគេ ភ្ជាប់ស្រុកខ្មែរមកខ្មែរវិញ តាមគន្លងអ្នកស្នេហាជាតិ។
- យល់ព្រមពេញទី !

អគ្គីក្រោកឈរលើកដៃសច្ចា ។ មាននួញញឹម។

- តែការតស៊ូ មិនមែនជាការងាយទេ។ អ្នកតស៊ូដើម្បីជាតិ គឺជាអ្នកដែលមានចិត្តស្អាតល្អ ចេះស្រលាញ់គេអាណិតគេ រួចចង់ជួយគេមែនៗ គឺជាអ្នកដែលរម្យទម មិនចេះខឹង មិនខ្លាចការ មានចិត្តអំណត់ ក្នុងកិច្ចការ។ អើបង ! អ្នកតស៊ូ គឺមនុស្ស ដែលហ៊ានលះបង់ប្រយោជន៍ផ្ទាល់ខ្លួន មានបុណ្យសក្តិ ទ្រព្យសម្បត្តិប្រពន្ធកូនជាដើម។ អ្នកតស៊ូមានតែទុក្ខ ជួបតែសេចក្តីក្រ អត់ឃ្លាន គ្មានពេលសប្បាយ ឬ ពេលទំនេរទេ រួចមានពេលខ្លះជាប់គុក រងទុក្ខទោសរហូតដល់ ស្លាប់បង់ជីវិតផង។ ចេញទៅតស៊ូ គឺប្រាសព្រាត់អស់ចំណងស្នេហាទាំងឡាយ ដែលចងយើង ដើម្បីឈោងចាប់យកភពមួយថ្មី ដែលយើងអាចដាក់ឈ្មោះហៅបានថា«ភពឯកា» ឬ «ភពសង្វេគ»។ នៅចុងក្រោយបំផុត ចេញទៅតស៊ូ គឺចេញទៅបួស តែបួសនេះមានន័យធ្ងន់ជាងបួសធម្មតាទៅទៀត គឺបួសដើម្បីព្រះពុទ្ធសាសនាផង រួចដើម្បីជាតិផង ដើម្បីសេចក្តីសុខ និង សេចក្តីចំរើនរបស់មនុស្សទាំងអស់លើទ្វីបលោកផង។
- ទឹកពុះហើយឬ ?

នាយអគ្គីស្ទុះភ្លេតចូលចង្ក្រាន កាន់យកកំសៀវមួយចេញមក អ្នកលាងចានដែកមួយយ៉ាងស្អាត រួចចាក់ទឹកពុះនោះក្នុងចានដែក។ អ្នកយកគមកធ្វើសំលី រួចលុបលាងមុខរបួស យ៉ាងថ្នមៗ រុំរបួសនោះយ៉ាងស្រួល។ បុរសធ្វើផងនិយាយផងថា៖

- គឺជាកិត្តិយសមួយយ៉ាងធំណាស់ ដែលយើងតាំងខ្លួនយើងជាអ្នកតស៊ូនេះ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដោយយល់ច្បាស់ថា

លោកគ្រូ និង ខ្ញុំបានគិតត្រូវ។ មិនអីទេ យើងតាំងខ្លួនយើងជាអ្នកតស៊ូបានពេញទី ពីព្រោះយើងមិនដែលធ្វើអ្វីអាក្រក់នឹងអ្នកណា យើងមិនដែលប្លន់អ្នកណា យើងមិនដែលសេពសុរា លេងបៀ លួចកូនគេ។ យើងជាអ្នកបួសស្រេចទៅហើយ ។ ចុះមិត្តយើងឯទៀតទៅ តាមយើងទេ ?

- ទៅ! ប្រាកដជាទៅដាច់ខាត។
- យើងទៅតាំងទីកន្លែងត្រង់ណា ?
- គង់ដឹងទេ តែឥឡូវនេះត្រូវដឹងថា យើងឈប់ចូលស្រុកហើយ។
- ជយោ ! លោកគ្រូ ! ហ៊ឺ រួចហើយឥឡូវសូមលោកគ្រូសម្រាកចុះ ខ្ញុំយាមមាត់ទ្វារជូន។

មាននួសើច ចាប់ដៃនាយអគ្គីជាប់ នៅស្ងៀមមួយស្របក់ រួចនិយាយថា៖

- យាមឯណា ខ្ញុំមិនទាន់បានសួរបងឯងផង។

នាយអគ្គីមុខស្មើ។

- ឱ ! បាទ !
- តើកាលពីយើងបែកគ្នានោះ បងឯងមានទុក្ខយ៉ាងណាខ្លះ ម៉េចមិនប្រាប់ខ្ញុំផង ?

នាយអគ្គីឡើងស្រងូតស្រងាត់ ឆ្លើយថា៖

- បាទ ! ខ្ញុំបានវាយប្រលូកជាមួយខ្មាំង ដែលពេមខ្ញុំដូចស្រមោច។ គេចាប់ខ្ញុំបាន។ ខ្ញុំនឹកថា អស់បានជួបមុខលោកគ្រូហើយ។ គេយកខ្ញុំ ទៅសម្លាប់។ ខ្ញុំញញឹម មុខក្តីមរណភាពនេះ។ បាទ ! ខ្ញុំញញឹម ព្រោះខ្ញុំពេញចិត្តនឹងស្លាប់ ព្រោះខ្ញុំបានស្លាប់ ដោយបានបំរើបុព្វហេតុមួយ ដ៏ល្អ គឺមាតុប្រទេស និង ជនជាតិយើងពិតៗ។ គាប់ជួនពេលនោះ នៅវេលាយប់ ចង្រិតយំ អំពិលអំពែកហើរ ខ្យល់បក់ ផ្កាយរះព្រោងព្រាត ស្រីម្នាក់ជាបុត្រីមេកង មានចិត្តអាណិតខ្ញុំ បានលួចចូលមកដោះលែងខ្ញុំ។

បរិយាកាសនៃកិច្ចសន្ទនា ក៏ប្រែរីករាយវិញ។ សម្លេង៖

- អូ ! អូ ! អូ !
- បាទ ! នាងនោះល្អ ចិត្តក៏ល្អទៀត គេថាឲ្យខ្ញុំរត់ទៅចុះ។ ខ្ញុំឃើញមុខនាងស្រពិលៗ ។ ខ្ញុំក៏ប្រាប់នាងថា៖
- អូនកុំមើលងាយបង ៗមិនមែនជាមនុស្សចិត្តអន់ រត់ពីកណ្តាប់ដៃខ្មាំងទេ ។ អូនជាខ្មាំង នឹងបង ឥឡូវត្រូវការ អូនហ៊ានយកកាំបិត មកបុកត្រង់ដង្ហើមបង ឲ្យស្លាប់ទៅ មិនគប្បីមកដោះលែងបង ដោយលួចលាក់ទេ។ នាងយំឱបដៃខ្ញុំ ដែលជាប់ចំនង និយាយខ្សឹកខ្សួលថា៖
- ចា៎ះ ប្អូនសូមទោសបង ប្អូនជាមិត្តនឹងបង ដែលមកដោះបងនេះ។ ជាកិត្តិយសមួយ របស់ប្អូន ដោយបានជួយជីវិត អ្នកស្នេហាជាតិម្នាក់។ ប្អូនមិនមែនខ្មាំងរបស់បងទេ ប្អូននិយាយនឹងបង មិនបានវែងឆ្ងាយទេ។ តែប្អូន សូមបងជ្រាបថា សព្វថ្ងៃនេះ ប្អូនជាមនុស្ស។ ពួកនេះ បង្កឲ្យស្រុកយើង បង្ហូរឈាមគ្នា កាប់សម្លាប់គ្នា ព្រាត់ប្រាសគ្នា បែកគូស្នេហា បែកកូនប្រពន្ធ បែកគ្រួសារ ។ ឱបង ! បង ! ពាក្យថាសង្គ្រាមៗ ធ្វើឲ្យប្អូនជាស្រីក្រៀមក្រំជានិច្ច ក្រៀមគ្មានពេលល្ហែ ក្រៀមរាល់វេលា។ យប់ ថ្ងៃ ព្រឹក រសៀល ល្ងាច ប្អូនរាប់ពេលរាប់ម៉ោងនាទី ធ្មេចភ្នែកសួរថា «តើកាលណា ទើបបានសុខ ?» ប្អូនចង្អៀតចិត្តណាស់ បង។

ខ្ញុំឆ្លើយតបថា៖

- ប្អូនមានចិត្តដូចបង បងដែលខំច្បាំងនេះ ក៏ដើម្បីសេចក្តីសុខសាន្ត ត្រាណដែរ។ ដើម្បីឲ្យបានសុខនេះ លុះត្រាតែស្រុក ត្រូវបានជាស្រុកអ្នកជា។ ស្រុកខ្ញុំគេ ចម្បាំងនៅតែមាន។ ស្រុកមិនយុត្តិធម៌ សង្គ្រាមនៅតែឆេះ ។ ស្រុកមានគំនិតប្រកាន់ពួកក្រុម ការភាន់ប្រែ នៅតែកើត។ ចម្បាំងនេះ ពុំមែនធ្វើឲ្យប្អូនខ្លាច ប្អូនព្រួយ យំ បារម្ភនោះទេ . . . ។
- ទេ ! . . . ទេ . . . ប្អូនដឹងច្បាស់ណាស់ថា «បងធ្វើត្រូវ ប្អូនស្អប់ចម្បាំងរុករានទេតើ គឺប្អូនស្អប់ខាងក្រុមពួកខ្ញុំ សព្វថ្ងៃនេះ»។
- បងមិនទៅណាទេ!
- ទេ ! ទេ! សូមបងអាណិតប្អូន អញ្ជើញទៅចុះ ទុកជីវិតបង ដើម្បីបម្រើសន្តានចិត្តខ្ពស់មួយ ដែលជាសន្តានចិត្ត ខ្មែររាល់គ្នា ឲ្យបានសម្រេចទៅចុះ។
- ប្អូនជាខ្មែរ ឬ ខ្មាំង ?
- ចាំះ ! ប្អូនជាខ្មែរ!
- បងទៅណាមិនរួចទេ បងចង់ស្តាប់សម្តីអូន ចង់ស្លាប់រស់ជាមួយអូន។
- ទេ ! បងអាណិតខ្មែរទាំងពួងផង ដ្បិតខ្មែរទាំងអស់ត្រូវការបង . . . ទៅៗ អញ្ជើញទៅចុះ។

នារីយំសោក ស្ទើរបោកខ្លួននៅលើដី ដោយខ្ញុំ ពុំព្រមរួចខ្លួនសោះនោះ។ សូមលោកគ្រូគិតមើល តើឲ្យខ្ញុំទៅណារួច បើខ្ញុំទុកស្រីកម្សត់នេះ ជាកំនប់មាសទៅហើយ។ ដល់ក្រោយមក ខ្ញុំក៏បបួលនាងទៅជាមួយខ្ញុំ ។ ឱ ! រាត្រីកម្សត់។ លោកគ្រូ ! ខ្ញុំសូមសម្រក់ទឹកភ្នែក មួយតំណក់ចុះ នៅលើសេចក្តីស្នេហា ដ៏ស្មោះត្រង់នេះ។ បាទ! នាងព្រមរត់ទៅជាមួយខ្ញុំ ពីព្រោះថ្ងៃជិតរះ ជីវិតខ្ញុំជិតស្លាប់ហើយ។ យើងចេញដំណើរទៅ។ មិនយូរប៉ុន្មាន កងទ័ពខ្មាំង ដេញតាមជាប់ពីក្រោយ។ ឱលោកគ្រូអើយ ! នាងនោះរត់មិនរួច ព្រោះគ្នាពុំធ្លាប់រត់ ដូចពេលនោះសោះ ។ ខ្មាំងក៏កាន់តែជិតមក ជិតមក។ ខ្ញុំដកព្រួញបាញ់វិញ ដោយប្តេជ្ញាថា ឲ្យស្លាប់ជាមួយគ្នាចុះ។ តស៊ូបានប្រមាណ មួយសន្ទុះធំ ខ្មាំងព័ទ្ធជុំវិញខ្លួនអស់។ បាទ ! ពេលនោះព្រួញអាសិរពិសមួយ យ៉ាងកំណាច ស្ទុះមកត្រូវនាងចំកណ្តាលខ្នង ប្អូនជាគូជីវិតដួលដេកលើធរណី ។ ខ្ញុំឱបនាង។ នាងយំ ដោយខ្សឹកខ្សួល ប្រាប់ថា៖

- បងសម្លាញ់ប្អូន ?

ខ្ញុំខ្សឹបប្រាប់វិញថា៖

- បងស្រលាញ់អូន !

នារីញញឹមទឹកភ្នែកហូរសស្រាក់ ដាច់ខ្យល់ស្លាប់ភ្លាម មួយរំពេច។ បាទ ឱ ! ស្លាប់ទៅៗ។

នាយគឺ គ្រវីក្បាល។

មានន្ទអង្អែលខ្នងសួរថា៖

- ចុះយ៉ាងណាទៀត ?

- បាទ !ខ្ញុំប្តេជ្ញាក្នុងចិត្តថា តស៊ូលុះត្រាស្លាប់ ខ្ញុំក៏ហូតដាវចូលប្រកាប់ប្រចាក់។ ខ្ញុំងងឹតមុខ គិតតែពីប្រលូកគ្មានថយ រហូតដល់ ខ្មាំងស្លាប់អស់ជាច្រើន ដួលរណោងលើដី ឆ្លៀតឱកាសនោះ ខ្ញុំក៏ចាប់សេះមួយរត់មកទីនេះ ។ តាំងពីនោះមក ខ្ញុំលែងចង់បានប្រពន្ធទៀតហើយ។

សូរជើងសេះមួយ លាន់ឮឡើង ។ នាយគី ផ្ទៀងត្រចៀកស្តាប់។ មាននន្ទក្រោកអង្គុយប្រុងស្មារតី។ នាយគីស្ទុះភ្លែតទៅខាងក្រៅ។ ក្នុងងងឹត ពាជីមកដល់ នាយគីដកដាវខ្វាច់។ ចុងដាវ នៅលើដើមទ្រូងអ្នកជិះសេះ ជាស្រេច។

- អ្នកណា ?
- អញ!
- អូ អា កោប ! យី ! អាចង្រៃ ម្តេចមកគ្មានឲ្យដំណឹងអញមុន . . .។

នាយកោប លោតពីលើខ្នងសេះ មកឱបអគ្គី យ៉ាងស្និទ្ធស្នាល។

- អញរវល់ណាស់ មិនបានឲ្យដំណឹងអ្វីទេ។ មកទៅក្នុង។
- អាកោបទៅមិនបានទេ ឈប់ ! អាកោប អាឯងហ៊ានតែចូល អញសម្លាប់ឯងចោលឥឡូវនេះ។
- អាឆ្កួត ! មានការ។
- ការអី ?
- អញមកប្រាប់លោកគ្រូ។
- យី ! ម៉េចអាឯងដឹង ?
- ហ៊ឺ រឿងអីអាកោបមិនដឹងនោះ ? ប្រយ័ត្ន ! ការសំខាន់ណាស់។
- ឈរនៅហ្នឹងហើយ ចាំអញទៅជម្រាបគាត់ជាមុនសិន។

ពេលនោះ សម្លេងមាននន្ទលាន់ឮឡើង ពីលើគ្រែក្នុងបន្ទប់៖

- អ្នកណា កោបឬ ?
- បាទ !
- គីឲ្យកោបចូលមក !

នាយគីរុញស្មានាយកោប ឲ្យចូលមក។ នាយកោបធ្វើគារវកិច្ចដោយគោរព៖

- ខ្ញុំបាទមកនេះមានការប្រញាប់ណាស់ ។ លោកតាគិរីសុមេរុ ឲ្យខ្ញុំមកជម្រាបលោកគ្រូថា «គេបានចាត់ទ័ពសេះ មកតាមចាប់លោកគ្រូ ចំនួន១២នាក់»។
- កោបឯងភ័យ ឬ គ្នាប៉ុណ្ណឹង ?
- បាទទេ!
- គី ?
- បាទ ទេ !
- កោប ?

- បាទ !
- ត្រៀមខ្លួន!

នាយកោបញាក់មុខឆ្លើយថា៖

- បាទ!

មាននួក្រោកអង្គុយ ហាក់ដូចគ្មានឈឺអ្វី។

- បាន ! ខ្ញុំទទួលប្រាំនាក់ កោបទទួលបី គឺទទួលបួននាក់។
- បាទ !
- បាទ !

មាននួសួរទៀតថា៖

- អ្នកណានាំមក ?
- និលពេជ្រ!
- អែយ៉ា ! ទុកនិលពេជ្រឲ្យមកខ្ញុំចុះ កាលណាវាមកដល់។

នាយកោបងក់ក្បាល។

- បាទ ! មិនយូរទេ ប្រហែលបន្តិចទៀត ព្រោះខ្ញុំឮសូរជើងសេះ តែពីក្រោយខ្ញុំគគ្រឹក។
- អឺ ! មិនជាអីទេ ។ ឥឡូវ ទៅរាំងទ្វាររបងឲ្យជិត។ កោបនៅម្ខាង គឺនៅម្ខាងមាត់ទ្វារនេះ។ ឯខ្ញុំ នៅពួនគុម្ពផ្កាកណ្ដាល។
- បាទ !
- មានទ្វារ រត់ទៅតាមក្រោយទេ ?

នាយគឺឆ្លើយថា៖

- បាទ ! មានផ្លូវសម្ងាត់មួយ។
- របងគឺឯង ល្មមពួកវាចូលបានទេ ?
- មានតែតាមមាត់ទ្វារប៉ុណ្ណោះ ព្រោះជុំវិញសុទ្ធតែឫស្សី។
- អឺ ! ល្អ ខ្ចិលទៅណា គឺឯងថយមុន កោបថយក្រោយ។
- បាទ !
- បាទ !
- យើងវាយតដៃ ដើម្បីដោះខ្លួន ទៅតាមទ្វារក្រោយណ៎ា !
- បាទ!
- បាទ!
- ដល់ខាងក្រៅតោងបំបែកគ្នា រួចទីជួបគ្នា គឺមាត់ពាមទន្លេសាប ព្រំប្រទល់ខ្មែរ -សៀម។

- ទល់ដែន!
- ទល់ដែន !
- កុំភ្លេចចូលទៅហៅអារុណ មហាកាល ស្រទំ ស្បៃវែងផងណ៎ា !
- បាទ !
- បាទ !
- ឥឡូវ ទៅចាំនៅទីកន្លែងរៀងខ្លួនចុះ ព្រោះឮសូរជើងសេះ មកដល់ហើយ។

និលពេជ្រ នាំទ័ពបំផាយសេះ យ៉ាងលឿន ទាំងកណ្ដាលយប់។ នៅតាមផ្លូវ និលពេជ្របានសាកសួរដល់ពល ដែលមកជាមួយ តើអ្នកណាស្គាល់ផ្ទះនាយគី នៅរហាត់ទឹក ។ មានទាហានម្នាក់ឈ្មោះសាន បានឆ្លើយឡើងថា៖

- បាទស្គាល់។

បានជានិលពេជ្រសួរដូច្នោះ ពីព្រោះដឹងច្បាស់ថា សេនាជំនិតដែលមានន្ទមាន នៅជិតនេះ គ្មានអ្នកណាក្រៅពីអគ្គីទេ។ អ្នកធ្លាប់ស្គាល់អគ្គីនេះ ដែលជាមនុស្សពូកែឆើតឆាយមួយដែរ។ មានន្ទត្រូវរបួសផង ប្រាកដជាទៅជ្រកផ្ទះអគ្គីមិនខាន។ អាស្រ័យហេតុនេះ អ្នកបញ្ជាទាហាន ឲ្យបំបោលសេះ កាត់វាលតម្រង់ទៅភូមិរហាត់ទឹកតែម្ដង ទើបឆាប់ការ។ ក្នុងដំណើរ ដ៏ស្រូតរូតនេះ អ្នកឮសូរជើងសេះមួយ ខាងមុខដែរ តែអ្នកនឹកស្មានថា ជាសេះរបស់អ្នកស្រុកធម្មតាទេ។ កាលបើនាយសានឆ្លើយថា បានស្គាល់ផ្ទះអគ្គីច្បាស់ និលពេជ្រត្រេកអរយ៉ាងក្រៃលែង។ គ្រោងការណ៍មួយវាត់ក្លែត ក្នុងបញ្ញាអ្នក គឺគ្រោងការណ៍ឡោមចាប់មានន្ទឲ្យបាន។

លុះបានទៅដល់ជិតផ្ទះអគ្គីហើយ អ្នកបញ្ជាឲ្យទាហានទាំងអស់ ចុះពីលើខ្នងសេះរៀងខ្លួន រួចឲ្យសានដើរលបៗ ទៅស្ដាប់មើល។ នាយសាន ថ្វីដ្បិតតែធ្លាប់តយុទ្ធ មកច្រើនគ្រាណាស់មកហើយក៏ដោយ ក្នុងពេលនេះ ក៏នៅមានសេចក្ដីតក់ស្លុត យ៉ាងខ្លាំង។ បេះដូងគាត់ញ័រ រំភើប ដៃគាត់ឡើងត្រជាក់អស់។ គាត់លូនបន្តិចៗ ទៅមុខ ត្រាតែបានទៅដល់ផ្ទះអគ្គី ដូចប្រាថ្នា។ គាត់លបមើលតាមមាត់ទ្វារ គ្មានឃើញអ្វីសោះ។ ក្នុងផ្ទះស្ងាត់ឈឹង តែឃើញទ្វារពុំទាន់បិទ ចង្កៀងមួយឆេះប្លុងៗ។ អ្នកលូនថយក្រោយដូចក្ដាម ត្រលប់ទៅរាយការណ៍ ប្រាប់និលពេជ្រវិញ។

- ម៉េចមានឃើញអ្វីខ្លះ ?
- ឃើញទ្វារបើក ចង្កៀងមួយប្លុងៗ។
- ប្រហែលមានមនុស្សទេ ?
- ប្រហែលដេកលក់អស់ហើយ។
- បើដូច្នោះទៅ !

កងទាហានទៅដល់មាត់ទ្វារ ។ នាយសានលូកដៃទៅប្រានទ្វារ របងទ្វារពុំរបើក ដោយចាក់សោជាប់។ និលពេជ្រសួរខ្សឹបៗ ថា៖

- ម៉េចបើកទ្វាររួចទេ ?
- បាទទេ ! ជាប់សោ ។ ធ្វើយ៉ាងណាទាន ?

- ទៅរក លើកជណ្ដើរផ្ទះខាងមុខនោះ សិនមក តែប្រយ័ត្នម្ចាស់គេដឹងណា ! ម្យ៉ាងទៀត ប្រយ័ត្នឆ្កែព្រុសផង។
- បាទ !

សានក៏ស្ទុះ ទៅលើកជណ្ដើរផ្ទះរបស់អ្នកស្រុកម្នាក់ យកមកផ្អែកលើទ្វារ។ នាយសានឡើងជណ្ដើរភ្លាម ឥតបង្អង់។ លុះមកដល់លើទ្វារហើយ នាយសានក៏បែរគូទ ទម្លាក់ជើងទាំងពីរចុះ ដៃទាំងពីរចាប់ខ្លោងទ្វារ ធ្វើឲ្យនាយសាន ធ្ងន់ខ្លួនយើងយោង។

នាយកោប ដែលលិទ្ធអណ្ដាត រង់ចាំចំណី ដល់បានឃើញខ្មាំងមកដូច្នោះ ក៏ស្ទុះរឹងទៅកាប់មួយដាវចំពីក្រោយ ត្រង់គល់ក ។ នាយសានលាន់សម្លេង ឮងឹក រួចធ្លាក់ខ្លោកដល់ដី។

និលពេជ្រ ដែលនៅខាងក្រៅនឹកថា នាយសានបានដល់ដីហើយ រួចមុខជាមកបើកទ្វារមិនខាន តែចាំបាត់ៗ៖ និលពេជ្រខ្សឹបហៅ៖

- សាន ! សាន ! ទៅណាបាត់អន្តរជាននេះ អាជីទៅមួយទៀតបន្តគ្នាទៅ។

នាយជីជឹកមុខឡើងជណ្ដើរ ដល់ចុង ក៏វាត់ជើងស្ទុះចុះមក។ ក្នុងពេលនោះ ដាវអគ្គីលៀនចេញផ្លេ ពីគុម្ពផ្កាមក តែនាយជីវាយរងដាវទាន់ ដាវទាំងពីរក៏ប្រកួតគ្នាឮផាំងៗ ដូចរន្ទះកណ្ដាលយប់ស្ងាត់។ ពួកខាងនិលពេជ្រស្រែកថា « មានពួកវារើយ !» ។ លំដាប់នោះ នាយទាហាន ក៏ជ្រុះមកក្នុងរបងផ្ទះនាយគី ខ្លោកៗ បន្តបន្ទាប់គ្នា ដូចគ្រាប់ភ្លៀង។ នាយកោប និងអគ្គី តយុទ្ធម៉ាំងៗ យ៉ាងអង់អាច។ និលពេជ្រមកដល់ក្រោយគេ បញ្ជាឲ្យឈប់។

- ឈប់ ! អ្នកណាហ្នឹង ?

អគ្គីឆ្លើយថា៖

- អញ!
- អឺ ! គីទេឬ ?
- អឺ ! អញ ម៉េចនិលទេឬ ? ឯងមកលេងនឹងអញឬ ?
- អឺអញៗ មកលេង!
- បើមកលេង មកកុំបង្អង់ !
- ឯងមកមានការអីទាំងយប់ ? (អគ្គីសួរបន្ថែម)
- អញមកជាតំណាងច្បាប់។

នាយកោបចេញពីគុម្ពផ្កាមក សើចក្អាកក្អាយ៖

- ហាសៗ តំណាងច្បាប់ ! មានតែចោរទេ ដែលចូលក្នុងរបងផ្ទះគេ ដោយលបៗ ។ អ្នកតំណាងច្បាប់ មិនធ្វើដូច្នោះទេ។
- យី ! អាកោប អញមកនេះមានសំបុត្រ។
- ចាំភ្លឺស្រួលបួលទៅពូ ! មានអី។

- អាកោប អញមិនខ្ជិនិយាយនឹងឯងទេ។

និលស្ទុះទៅមុខ ភ្នែកមើលទៅក្នុងផ្ទះ ។ អគ្គីលើកដាវកាប់ រាំងដើមទ្រូងនិលពេជ្រ។

- មិនបានទេ ! មិត្តទៅណាមកណា ទៅមិនបាន។
- អញទៅក្នុងផ្ទះ។
- ប្លន់ឬ ?
- អញចាប់មនុស្សទោស។
- គ្មានមនុស្សទោសទេ នៅនេះមានតែអ្នកជាទាំងអស់។
- មាន ។
- ទៅមិនបាន ទៅស្លាប់ឯង ឬ ស្លាប់អញ !
- ព្រះកម្មុតឲ្យអញមកណា។
- ទេវតាឲ្យមកក៏ត្រូវឈប់ ដ្បិតអគ្គីមិនឲ្យចូលទៅ។
- ឯងរឹងទទឹងនឹងច្បាប់ឬ ?
- ឯងរកចាប់អ្នកណា ?
- មានន្ទ !
- ហ៊ឹសៗ អាក្រពើ វង្វេងបឹង!
- មានន្ទនៅឯណា?
- នៅនេះ ?
- សម្លេងមានន្ទលាន់ឮឡើងពីកៅអីមួយ ដែលនៅក្នុងងងឹត។ មានន្ទដើរស្ទុងៗ ចេញមកយ៉ាងខែង ដៃពត់ចុងដាវតូចស្តើងមួយ ដែលចាំងផ្លេកៗ។
- រកខ្ញុំធ្វើអី ?
- ក្នុងនាមនៃច្បាប់ ខ្ញុំសូមចាប់ សូមអញ្ជើញអានសំបុត្រនេះទៅចុះ ។

មានន្ទកញ្ឆក់សំបុត្រ ពីដៃនិលពេជ្របាន ញីហែកខ្ទេចខ្ទី គ្រវាត់ចោលទៅ។ និលពេជ្រខឹង ខ្ជួលឡើង។

- យី ! ម៉េចព្រះតេជគុណ ហ៊ានហែកសំបុត្រព្រះកម្មុត ?
- ខ្លាចអី សំបុត្រមិនត្រឹមត្រូវតាមច្បាប់។
- មិនមែនទេ ! បោះត្រាលោកផងណា!
- អើ! ត្រាមែន តែសំបុត្ររំលោភ ឲ្យចាប់យើងទាំងយប់ គ្មានច្បាប់ណាឲ្យចាប់ដូចនេះទេ។
- អាកូន ! ចូលចាប់ !

មានន្ទថយក្រោយបីជំហាន គ្រវាសដាវ និយាយយ៉ាងសង្ហាថា៖

- ចាប់មានន្ទបាន លុះត្រាតែធ្លាក់អាវុធពីដៃ។

នាយកោប និង នាយគី ក៏ថ្លែងសកម្មភាពជំនាលគ្នា ដាវលាន់ឮឆាំងៗ ចែសៗ ឡើងពីរោះ ដូចសូរនាតដែក។ បីទល់នឹងពីរ ជាទីគួរដែរ។ មានន្ទវាយផ្ទួងៗ ពីរបីដាវ ស្ទុះទៅកាប់អាម្នាក់នៅចំហៀងខាង ដួលច្រប្រោងជើង បាត់ស្មារតី រួចស្រែកថា៖

- មួយហើយរើយ !

មានន្ទវាយថយ រត់ទៅគេច នឹងគល់ឈើ ដែលធ្វើឲ្យខាងនិលពេជ្រវិលមុខ។ ដោយងងឹតផង អ្នកតជាប់ដៃ ចុងដាវសត្រូវ ខ្វែងខ្វាត់ ប្រវាត់គ្នា ច្រុះនឹងចុងដាវអ្នក។ មានន្ទគេចទៅពួន ឯគល់ឈើមួយទៀត។ ខាងនិលពេជ្រ រកមិនឃើញ រោ។ មានន្ទស្រែកហៅ ថា៖

- ឯនេះទេរើយ ! មក !

កងនិលពេជ្ររត់ទៅ មានន្ទគេចទៅម្ខាង វាយខ្នងនាយជីផ្ទួង មួយដាវអស់ទំហឹង ដែលនាំឲ្យជីភ័យជាអនេក។ ដល់ដឹងថា មានន្ទ ក៏ស្ទុះហក់ដេញ តាមប្រកិត ។ ចំនែកខាងនាយកោប និង អគ្គី ក៏បង្កើតបរិយាកាសកំប្លែងលេងលាយមែនដូចគ្នា។ យូរៗ នាយកោប បែរទៅសើចដាក់អគ្គីម្តង។ មានន្ទញញឹមយ៉ាងរីករាយ នឹងស្ថានការណ៍រីករាយនេះ។ លុះចេញដល់ក្រៅរបង ជនទាំងបី ចេះតែវាយថយ រហូតទៅដល់នឹងហ្វូងសេះ របស់កងនិលពេជ្រ ដែលចងតម្រៀបគ្នា។ មានន្ទបញ្ជាយ៉ាងខ្លាំង ថា៖

- ឡើងសេះ !

នាយកោប និង អគ្គីហ៊ើសដូចសូរ ដល់លើខ្នងសេះជាស្រេច ក៏បំផាយសេះទៅ ដោយមានជនខាងនិលពេជ្រ ដេញជាប់ពីក្រោយ។ រីឯមានន្ទ កាលស្រែកបញ្ជា ស្ទុះរឹងភ្លាមដែរ តែទាក់ជើងនឹងកូនឈើមួយ ដួលព្រូស។ មានន្ទរមៀលខ្លួន បណ្តោយដូចផ្លែក្រូច រួចក្រោកឈររឹបរិញ តដៃទៅទៀតយ៉ាងអង់អាច។ និលពេជ្រស្ទុះមករាំងផ្លូវ មិនឲ្យមានន្ទឡើងសេះរួច ។ និលពេជ្របញ្ជា ឲ្យទាហានម្នាក់ លែងខ្សែសេះ ឲ្យរត់ទៅឆ្ងាយពីទីនោះ។ តែមានន្ទទាត់ត្រូវមួយជើង ដួលផ្កាប់មុខ ដោយមិនដឹងខ្លួន។ កងខាងនិលពេជ្រ រោមមានន្ទដូចស្រមោច ប៉ុន្តែវៀតតែមានខ្លះ ត្រូវរបួសច្រើនអន្លើណាស់ទៅហើយ។ មានន្ទគេចខ្លួនបាន ក៏លោតលើខ្នងសេះបំផាយទៅ។ និលពេជ្រក៏បញ្ជា ឲ្យកងពលឡើងសេះតាមទៅដែរ។ មានន្ទ រត់ឆ្លងអូរ ឆ្លងជ្រោះ យ៉ាងលឿន ។ និលពេជ្រព្យាយាមតាមជាប់ពីក្រោយ មិនឈប់ឈរ។

ព្រះអរុណ រះស្វាងឡើង ។ សេះមានន្ទ កាន់តែដាបទៅៗ រីឯខ្មាំង កាន់តែជិតមកៗ។ មានន្ទមើលឃើញទាំងអស់មានប្រាំមួយនាក់ ។ អ្នកនឹកថា តើគេចខ្លួនយ៉ាងណា ឲ្យរួចទាន់ភ្លឺមិនទាន់ច្បាស់នេះ។ ដល់ដើមអំពិលមួយ អ្នកលោតទៅចាប់មែកអំពិល តោងឡើងទៅពួននៅស្ងៀម។ សេះដោយភ័យចេះរត់ទៅមុខ ។ កងនិលពេជ្រ ចេះតែដេញតាមប្រកៀក។ មានន្ទមើលពីក្រោយ ឃើញហុយធ្លុប អ្នកសើចយោលខ្លួន រួចចុះមកគេចទៅខាងជើង។ ទៅតាមផ្លូវ អ្នកដោះឡេវអាវផ្តុំខ្យល់ ដកដង្ហើមវែងៗ ឲ្យមានកម្លាំង។ មាណពនឹកថា ខ្យល់ព្យុះ មុខជាផុតរលត់មិនខាន។ អ្នកដើរបណ្តើរ ហួចបណ្តើរ បីដូចអ្នកគង្វាលគោម្នាក់ ដែលគ្មានដឹងឮ ដល់រឿងអ្វីសំខាន់ឡើយ។ បុរសចេះតែក្រលេកមើលក្រោយ ម្តងៗ ក្រែងខ្មាំងដេញតាមមកទៀត។ អ្នកសម្លឹងមើលព្រៃឈើរកនឹក «តើជាព្រៃភូមិណា ស្រុកណា ? » ។ ពន្លឺព្រះអាទិត្យ ក៏ឡើងថ្លាត្រចង់ គួរជាទីសប្បាយ។ តាមផ្លូវដើមរុក្ខជាតិធំ តូច ដុះណែនណាន់តាន់តាប់ ខ្ពស់ទាប។ អ្នកនឹកថា ស្រុកខ្មែរ ជាស្រុកមានភោគទ្រព្យក្រៃពេក ពុំគួរនៅក្រោមអំនាចខ្មាំងសោះ។ អ្នក

នឹកទៀតថា «ពួកនិលពេជ្រ ស្លាប់ថ្ងៃនេះ ក៏ក្រេលដែរ គឺខ្មាំងស្លាប់ នឹងដៃអ្នកជាច្រើន អ្នកមិនខាតទេក្នុងម្ភៃមួយម៉ោងចុងក្រោយនេះ។

សត្វកុក ដែលនៅប្របផ្លូវ ពួនសម្ងំចឹកត្រី ក្នុងថ្លុកមួយ ផ្អើលឈូហើរឡើង។ មានន្ទភ្ញាក់ព្រើត ក្រាបពួន តែដល់មិនឃើញអ្វី ក៏ដើរទៅមុខទៀត។ អុញនុ៎ះ ! ឃើញវាលស្រែទេតើ។ មានអ្វី ? មានន្ទញញឹមគិតថា «ឱ ! ភូមិកុយមែងទេតើ » អ្នកបែរសសៀរ យកជើងព្រៃ។ លុះដល់ផ្ទះមួយ ដែលនៅចុងភូមិ អ្នកឡើងភ្លាម ចូលទៅក្នុងបន្ទប់បិទទ្វារបាត់៕

## រឿងមហាចោរនៅទល់ដែនវគ្គទី១២៖អាសន្នធំ

### ដោយសព្វវចនាធិប្បាយសេរីវិគីភីឌា

គឺជាផ្ទះមួយ ដ៏សមរម្យ ដែលមានន្ទពួន ធ្វើអំពីឈើប្រក់ក្បឿង មានទីធ្លាធំតាមឋានៈខ្មែរជនកណ្ដាល។ តែក្នុងភូមិកុយមែងនេះ ផ្ទះប៉ុណ្ណោះជាផ្ទះមួយ ដ៏រុងរឿងណាស់ទៅហើយ កណ្ដាលចំណោមផ្ទះឯទៀត ដែលសុទ្ធសឹងតែជាកូនខ្ទម រយីករយាក។

មានន្ទចូលក្នុងបន្ទប់មួយ រួចបិទទ្វារជិតស្លុង។ មាណព មើលឃើញគ្រែពូកស្អាត មុងសស្គុស។ អ្នកនឹកថា ប្រហែលជាបន្ទប់ដេកហើយ។ នៅកៀនគ្រែមានតុមួយ ប្រដាប់ដោយកញ្ចក់តាំង ស្និតសិតសក់ កែវម្សៅ កែវល្មៀត ដបទឹកអប់ផង។ មានន្ទចាប់អារម្មណ៍ថា «លោ១ ជាបន្ទប់កូនក្រមុំគេ ក៏មិនដឹង ?។ បុរសត្រិះរិះមើល តើឧត្ដម មិត្តចាស់របស់អ្នក មានកូនក្រមុំទេ ? ទេ! វាមិនដែលមានកូនឯណាទេ។ ចុះវា លក់ផ្ទះនេះ ឲ្យទៅអ្នកណាមួយ ហើយឬ? តែតាមតុទូក្នុងផ្ទះ ដែលធ្លាប់ដូចបានស្គាល់ពីមុន មកហើយ គឺតុ ទូ ដដែលសោះ។

អតីតសង្ឃានោងទេវី ភិតភ័យយ៉ាងខ្លាំងនឹងរឿងនេះ ។ ណាមួយនៅភូមិកុយមែង មានភ្នាក់ងាររាជការ របស់ឪពុកអ្នកផង ប្រហែលជាពួកអស់នេះ បានទទួលកិច្ចបញ្ជាពីសិរីសោភ័ណមក ឲ្យជួយចាប់អ្នកជាប្រាកដ។ ណាមួយទៀតដៃអ្នក ដែលពីម្សិលមិញ បានលាងរុំនោះ ក៏ឈឺចាប់ចុកយ៉ាងខ្លាំង ពីព្រោះអ្នកបានតស៊ូ ដើម្បីរំដោះខ្លួន ឲ្យបានរួចជីវិត ពីយប់មិញ មកនេះ។ អ្នកកម្លោះ យកដៃឆ្វេងស្ទាបមើល ឃើញហើម ធ្វើឲ្យឈឺក្រៃពេក។ រីឯ ពូកខ្នើយ ធ្វើឲ្យអ្នកងងុយដេកយ៉ាងខ្លាំង តែពុំហ៊ានប្រាសខ្នង ដល់ឡើយ ។ អ្នកនឹកថា « ចុះឧត្ដម វាទៅណា ? វាភ្លេចអ្នក ហើយឬនៅ ? ពីព្រោះមិត្តទាំងពីរនេះ ឃ្លាតគ្នា តាំងពីកាលនៅវ័យកុមារ រៀង១ខ្លួនមក។

ខាងក្រៅ ឮសូររទេះបរបោក់ឃឹប១ ចូលមកក្នុងរបងផ្ទះ។ មានន្ទ លបស្ដាប់ ឮសូរមាត់ស្រីជជែកងេកងោក១ អំពីដូរស្រូវលក់ថ្លៃ តថ្លៃ ទិញប្រហុក ។ បន្ទាប់មក ទើបអ្នកឮសូរមាត់ឧត្ដម ដែលអ្នក នៅចាំសម្លេង នៅឡើយ។ បុរសត្រេកអរយ៉ាងខ្លាំង ដោយទើបបានដឹងប្រាកដថា ជាផ្ទះមិត្តចាស់របស់អ្នកពិតមែន។ ក្នុងពេលនោះ ឧត្ដមជជែករ៉ូងរ៉ាំងរួច ក៏ចូលមកបើកទ្វារបន្ទប់ ដែលមានន្ទនៅពួន មានន្ទស្ទុះទៅខាងទ្វារ កំបាំងខ្លួនបាត់ នឹងទ្វារ ដែលបើកមក។ លុះឧត្ដម បានចូលស៊ប់ ដល់ក្នុងបន្ទប់ហើយ មានន្ទរាំងទ្វារជិតភ្លាមមួយរំពេច។ ឧត្ដមស្រឡាំងកាំង ទើបដឹងហើយស្គាល់ថា ជាមានន្ទ ក៏ស្ទុះទៅ ឱបមិត្តកម្សត់នេះ។

- យី ! មកពីណា ? ម៉េចឯងមកពួននៅទីនេះ ? មានរឿងអ្វី ?

មានន្ទយកដៃខ្ទប់មាត់ឧត្ដម៖

- កុំមាត់ខ្លាំង គេឮ!
- មិត្តឯងសុខសប្បាយជាទេឬ ?
- សុខសប្បាយទេ តែក្នុងពេលនេះយើងមានរឿង . . . ។

មានន្ទប្រានឧត្ដមចេញ និយាយយ៉ាងនឹងនួនទៅទៀតថា៖

- យើងជាមនុស្សអសិរពិស តើឯងអាចទទួលយើង ឲ្យនៅទីនេះបានទេ?

ឧត្តមធ្វើទឹកមុខស្រងូតស្រងាត់៖

- រឿងអ្វី ? ធំប៉ុន្មាន ?

មាននន្ទក៏រ៉ាយរ៉ាប់រឿង ប្រាប់ឧត្តមដោយគ្រួសៗ តាំងពីដើមដល់ចុង។ លុះស្តាប់ចប់សេចក្តី ឧត្តមសើចទះស្មាមាននន្ទយ៉ាងរីករាយ។

- ឯងនៅទីនេះបាន។ គោងទុកផ្ទះនេះ ដូចជាផ្ទះឯង ។ តើឯងបម្រុងនៅប៉ុន្មានថ្ងៃ?
- ប្រហែលបីថ្ងៃ។
- កុំភ័យអី ចាំអញជួយលាក់បំពួនឯង រួចជួយរក្សាឯងឲ្យជា។
- ឥឡូវឯងបាយទឹក រួចហើយនៅ ?
- ទេកុំឲ្យឯងព្រួយអី ! អញបាយរួចហើយ តែសុំទឹកមួយផ្តិលមក។
- អុះ ! ណ្ហើយកុំ . . . !
- ម៉េច ?
- ក្រែងគេដឹងច្រើនគ្នា!
- ហ៊ី ! ឆ្កួតអញគ្មានឲ្យអ្នកណាដឹងទេ។

ថាហើយ ឧត្តមបើកទ្វារចេញទៅក្រៅ រួចបិទទ្វារវិញយ៉ាងស្រួល។ គឺបុរសម្នាក់ អាយុប្រមាណសាមសិបឆ្នាំ មុខមាំស្លូតបូត សម្តីម៉ាត់ៗ។ បន្តិចក្រោយមក បុរសដ៏ប្រពៃនេះ ត្រលប់ចូលមកក្នុងបន្ទប់វិញ កាន់ទឹកមួយផ្តិលមក ហុចឲ្យមាននន្ទ។ មាននន្ទទទួលផ្តិលទឹកនេះ រួចផឹកឮក្អឿកៗ។ ឧត្តមច្រត់ចង្កេះ មើលមិត្តកម្សត់របស់អ្នក ដោយស្នេហា៖

- ហ៊ឹសៗ តាំងពីណាមក កាលណាអញជួបនឹងឯង គឺមានតែរឿងមួយទេ គឺរឿងទឹកមួយផ្តិលប៉ុណ្ណោះឯង។

មាននន្ទផឹកទឹកឆ្អែត ទៅអង្គុយលើគ្រែ ។ ឧត្តមទៅអង្គុយជិតទន្ទឹមស្មាគ្នា។

- ឯងដេកក្នុងបន្ទប់នេះចុះ
- ចុះឯងទៅដេកឯណា ?
- ហ៊ី ! អញតាមបានទេ ដេកឯណាក៏បាន អូ ! ចាំអញ ទៅប្រាប់ប្រពន្ធអញ ឲ្យគេដឹងផង។

មាននន្ទទាញស្មាឧត្តមជាប់។

- កុំ !
- ហ៊ី ! ឆ្កួត មានអី កុំភ័យឲ្យសោះ បើឯងមានគ្រោះថ្នាក់ អញសាកដៃអញម្តង ឲ្យឯងឃើញ។

ឧត្តមក៏ទៅខ្សឹបដាក់ត្រចៀកនាង យីហ៊ុប ជាភរិយា។ គឺជាស្រីម្នាក់ អាយុប្រមាណម្ភៃឆ្នាំ ស្គមខ្ពស់ ភ្នែកមាន់ សម្រស់ល្អ សម្តីលះ ចេះខ្នះខ្នែង ក្នុងការរកទទួលទាន និងចេះរាក់ទាក់ ក្នុងការទទួលភ្ញៀវពន្លឺ។ ដំបូងនាងភ័យ សួរប្តីថា៖

- រឿងអី ? អ្នកណា ?

- ពួកម៉ាកបង!
- ឈ្មោះអ្វី ?
- មាននន្ទ!
- ឱ ! លោកមាននន្ទ គាត់នៅឯណា ? លោកអើយ ! ខ្ញុំខានឃើញគាត់យូរមកហើយ។
- ក្នុងបន្ទប់ផ្ទះយើង។ តែកុំមាត់ឲ្យសោះ។

ឧត្តមក៏និយាយរឿងមាននន្ទ ប្រាប់នាងយីហ៊ុប ឲ្យបានដឹង ។ នាងយីហ៊ុប ក៏ចូលទៅសំពះ សួរមាននន្ទ។

- ចា៎ះ ! អញ្ជើញលោកសម្រាន្ត នៅកន្លែងនេះចុះ ។ ចំនែកខ្ញុំ និងប្ដីខ្ញុំ មិនជាការអ្វីទេ។

ថាហើយ នាងយីហ៊ុប ក៏លាចេញមក បើកទូ យកសារុង កន្សែងជូនទៅមាននន្ទ ឲ្យផ្លាស់។ រួចនាងដាំទឹកក្ដៅ យកមកឲ្យ មាននន្ទស្អំដៃ។ ថ្ងៃនោះ ភរិយាស្វាមី ខ្នះខ្នែងយ៉ាងអស់ពីចិត្ត តាំងពីម្ហូបអាហារទទួលទាន រហូតដល់កន្លែងដេកពួន និងប្រដាប់ប្រើប្រាស់ ផ្សេងៗ ។ លុះដល់ពេលស្រស់ស្រូបរួច មាននន្ទដោយអស់កម្លាំងខ្លាំងពេក និទ្រាលក់យ៉ាងស្កប់ស្កល់។ ភ្ញាក់ឡើង អ្នកឃើញនាងយីហ៊ុប អង្គុយនៅចុងជើង អ្នកហុចទឹកមួយផ្តិល ឲ្យលុបមុខ ជូនផ្លែក្រូចដែលបកសម្បកស្រេច ឲ្យបរិភោគ ។ មាននន្ទទើបឃើញមុខនាងច្បាស់ អ្នកនៅផ្ទឹង រួចនាងសើច។

- បង ! ភ្លេចខ្ញុំហើយឬនៅ ?
- បាទ ! ខ្ញុំប្រហែលៗអ្នកដែរ។
- ខ្ញុំនៅសិរីសោភ័ណ។
- ផ្ទះអ្នកណា ?
- ឪពុកខ្ញុំ ពូកែវមណី។
- អូ ! អូ ! អត់ទោស ខ្ញុំភ្លេចហើយ ខ្ញុំទើបតែនឹកឃើញ។ ឱ! យើងបែកគ្នាយូរណាស់មកហើយ តាំងពីយើងនៅតូចៗ . . .។

អនុស្សាវរីយ៍កម្សត់មួយ ងើបផុសចេញពីផ្នូរចាស់មក។ មាននន្ទនឹកឃើញនាងយីហ៊ុប ឡើងវិញពេញទី ។ អ្នកឃើញនាងបេះផ្លែត្របែក យកឲ្យអ្នក ឃើញនាង និងអ្នកលេងលោតអន្ទាក់ ក្រោមដើមក្រខុប។ នាងយីហ៊ុប នឹកឃើញដូចគ្នា ដែរ។ គឺនាងហើយ ដែលចាប់និយាយតទៅទៀត៖

- ខ្ញុំឃើញថា បងមិនភ្លេចខ្ញុំទេ!
- បាទ ! ខ្ញុំឥតភ្លេចអ្នកទេ!
- ចា៎ះ ! កុំហៅខ្ញុំអ្នក គោងហៅខ្ញុំដូចដូចកាលយើងនៅពីតូចៗ។
- អូនសុខសប្បាយជាទេ?
- ចា៎ះ ប្អូនសុខសប្បាយជាទេ។
- អូន ! រៀបការយូរហើយ ?
- ចា៎ះ ពីរឆ្នាំហើយ!

- ការនៅឯណា ?
- ការនៅបាត់ដំបង ។ កាលនោះ ខ្ញុំទៅនៅបាត់ដំបង ជាមួយឪពុកធំខ្ញុំ។
- បាទ ! បាទ ! មែនហើយ ឧត្តមទៅណាហើយ ?
- ចាំះ ! ទៅកំពង់ក្រោមហើយ។
- ឆ្ងាយទេ ?
- ល្ងាចបានគាត់វិលត្រលប់មកវិញ។

នារីខិតចូលជិតមាននូ ។ នាងចង់និយាយអំពីរឿងផ្សេងៗ ជាច្រើន តែនាងនឹកថា «នាងមានប្តីហើយ»។ មាននូក្រោកអង្គុយឡើង ប្រុងប្រយ័ត្ន មិនឲ្យប៉ះពាល់ដល់ភរិយាគេទេ រឿងចាស់ជារឿងចាស់។ គោងបង្កប់រឿងចាស់ ក្នុងផ្នូរមួយ រួចបំភ្លេចចោល កុំបីនឹកនា។ គប្បីកុំជម្រុញរឿងថ្មី រហូតដល់ទៅមានតំណាមួយ ដែលអាចក្លាយទៅជា កម្មទៀត ។ ហេតុនេះត្រូវកាន់ចិត្តរឹង ក្នុងរឿងនិយាយគ្នា ជាការសំខាន់បំផុត។ នាងយីហ៊ុបចាប់ដៃមាននូ ស្រាយរបួសស្អំទឹកក្តៅះ

- ប្អូនជួយធុរៈបងទេ ! យើងមិនមែនស្រលាញ់គ្នាទេ ប្អូនមានប្តីហើយ។

មាននូសើច ។ សំណើច សម្រស់ទឹកមុខ នាំឲ្យនាងព្រឺខ្លួនខ្ញាកៗ តែនាងចេះតែខំប្រឹងទប់ជានិច្ច។

- បងដឹងថាប្អូនមានប្តីហើយ តោងជឿចិត្តបងចុះ។
- ប្អូនជឿ ចាំះ ! បងឈឺទេ ?
- ឈឺ។
- ប្អូនធ្វើតិចៗ។ សូមបងនៅផ្ទះប្អូន ទម្រាំដល់ជាមុខរបួស ចាំអញ្ជើញទៅចុះ។
- បងអរគុណណាស់ តែបងនៅទីនេះមិនបានយូរទេ។
- បង ! មានការអី ?
- មានការប្រញាប់ ជួបនឹងគេ។
- ឯណា ?
- នេះជាការផ្ទាល់ខ្លួនបង មិនមែនជាភារៈសំខាន់ទេ ។ តែនៅទីនេះ មានក្រុមអ្នករាជការទេ ?
- មាន ! ម៉េចបងភ័យឬ បានជាធ្វើទឹកមុខស្លូតយ៉ាងនេះ ?
- បងកំពុងរបួស ហើមដៃអស់ រកការពារខ្លួនមិនបានទេ។
- មិនអីទេ បើមានរឿងអី ប្អូននាំបងទៅពួនក្នុងជង្រុកស្រូវនោះ។ នុ៎ះបងមើលឃើញទេ ?
- ឃើញ . . . អើស្រួលហើយ។
- តែល្ងាចនេះ មានបងប្អូនខ្ញុំម្នាក់ទៅភ្នៀត។
- កាលណា បានគេចេញដំណើរទៅ ?
- យប់បន្តិច ដ្បិតពិបាកចាប់គោណាស់។ ខ្ញុំឲ្យគាត់ខ្ចីរទេះខ្ញុំ។
- គេដឹកអ្វីទៅ ?
- អត់ដឹកអ្វីទេ ។ ឱ ! គេដឹកចំបើងទៅ។ ឥឡូវចាំប្អូន រៀបចំបាយទឹកជូនបង។

- មានអ្វីខ្លះថ្ងៃនេះ ?
- ចាះ ! អត់មានអ្វីទេ តែខ្ញុំបានធ្វើមាន់មួយជូនបង។
- អរគុណណាស់។

មានន្ទ ដោយសេចក្ដីពាក់ទាក់ដែលនាងឃីហ៊ុប បានធ្វើដោយស្មោះត្រង់បំផុតនេះ អ្នកភ្លេចខ្លួន ភ្លេចឈឺ ភ្លេចគ្រោះថ្នាក់ ។ នាងសើចតបវិញយ៉ាងព្រងើយ រួចចេញទៅ។

ព្រះសុរិយាជិតអស្ដង្គត ចោលពន្លឺល្អះល្អ ទន់ភ្លន់មកលើពសុធា។ មានន្ទឮសូរមាត់ឧត្ដម ដែលទើបវិលត្រលប់ ពីកំពង់មកវិញ។ ក្រៅពីមាត់មិត្តនេះ អ្នកឮសូរមាត់ស្រីប្រុស ឯទៀតជាច្រើន ដែលលើកចំបើងដាក់រទេះ។ ទ្វារបន្ទប់របើកឡើង។ នាងឃីហ៊ុប លើកបាយល្ងាចជូនលាយទាំងសំណើច ញញឹមមួយ ដែលបុរស ពុំអាចភ្លេចបានឡើយ។ នៅកៀនមាត់ ដែលហើបបន្តិចនេះ មានន្ទសង្កេតឃើញធ្មេញតូចស្មើ ដែលចាំងរលើបដូចត្បូង។ ខាងក្រៅ ភ្ញៀវទាំងឡាយ ចូលមក។ ឧត្ដម ទទួលភ្ញៀវប្រុស ស្រី ដែលមកបរិភោគបាយ យ៉ាងរកាកដូចសត្វ ចូលសម្បុក។

រាត្រី ក៏ត្រដាងស្បៃងងឹត មកពាសពេញ។ ពន្លឺកូនចង្កៀងក្នុងផ្ទះឧត្ដម ក៏ឆេះឡើង បន្តពីពន្លឺព្រះសុរិយា ដែលរលត់ទៅ ថ្មីៗនេះ។ បន្តិចមក មានន្ទឮសូរជើងសេះ សន្ធឹកសន្ធាប់មកដល់។ អ្នកស្លៀកពាក់ព្រឹបគ្មានបង្អង់ ចងដាវព្យួរនឹងចង្កេះ ផ្លុះកញ្ចាក់ លបចាំស្ដាប់។ ចិត្តអ្នក ញាប់ញ័រយ៉ាងខ្លាំង។ ជនអ្នកជិះសេះ ឡើងមកលើផ្ទះ ។ ឧត្ដមចេញទៅទទួល។

- ជម្រាបសួរលោក !
- លើកដៃថ្វាយព្រះ។
- ទាន! លោកអញ្ជើញមកមានការអីទាន ?
- លោកមានឃើញអ្នកទោសម្នាក់ រត់មកជ្រកនៅទីនេះទេ ?
- អ្នកទោស ?
- បាទ! អ្នកទោស!
- មិនឃើញអ្នកទោសណាទេ។

និលពេជ្រមើលនាយអាយ។ ឧត្ដម ឡើងស្លាំង បន្តពាក្យទៅទៀតថា៖

- គ្មានអ្នកណាក្រៅពីគ្រួសារខ្ញុំទេ។
- អត់ទោស ! ខ្ញុំសុំឆែក។
- លោកមិនចាំបាច់ឆែកទេទាន !
- ខ្ញុំមានសំបុត្រពីអ្នករាជការធំមក។

និលពេជ្រហុចសំបុត្រឲ្យទៅឧត្ដមមើល។ កងទាហាន ក៏ចូលមើលក្នុងបន្ទប់ផ្ទះ រកមើលក្រោមគ្រែ បើកទូ រកមើលតាមពាងទឹក និងកៀនកោះសព្វគ្រប់ តែឥតមានឃើញអ្វី។ ឧត្ដម មានក្ដីតក់ស្លុត យ៉ាងខ្លាំង។ លុះចូលក្នុងបន្ទប់មិនឃើញមានន្ទវិញ ក៏អ្នកហាក់ធូរដើមទ្រូងបន្តិច តែព្រួយបារម្ភ មិនដឹងមិត្តនេះ ទៅឯណាបាត់ទៅហើយ។

និលពេជ្រនិយាយថា៖

- ខ្ញុំបានដឹងការច្បាស់ថា ចោររបស់ខ្ញុំរត់មកជ្រកនៅទីនេះតាំងពីព្រឹក។
- បាទទេ ! ប្រហែលលោកច្រលំហើយមើលទៅ ពីព្រោះបើរត់មកនៅទីនេះ មុខជាឃើញមិនខាន បើឆែកគ្មានសល់រន្ធមួយ យ៉ាងនេះ។
- បាទ ! មិនប្រាកដដែរ តែសូមលោកអត់ទោសចុះ។
- បាទទេ ! មានការអីទាន ចាំក្រោយៗ អញ្ជើញមកទៀត ខ្ញុំទទួលលោកដាយរាក់ទាក់ជានិច្ចទាន !

និលពេជ្រក៏លា ចុះទៅវិញ ។ ឧត្តមសុំអញ្ជើញ អង្គុយពិសាតែសិន ក៏មិនព្រម ។ ឧត្តមបានជូនកងអ្នករាជការនេះ ដល់មាត់ជណ្ដើរ។ នាងឃីហ៊ុប កាលឧត្តមចូលមកវិញ ក៏ស្ទុះទៅប្រាប់ឧត្តម ជាប្ដីយ៉ាងញ័រមាត់ថា៖

- ខ្ញុំបានបង្ហាញជង្រុកនោះឲ្យគាត់ពួន។
- អូនឯងឆ្លាតមែន។
- តែប្អូនខ្លាចក្រែងពួកវារើជង្រុកទៀតណ៎ា !

ក្នុងពេលនោះ ពូកនិលពេជ្ររើជង្រុកមែន។ នាងឃីហ៊ុប យកដៃទាំងពីរខ្ទប់មុខ។ ឧត្តម ស្ទុះយកដាវ ប្រាប់ភរិយាថា ៖

- តែប៉ុណ្ណោះយើងចោលផ្ទះហើយ។

នាងឃីហ៊ុបចាប់ដៃប្ដីជាប់។

- កុំបង ! កុំ ! គ្នាគេច្រើនណាស់
- ទេ ! មិត្តរបស់បងមានអាសន្នធំហើយ តោងស្លាប់រស់ជាមួយគ្នា។
- ទេបង ! ទេ !

ឧត្តមចោលកន្ទុយភ្នែក ទៅជង្រុក តាមចន្លោះបង្អួច ។ តែអ្នកមិនឃើញ ចាប់បានមានន្ទសោះ។ អ្នកបែរទៅរក នាងឃីហ៊ុបវិញ៖

- ម៉េចពួកវា រកមានន្ទមិនឃើញ ក្នុងជង្រុក ?
- ប្អូនមិនដឹងជាគាត់ទៅពួនឯណាទៀតទេ។ ប្រហែលគាត់ចេញទៅ ពួនឯណាទៀតហើយ។

ឧត្តមដាក់ដាវ ទៅនឹងជញ្ជាំងវិញ ឈានផ្លោះរំលងបីបួនកាំជណ្ដើរ ចុះទៅជួបនិលពេជ្រ។

- ខ្ញុំបាទជម្រាបថា នៅទីនេះគ្មានចោរទេ លោកមិនជឿខ្ញុំ ។ ម៉េចរកឃើញទេលោក ?
- ខ្ញុំត្រូវរកឲ្យសព្វកន្លែង។
- បាទ ! ខំរកទៅក្រែងបានឡើងបុណ្យសក្តិបន្តិចទៀត

និលពេជ្រពេបមាត់ ដោយអៀនប្រៀន។ ឧត្តមឡើងទឹកមុខថ្លា។

- ខ្ញុំបាទជាខ្មែរអ្នកសប្បុរស រួចបើកងរាជការ មករុកកួនយ៉ាងនេះ មុខជាខូចចិត្តច្រើន ជាមិនខាន។

- ខ្ញុំធ្វើនេះ សម្រាប់ជាប្រយោជន៍អ្នករាល់គ្នាទេតើ ?
- ឱ ! មិនមែនដោយឈ្នានីស ដោយចង់យកគាប់គួរ ឬដោយចង់បានបុណ្យសក្តិទេ ?
- តោងលោកជ្រាបថា ខ្ញុំជាមនុស្សកាចណាស់ ក្រៅពីលោកខ្ញុំទះកំផ្លៀងហើយ។
- អ្នកកាន់អំនាច មិនដែលទះកំផ្លៀងជនអ្នកស្លូតត្រង់ទេ ? តើចោរនោះចិន ឬ យួន ?
- ខ្មែរ!
- អូ ខ្មែរ ! ខ្ញុំមានសេចក្តីសោកស្តាយណាស់ តាមរបៀបរកចាប់ទាំងព្រលឹម ខ្ញុំស្មានថាជាចិន ឬ ជ្វា។

មុខនិលពេជ្រ ឡើងក្រហម។ និលពេជ្រស្រែកដល់កងទាហាន ឲ្យចាប់សេះរុករានពេញភូមិ ទាំងអស់។ កងនិលពេជ្រ បែរទៅរកផ្ទះជិតខាងទៀតទៅ។

ក្នុងពេលនោះ បងប្រុសរបស់ឧត្តម ដែលកំពុងបរិភោគបាយជាមួយ ក៏លាឧត្តមទៅភូមិភ្នៀត គឺលោកឧត្តុង្គ ។ គាត់មានបុត្រីមួយ ឈ្មោះនាងមាលា រូបល្អគួរសម ដែលបរិភោគបាយ ជាមួយគាត់។ ក្នុងពេល ដែលគេឆែកឆេរផ្ទះ នាងមាលា គ្មានតក់ស្លុតអ្វីទេ។ និលពេជ្រចេះតែលបមើលនាង ម្តងជាពីរដងដែរ។ នាងដឹងខ្លួន ខាំធ្មេញខឹងនឹងនិលពេជ្រជាពន់ពេក។ លុះលាឧត្តម ជាឪពុកមាហើយ នាងឡើងលើរទេះ អង្គុយលើចំបើង យ៉ាងស្រួលបួល។ ឪពុកនាង លោកឧត្តុង្គ បររទេះទៅ ក្រោយដែលបានលានាងយីហ៊ុប និងឧត្តមដែលបានជូននាងដល់រទេះ។ តាមផ្លូវ នាងមាលានិយាយថា៖

- យី ! ខ្ញុំមិនដែលឃើញពួក អីក៏មហាតម្ល៉េះ ? ចូលរុករានផ្ទះគេទាំងអំណាច ឫកក្រអើតគ្រប់គ្នា។
- អញ្ចឹងហើយពួកគេនោះ។
- ពួកអាអស់នេះ បានតែកាប់ចោលឲ្យអស់ទេ។ ហ៊ឺ ! និយាយពីអាមេគេនោះ វាធ្វើឫកសង្ហាណាស់ ច្រត់ដៃចំខែង។

ពូឧត្តុង្គ ជាឪពុក បង្អុយបារីស្លឹកសង្កែបណ្តើរ ស្តាប់បុត្រីបណ្តើរ ដែលប្រាសខ្លួនដេក ខាងលើចំបើងឯណោះ ។ យូរៗ អ្នកឆ្លើយសម្របថា៖

- អឺ !

នារីបន្តសម្តី យ៉ាងស្រួយស្រះ ទៅទៀត៖

- វាសុទ្ធតែរកចោរ ៗ។ វាចេះតែពាក្យមួយម៉ាត់នេះ មើលទៅ។ ឲ្យតែចង់ចាប់អ្នកណា អ្នកនោះចោរហើយ។ ហ៊ឺ ! បន្តិច

ទៀតវាមកចាប់យើង វាថាយើងចោរដែរមិនខាន។ ឱ ! ពុកអើយ ! បើលោតែ វាហ៊ានចាប់ពុក ខ្ញុំប្រថុយស្លាប់ នឹងពួកអាវាតត្បាត នេះម្តង។ ខ្ញុំខឹងណាស់។ ពួកអានេះ វាថាស្គាល់ខ្មែរ ក៏ដូចជាមិនស្គាល់ខ្មែរ។

- អឺ ! ខ្មែរយើងចិត្តគ្រាន់បើ តាំងពីដើមមក។
- ខ្ញុំស្អប់វាណាស់។ ធ្វើម្តេច ឲ្យមានខ្មែរណាបះបោរឡើង ខ្ញុំជួយខ្មែរនោះទាំងចិត្ត ទាំងធនធានមិនខាន។
- គ្មានអ្នកណាចង់នៅខ្ញុំគេទេ តែគ្មានខ្មែរណាហ៊ានហើបទេ ព្រោះគេដឹង គេសម្លាប់ចោលទៅ។

- គិតទៅអាណិតគ្នា អ្នករត់នោះ។ ប្រហែលមិនដឹង ជាគ្នាកិតភ័យយ៉ាងណាទេ ។ ខ្ញុំលបសួរមីងយីហ៊ុប ៗថា «មិនមែនចោរឯណាទេ គាត់នោះឈ្មោះមានន្ទ» ។ គាត់ជាមេទ័ពណាំពុក «មេទ័ពរបស់ព្រះកម្ពុត» ។ គេរកចាប់គាត់ ដោយរំលោភតែម្តង។ គាត់ជាមនុស្សសុចរិតទេ។
- អ្នកណា ? មានន្ទ ? ឪពុកស្គាល់ហើយ មានន្ទ ត្រូវជាកូនបង្កើតរបស់ព្រះកម្ពុត នេះឯង ។ ឱ! បើមានន្ទ អាណិតស្រណោះ មែន ពីព្រោះគាត់នោះខែងណាស់ ចិត្តស្រលាញ់ញាតិខ្មែរណាស់។ គាត់និយាយតែពីខ្មែរ កាន់ជើងខ្មែរ ការពារខ្មែរ ដាស់ទឹកចិត្តខ្មែរ។ ហ៊ី ! មានន្ទ ហ្ន៎ ! ។ អាក្រក់មែន ពួកអាប្លន់នគរនេះ។ ឱ ! ដូចនោះហើយ បានជាគេរកចាប់។ តែមិនអីទេ ទេវតាខ្មែរ គង់ជួយឲ្យមានន្ទ រួចពីភយន្តរាយមិនខាន ខ្មែរនឹងឈ្នះអស់មារ សត្រូវមិនខាន។ ឱលោកអើយ ! ខ្ញុំបន់ មួយថ្ងៃដប់ដង មួយរយដង ឲ្យខ្មែរយើងឈ្នះម្តងលមើល តើវាទៅណាទៅ អាពួកចោរពិតៗនោះ ? សព្វថ្ងៃឫកវា ធំណាស់ ឲ្យតែមានជ័យវិញម្តង បានតែចាប់សម្លាប់ចោល ទើបសមមុខវា។

កិច្ចសន្ទនារវាងបិតា និងបុត្រី មានជាហូរហែ រហូតតាមផ្លូវទៅ គ្មានឈប់ឈរឡើយ។ លុះរទេះយើង បានទៅដល់ភូមិភ្នៀត រទេះបរចូល ទៅក្នុងផ្ទះមួយ យ៉ាងគួរសម។ នាងមាលាចុះពីលើចំបើង និយាយទៅកាន់ឪពុកនាងថា៖

- ពុកអញ្ជើញទៅលើផ្ទះចុះ ទុកឲ្យខ្ញុំយករទេះទៅទុក យកគោទៅឯក្រោល។

ឧត្តុង្គញញឹមរកបុត្រី ជាសញ្ញាទទួលយល់ព្រម។ នាងមាលា បររទេះតម្រង់ចូល ទៅក្នុងខ្ទមតូចមួយនៅជិតនោះ។ ព្រះអាទិត្យ ដែលលិចទៅយូរហើយ បណ្តាលឲ្យក្តីងងឹត គ្របដណ្តប់ពាសពេញ។ គេមើលឃើញ តែចន្លុះនារី ដែលបញ្ចាំងពន្លឺក្រហមភ្លឹបភ្លែតៗ។

នាងដោះគោរួច នាងនាំទៅចងឯក្រោល ។ នាងត្រលប់មកវិញ អូសរទេះ បញ្ចូលក្នុងខ្ទមនោះ ។ ស្រាប់តែបុរសម្នាក់ ឈរនៅពីមុខនាង ប្រលាក់ចំបើងស្រមាម។ នាងភ្ញាក់ហៀបនឹងស្រែកឡើង តែនាងនឹកឃើញថា មិនមែនចោរទេ។ នាងមើលមុខបុរសនេះ សម្រេចបានជាមនុស្សស្លូតត្រង់។ ទឹកមុខបុរស ហាក់អង្វរឲ្យនាងជួយធុរៈមួយ យ៉ាងធំ។ បុរសហាត់អស់កម្លាំង។ ភ្នែកប្រុសដែលមើលនាង ធ្វើឲ្យនាងអាណិត ។ នាងសួរថា៖

- អ្នកឯងមកពីណា ?
- អ្នកជិះខ្ញុំមក !
- ទេ ! ខ្ញុំអត់ជិះអ្នកឯងទេ ។
- បើមិនជិះខ្ញុំ ម៉េចអ្នកបានមកដល់ទីនេះ?
- ឱ ! អីអ្នកឯងនៅពួនក្នុងចំបើង ?

មានន្ទសើច ងក់ក្បាល។ នាងមាលាដឹងជាក់ថា មានន្ទប្រាកដ។ បុរសឃើញថា នាងតក់ស្លុតយ៉ាងខ្លាំង ដោយភ្នែកនាងដាក់ចុះ។ កាយវិការរបស់យុវតី ធ្វើឲ្យមានន្ទដឹងថា នាងមិនដែលនិយាយ ជាមួយប្រុសណាក្នុងទីស្ងាត់ ដូចនេះសោះ។

- ចូរអ្នកកុំភ័យបារម្ភអ្វី!
- ខ្ញុំមិនមែនខ្លាចទេ គឺលោកទេដែលត្រូវភ័យនោះ។ ឥឡូវតើលោកបម្រុង អញ្ជើញទៅណាទៀត ?
- ដើររកអ្នកមានសប្បុរស និង នារីដែលមានរូបល្អ ចិត្តល្អដូចអ្នក។
- លោកអាចជ្រកនៅក្នុងផ្ទះខ្ញុំនេះសិន ចាំខ្ញុំទៅជម្រាបលោកឪពុកខ្ញុំ។

មាននូចាប់ដៃនាងជាប់មិនឲ្យទៅ។

- ទេ ! កុំ ! ខ្ញុំសូមអរគុណណាស់ ដោយមានចិត្តអនុគ្រោះ មកដល់ខ្ញុំយ៉ាងនេះ ខ្ញុំមិនភ្លេចទេ អស់មួយជីវិតខ្ញុំ ។ ទៅជម្រាបលោកធ្វើអ្វី ពីព្រោះខ្ញុំជាសត្វពស់ តែគេដឹងឮ មុខជាអ្នក ក៏មិនបានសុខ ។ ហេតុនេះ ខ្ញុំសុំតែទឹកមួយផ្តិលទេ បើអ្នកមេត្តា ចែកទានផង។
- ចាំះ ! មានអី ចាំខ្ញុំដងមកជូន។
- សូមកុំទៅប្តឹងគេណ៎ា !
- បើដូច្នោះ ខ្ញុំមិនទៅទេ ទុកឲ្យលោកស្រេកស្លាប់ចុះ !
- បើអ្នកមានចិត្តករុណាមែន ៗ អ្នកអាចអញ្ជើញបាន។

នារីរត់យ៉ាងលឿន ផ្លោះកាំជណ្តើរចុះមកវិញ បានទឹកមួយផ្តិលយ៉ាងស្អាត ។ មាននូផឹកទឹកក្អឹកៗ។ នាងមាលាមានចិត្តមេត្តា ដល់បុរស ជាពន់ពេក។

- ខ្ញុំស្តាយណាស់ដោយគ្មានពេលយូរ នឹងនិយាយជាមួយអ្នក។ អរគុណ នឹងទឹកមួយផ្តិលណាស់។
- ទៅណាវិញ ? កុំអាលទាន់ទៅ . . . ចាំ . . . ចាំះ !
- វាសនាយើង បានជួបគ្នាតែប៉ុណ្ណោះទេ។ ខ្ញុំទៅមុខទៀត។
- ខ្ញុំត្រេកអរណាស់ ដោយសារបានជួប រួចបានជូនទឹកមួយផ្តិលដល់ខ្មែរម្នាក់ ដែលស្រលាញ់ខ្មែរឯទៀត។

មាននូផ្ទៀងក្បាលស្តាប់សម្តី ដ៏ពីរោះនេះ រួចនិយាយថា៖

- បើផែនដីខ្មែរទាំងមូលមានកុលបុត្រ ប្រកបដោយចិត្តដូចអ្នក ប្រហែលជាខ្ញុំមិនរងទុក្ខដូច្នេះទេ។ តែឥឡូវខ្ញុំទើបយល់ជាក់ថា ក្នុងដំណើរការជាតិ ដែលខ្ញុំកំពុងពុះពារនេះ ខ្ញុំហាក់ដូចឃើញកាន់តែជាក់ថា ពុំមែនមានតែខ្ញុំមួយទេ។
- ចាំះ ! គឺខ្ញុំមួយដែរ។
- ជយោ ! នារីខ្មែរ !
- ជយោ ! វីរបុរសខ្មែរ ! ឥឡូវយកសេះឪពុកខ្ញុំទៅ ។ លោកមានសោហ៊ុយទេ ?
- បាទ ! គ្មានទេ!
- លោកយកកញ្ចប់កន្សែងខ្ញុំនេះ ទៅចុះ។

ក្នុងពេលនោះ នាងមាលា ឮសូរមាត់ឪពុកនាងហៅ៖

- មាលា ! មាលា !

- ចាំះ !
- មក ម៉េចក៏យូរម្ល៉េះ ?
- អាល័យតែរលត់ចន្លុះពុក ចាំខ្ញុំរកភ្លើងអុជសិន។

នាងធ្វើ ឲ្យរលត់ចន្លុះ ។ នាងស្តាយ ដោយអស់ពន្លឺ នឹងទៅរកមើលមុខបុរសទៀត មិនបាន។ មានន្ទវាចាតទៅទៀតថាៈ

- សូមលាអ្នកហើយ ។ ថ្ងៃណាមួយគង់ជួបគ្នាវិញទេ។
- ចាំះ ! អញ្ជើញចុះ ឲ្យបានសុខសប្បាយ។

មានន្ទឱនគំនាប់នាងមាលា យ៉ាងគោរព ។ នាងមាលាស្ទើរស្ទុះទៅចាប់ដៃបុរស ដែលសំពះនាង ។ តែនាងមានសេចក្តីអៀន ខ្មាស ដែលឃាត់នាងមិនឲ្យធ្វើដូចនោះកើត។ នាងរំជួលក្នុងចិត្ត ឥតឧបមា។ កល្យាណឃើញបុរសយកអានដាក់លើខ្នងសេះ ឃើញបុរសលោតទំលើខ្នងសេះ ឃើញបុរសគំនាប់នាងជាលើកចុងបង្អើយ ឃើញសេះចេញទៅទិសខាងកើត បាត់ក្នុងក្តីងងឹត។ ភ្នែកនាង ហាក់លែងបានឃើញពន្លឺរស្មី នៃសេចក្តីស្នេហាដ៏ល្អមួយ រួចមានតែសេចក្តីស្តាយមួយម៉ាត់ទេ ដែលរស់នៅយ៉ាងរវើក ក្នុងចិត្តនាង។